ព្រះ
ត្រៃបិដកបាលី
និង
សេចក្ដីប្រែជាភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ ជាតក
ឆដមភាគ
៦០

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស. ២៥០២

សុត្តន្តបិដកេ

ខុទ្ទកនិកាយេ ជាតកំ

ឆដ្ឋោភាគោ

៦០

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស ជាតកំ

ឆដ្ឋោ ភាគោ

បកិណ្ណកនិបាតជាតកំ

សាលិកេទារជាតកំ[1]

(១) សម្បន្នំ សាលិកេទារំ សុវា ភុញ្ជន្តិ កោសិយ
បដិវេទេមិ តេ ព្រហ្មេ ន នេ វារេតុមុស្សហេ
ឯកោ ច តត្ថ សកុណោ យោ នេសំ សព្វសុន្ទរោ
ភុត្វា សាលឹ យថាកាមំ តុណ្ឌេនាទាយ គច្ឆតិ ។

(២) ឱឌ្ឌេន្តុ វាលបាសានិ យថា ពជ្ឈេថ សោ ទិជោ
ជីវញ្ច នំ គហេត្វាន អានយេហិ មមន្តិកេ ។

(៣) ឯតេ ភុត្វា បិវិត្វា ច បក្កមន្តិ វិហង្គមា
ឯកោ ពទ្ធោស្មិ បាសេន កឹ បាបំ បកតំ មយា ។

---

១ ម. សេកកេតកំ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

ឆដ្ឋភាគ

បកិណ្ណកនិបាតជាតក

សាលិកេទារជាតក

(១) *(បុរសអ្នកឆ្មាំស្រែពោលថា) បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែ បរិបូណ៌ផល ពួកសេកតែងស៊ី បពិត្រព្រាហ្មណ៍ ខ្ញុំសូមជំរាបលោក ខ្ញុំមិនអាចឃាត់ឃាំងពួកសេកទាំងនោះបានឡើយ បណ្ដាសេកទាំងនោះ មានសេកមួយ ដែលល្អជាងបក្សីឯទៀតទាំងអស់ ជាងសេកទាំងនោះ ស៊ីស្រូវសាលី តាមសេចក្ដីត្រូវការហើយ ក៏ពាំស្រូវដោយចំពុះហើរទៅទៀត ។*

(២) *(សាលិទ្ទិយព្រាហ្មណ៍ ពោលនឹងបុរសនោះថា) ជនទាំងឡាយ ចូរដាក់អន្ទាក់ធ្វើដោយកន្ទុយសេះ បក្សីនោះនឹងជាប់ ចូរអ្នកចាប់កាន់វាទាំងរស់ នាំមកក្នុងសំណាក់នៃអញ ។*

(៣) *(សេកនោះពោលថា) បក្សីទាំងនុ៎ះ ស៊ីផង ផឹកផង ហើយហើរចេញទៅ តែអញម្នាក់ឯងជាប់អន្ទាក់ហើយ តើអញធ្វើហើយនូវអំពើលាមកដូចម្ដេច ។*

(៦) ឧទរំ នូន អញ្ញេសំ   សុវ អច្ចោទរំ តវ
ភុត្វា សាលឹ យថាកាមំ   តុណ្ឌេនាទាយ គច្ឆសិ ។
កោដ្ឋំ នុ តត្ថ បូរេសិ   សុវ វេរំ នុ តេ មយា
បុច្ឆិតោ មេ សមក្ខាហិ   កុហឹ សាលឹ និធេយ្យសិ[១] ។

(៧) ន មេ វេរំ តយា សទ្ធឹ   កោដ្ឋោ មយ្ហំ ន វិជ្ជតិ
ឥណំ មុញ្ចាមិណំ ទម្មិ   សម្បត្តោ កូដសិម្ពលឹ
និធឹបិ តត្ថ និទហាមិ   ឯវំ ជានាហិ កោសិយ ។

(៨) កីទិសំ តេ ឥណទានំ   ឥណមោក្ខោ ច កីទិសោ
និធិនិធានមក្ខាហិ   អថ បាសា បមោក្ខសិ ។

(៩) អជាតបក្ខា តរុណា   បុត្តកា មយ្ហ កោសិយ
តេ មំ ភតា ភរិស្សន្តិ   តស្មា តេសំ ឥណំ ទទេ ។
មាតា បិតា ច មេ វុឌ្ឍា   ជិណ្ណកា គតយោព្វនា
តេសំ តុណ្ឌេន ហាតូន   មុញ្ចេ បុព្វកតំ ឥណំ ។

---
១ ម. និទហសិ ។ ឱ. និធហសិ ។

(៦) (ព្រាហ្មណ៍...) ម្នាលសេក ពោះសេកទាំងឡាយដទៃ (ជាពោះល្មម) ដោយពិត (ចំណែកខាងពោះ) របស់អ្នក ជាពោះធំក្រៃពេក ព្រោះថាអ្នកស៊ីស្រូវសាលីតាមសេចក្ដីប្រាថ្នារួចហើយ ក៏កាំយកស្រូវដោយចំពុះហើរទៅ ។ ម្នាលសេក អ្នកចាក់បំពេញជង្រុកក្នុងព្រៃនោះឬ ឬក៏អ្នកចងពៀរនឹងយើង ម្នាលសំឡាញ់ យើងសួរហើយ ចូរអ្នកប្រាប់ អ្នកកប់ស្រូវសាលីទុកក្នុងទីណា ។

(៧) (សេកពោល...) ខ្ញុំមិនចងពៀរជាមួយនឹងអ្នកទេ ជង្រុករបស់ខ្ញុំក៏មិនមានដែរ ខ្ញុំដោះបំណុលចាស់ ឲ្យខ្ចីបំណុលថ្មី ខ្ញុំហើរទៅដល់ដើមគរ ក៏កប់កំណប់ទុកក្នុងព្រៃនោះ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ ។

(៨) (ព្រាហ្មណ៍...) ការឲ្យខ្ចីបំណុលរបស់អ្នកដូចម្ដេច ការដោះបំណុលដូចម្ដេច អ្នកចូរប្រាប់នូវការកប់កំណប់ កាលបើដូច្នោះ អ្នកនឹងរួចចាកអន្ទាក់ ។

(៩) (សេកពោល...) បពិត្រកោសិយៈ ខ្ញុំមានកូនតូចៗ មិនទាន់ដុះស្លាប នៅខ្ចីនៅឡើយ កូនតូចទាំងឡាយនោះ ដែលខ្ញុំចិញ្ចឹមហើយនឹងចិញ្ចឹមខ្ញុំវិញ ហេតុនោះ ខ្ញុំឲ្យខ្ចីបំណុលដល់កូនតូចៗទាំងនោះ ។ ម្យ៉ាងទៀត ខ្ញុំមានមាតាបិតាចាស់ព្រឹទ្ធា មានវ័យកន្លងហើយ ខ្ញុំកាំ (នូវស្រូវសាលី) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ខ្ញុំឈ្មោះថាដោះបំណុលដែលគាត់ធ្វើហើយមុន ។

អញ្ញេបិ តត្ថ សកុណា ខីណបក្ខា សុទុព្ពលា
តេសំ បុញ្ញត្ថិកោ ទម្មិ តំ និធឹ អាហុ បណ្ឌិតា ។
ឦទិសំ មេ ឥណទានំ ឥណមោក្ខោ ច ឦទិសោ
និធិនិធានមក្ខាមិ ឯវំ ជានាហិ កោសិយ ។
(៨) ភទ្ទកោ វតាយំ បក្ខី ទិជោ បរមធម្មិកោ
ឯកច្ចេសុ មនុស្សេសុ អយំ ធម្មោ ន វិជ្ជតិ ។
ភុញ្ជ សាលឹ យថាកាមំ សហ សព្វេហិ[១] ញាតិភិ
បុនបិ សុវ បស្សេម បិយំ មេ តវ ទស្សនំ ។
(៩) ភុត្តញ្ច បីតញ្ច តវស្សមម្ហិ[២]
រតី ច នោ កោសិយ តេ សកាសេ
និក្ខិត្តទណ្ឌេសុ ទទាហិ ទានំ
ជិណ្ណេ ច មាតាបិតរោ ភរស្សុ ។
(១០) លក្ខី វត មេ ឧទបាទិ អជ្ជ
យោ អទ្ទសាសឹ បវរំ ទិជានំ
សុវស្ស សុត្វាន សុភាសិតានិ
កាហាមិ បុញ្ញានិ អនប្បកានិ ។

១ ម. សព្វេភិ ។ ២ ម. តវស្សមម្ហិ ។

ក្នុងព្រៃនោះមានបក្សីទាំងឡាយដទៃទៀត ដែលមានស្លាបអស់ហើយ ថយថយកំឡាំង ខ្ញុំត្រូវការដោយបុណ្យ ក៏ឲ្យដល់បក្សីទាំងនោះ បណ្ឌិតទាំងឡាយពោលថា បុញ្ញកម្មនោះជាកំណប់ ។ ការឲ្យបុលរបស់ខ្ញុំយ៉ាងនេះ ការដោះបំណុលរបស់ខ្ញុំយ៉ាងនេះ ខ្ញុំប្រាប់នូវការកប់កំណប់ ម្នាលកោសិយៈ អ្នកចូរដឹងយ៉ាងនេះ ។

(៨) (ព្រាហ្មណ៍...) បក្សីនេះគំរាប់ពិតពីដើមនេះ ប្រសើរណាស់ហ្ន៎ ជាសត្វប្រកបដោយធម៌ដ៏ក្រៃលែង មនុស្សពួកខ្លះមិនមានធម៌នេះ ។ អ្នកចូរហិតនូវស្រូវសាលី ជាមួយនឹងពួកញាតិទាំងអស់ តាមប្រាថ្នាចុះ ម្នាលសេក សូមឲ្យយើងឃើញអ្នកទៀត ព្រោះការបានឃើញនូវអ្នក(នេះ) ជាទីស្រឡាញ់របស់យើង ។

(៩) (ស្តេចសេក...) ម្នាលកោសិយៈ ខ្ញុំបានបរិភោគផង ផឹកផង ក្នុងលំនៅរបស់អ្នកហើយ ខ្ញុំមានសេចក្ដីត្រេកអរក្នុងសំណាក់ នៃអ្នកអស់រាត្រីមួយនេះ អ្នកចូរឲ្យទាន (ដល់សមណព្រាហ្មណ៍) ដែលមានអាជ្ញាដាក់ចុះហើយផង ចូរចិញ្ចឹមមាតាបិតា ដែលចាស់ជរាផង ។

(១០) (ព្រាហ្មណ៍...) លក្ខី (សិរី បុណ្យ ទីពឹងបាន) បានកើតឡើងហើយ ដល់យើងក្នុងថ្ងៃនេះ ព្រោះយើងបានជួបនឹងស្ដេចសេក ដ៏ប្រសើរ ជាងពួកបក្សីទាំងឡាយ យើងនឹងធ្វើបុណ្យឲ្យច្រើន ព្រោះបានស្ដាប់នូវសុភាសិត របស់សេក ។

(១១) សោ កោសិយោ អត្តមនោ ឧទគ្គោ
អន្នញ្ច ចានញ្ចភិសង្ខរិត្វា
អន្នេន ចានេន បសន្នចិត្តោ
សន្តប្បយិ សមណព្រាហ្មណេ ចាតិ ។

សាលិកេទារជាតកំ បឋមំ ។

ចន្ទកិន្នរីជាតកំ

(១២) ឧបនីយតិទំ មញ្ញេ ចន្ទេ លោហិតមទ្ទនេ[១]
អជ្ជ ជហាមិ[២] ជីវិតំ បាណា មេ ចន្ទេ និរុជ្ឈន្តិ ។
ឱសីទិ[៣] មេ ទុក្ខំ ហទយំ មេ ឌយ្ហតេ និតម្មាមិ
តវ ចន្ទិយា សោចន្តិយា ន នំ អញ្ញេហិ សោកេហិ ។
តិណមិវ វនមិវ មិលាយាមិ នទី អបរិបុណ្ណាវ[៤] សុស្សាមិ
តវ ចន្ទិយា សោចន្តិយា ន នំ អញ្ញេហិ សោកេហិ ។
វស្សមិវ សរេ បាទេ ឥមានិ អស្សូនិ វត្តរេ មយ្ហំ
តវ ចន្ទិយា សោចន្តិយា ន នំ អញ្ញេហិ សោកេហិ ។

---

១ ម. លោហិតមច្ចុនេ ។ ២ ម. អជ្ជាមិ វិជហាមិ ។ ៣ ម. ឱសីទិ ។ ៤ ម. អបរិបុណ្ណាវ ។

(១១) (អភិសម្ពុទ្ធគាថា) សាលិត្តិយព្រាហ្មណ៍ ជាកោសិយគោត្រនោះ មានចិត្តរីករាយ មានចិត្តខ្ពស់ឯក មានចិត្តជ្រះថ្លា បានតាក់តែងនូវបាយនិងទឹក ហើយញ៉ាំងសមណៈនិងព្រាហ្មណ៍ទាំងឡាយ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

ចប់ សាលិកេទារជាតក ទី ១ ។

ចន្ទកិន្នរីជាតក

(១២) (ចន្ទកិន្នរគាថា) ម្នាលនាងចន្ទា ជីវិតរបស់បងប្រហែលជាជិតដាច់ហើយ ព្រោះហូរចេញដោយឈាម អញនឹងលះបង់នូវជីវិត ក្នុងថ្ងៃនេះឯង ម្នាលនាងចន្ទា ជីវិតរបស់អញនឹងរលត់ ។ ជីវិតរបស់អញជាទុក្ខក្រៀមក្រំហើយ ហ្ឫទ័យរបស់អញក្ដៅណាស់ អញល្វើយពេក ព្រោះហេតុនាងចន្ទា កំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ អញនឹងស្ងួតស្រពោនដូចជាស្មៅ (ដែលគេដាក់លើថ្មក្ដៅ) ដូចជាដើមឈើ (ដែលគេកាត់ផ្ដាច់ឫសហើយ) អញនឹងរីងស្ងួតដូចជាស្ទឹងដែលមានទឹកមិនពេញ ព្រោះនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ ទឹកភ្នែកទាំងឡាយ របស់អញនេះហូរទៅ ដូចជាភ្លៀងដែលធ្លាក់ក្នុងស្រះហូរទៅ ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃឡើយ ។

(១៣) [illegible] រាជបុត្តោ យោ មេ ឥច្ឆិតំ បតិំ វរាកិយា
វិជ្ឈិ វនមូលស្មឹ សោយំ វិទ្ធោ ឆមា សេតិ ។
ឥមំ មយ្ហំ ហទយសោកំ បដិមុញ្ចតុ រាជបុត្ត តវ មាតា
យោ មយ្ហំ ហទយេ សោកោ កិំបុរិសំ អវេក្ខមានាយ ។
ឥមំ មយ្ហំ ហទយសោកំ បដិមុញ្ចតុ រាជបុត្ត តវ ជាយា
យោ មយ្ហំ ហទយេ សោកោ កិំបុរិសំ អវេក្ខមានាយ ។
មា ច បុត្តេ មា ច បតិំ អទ្ទក្ខិ រាជបុត្ត តវ មាតា
យោ កិំបុរិសំ អវធិ អទូសកំ មយ្ហ កាមាហិ[១] ។
មា ច បុត្តេ មា ច បតិំ អទ្ទក្ខិ រាជបុត្ត តវ ជាយា
យោ កិំបុរិសំ អវធិ អទូសកំ មយ្ហ កាមាហិ ។
(១៤) មា ត្វំ ចន្ទេ រោទិ មា សោចិ វនតិមិរមត្តក្ខិ
មម ត្វំ ហេហិសិ ភរិយា រាជកុលេ បូជិតា នារីភិ ។

១ ម. កាមា ។

(១៣) (នាងចន្ទកិន្នរី ពោលគាថាថា) រាជបុត្តណា បាញ់ប្ដីខ្ញុំដែល អញ្ចាំងក្នុងព្រៃព្រឹក្សាហើយ រាជបុត្ត (នោះ) ការក្រក់មែន ប្ដីរបស់ខ្ញុំនោះដែលត្រូវសរបុកហើយ ដេកលើផែនដី ទៀបគល់ឈើ ។ ម្នាលរាជបុត្ត សេចក្ដីសោក ក្នុងហឫទ័យណានៃខ្ញុំ ដែលកំពុងសំ-ឡឹងមើលនូវកិន្នរ សូមមាតារបស់អ្នក បាននូវសេចក្ដីសោកក្នុងហឫ-ទ័យដូចខ្ញុំនេះដែរ ។ ម្នាលរាជបុត្ត សេចក្ដីសោកក្នុងហឫទ័យណារបស់ខ្ញុំ ដែលកំពុងសំឡឹងមើលនូវកិន្នរ សូមប្រពន្ធរបស់អ្នកបាននូវសេចក្ដីសោក ក្នុងហឫទ័យដូចខ្ញុំនេះដែរ ។ ម្នាលរាជបុត្ត បុគ្គលណា បានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ដ ព្រោះការចង់បានខ្ញុំ សូមកុំឲ្យមាតារបស់អ្នក(នោះ)បានឃើញកូនផង សូមកុំឲ្យបានឃើញប្ដីផង ។ ម្នាលរាជបុត្ត អ្នកណាបានសម្លាប់កិន្នរដែលជាសត្វមិនប្រទូស្ដ ព្រោះការចង់បានខ្ញុំ សូមកុំឲ្យប្រពន្ធរបស់អ្នកនោះ បានឃើញកូនផង សូមកុំឲ្យបានឃើញប្ដីផង ។

(១៤) (ព្រះរាជាត្រាស់ថា) ម្នាលនាងចន្ទា នាងមានភ្នែកដូចផ្កាវនតិមិរក្នុងព្រៃ នាងកុំយំ កុំសោកស្ដាយ នាងនឹងបានជាអគ្គ-មហេសីនៃយើង ដែលពួកនារីបូជាក្នុងរាជត្រកូល ។

(១៥) អបិ នូនាហំ មរិស្សំ នាហំ កជពុត្តមា ហេស្សំ

យោ កិំបុរិសំ អវចិ អន្តរេន ឧយ្យំ ជានាហិ ។

(១៦) អបិ កិរតេ អបិ ជីវិតការណេ កិំបុរិស ននុ ហាសតិ

កាលំ សមត្ថុរាកោ ជនា អញ្ញំ តំ ខេត រោទិស្សតិ ។

(១៧) តេ បព្វតា តា[១] ច កន្ទរា តា ច គិរិគុហាយោ

តត្ថ តំ អបស្សន្តី កិំបុរិស កថំ អហំ កស្សំ[២] ។

យេសុ បព្វតេសុ មយំ ឯកតោ អភិរមិម្ហា

តត្ថ តំ អបស្សន្តី កិំបុរិស កថំ អហំ កស្សំ[៣] ។

តេ បណ្ណសន្ថតា រមណីយា វាឡមិគេហិ អនុចិណ្ណា[៤]

តត្ថ តំ អបស្សន្តី កិំបុរិស កថំ អហំ កស្សំ ។

តេ បុប្ផសន្ថតា រមណីយា វាឡមិគេហិ អនុចិណ្ណា

តត្ថ តំ អបស្សន្តី កិំបុរិស កថំ អហំ កស្សំ ។

---

១ ម. តាតិ ច ទិស្សតិ ។ ២ ម. តត្ថេវ តិដ្ឋិ ។ តត្ថ តំ អបស្សន្តី កិំបុរិស កថំ អហំ កស្សំ - ៣ ម. ម. តតិ ភាគា ន ទិស្សតិ ។ ៤ អនុចិណ្ណា អនុចរិតា ទិស្សតិ ។

(១៥) (កិន្នរី...) តែកាលបុត្រ អ្នកណាបានសម្លាប់ខ្ញុំកិន្នរ ដែលជាសត្វ មិនប្រទូស្ត ព្រោះការបរិភោគមាស ខ្ញុំស្លៀកស្លាប់ ខ្ញុំនឹងមិនធ្វើ (ជាប្រពន្ធ) របស់អ្នក(នោះ)ទេ ។

(១៦) (ព្រះរាជា...) ម្នាលនាងកិន្នរី ដែលជាស្រីមានសេចក្តីខ្លាចរអើល ចូរនាងរស់នៅផង នាងជាមេស្រីមាន ពាក់ស្មើកញ្ចាន់ នឹងស្រីក្រណ្ឌាជា ដោយប៉ុន ចូរនាងទៅកាន់ព្រៃហិមវន្តចុះ ព្ពុកស្រីអាចនឹងត្រេក ត្រអាលចំពោះនាង ។

(១៧) (កិន្នរី...) ភ្នំទាំងឡាយនោះផង ប្រហោងភ្នំទាំងឡាយនោះផង គុហាភ្នំទាំងឡាយនោះផង បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ យើងទាំងឡាយ ធ្លាប់ត្រេកត្រអាល ជាមួយគ្នា លើភ្នំទាំងឡាយណា បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នក លើភ្នំទាំងឡាយនោះ តើនឹងធ្វើដូចម្តេច ។ ភ្នំទាំងឡាយនោះដែរ ជាសាលាដែលស្លឹកឈើ គួររីករាយ ដែលពួកម្រឹគសាហាវធ្លាប់ ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ ភ្នំទាំងឡាយនោះ ដែរជាសាលាដែលផ្កាឈើ គួររីករាយ ដែលពួកម្រឹគសាហាវ ធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។

អជ្ជា សវន្តិ ចិត្តសន្ទិយោ កុសុមាភិកិណ្ណសោតាយោ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

នីលានិ ហិមវន្តេ បព្វតស្ស កូដានិ ទស្សនីយានិ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

បីតានិ ហិមវន្តេ បព្វតស្ស កូដានិ ទស្សនីយានិ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

តម្ពានិ ហិមវន្តេ បព្វតស្ស កូដានិ ទស្សនីយានិ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

តុង្គានិ ហិមវន្តេ បព្វតស្ស កូដានិ ទស្សនីយានិ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

សេតានិ ហិមវន្តេ បព្វតស្ស កូដានិ ទស្សនីយានិ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

ចិត្រានិ ហិមវន្តេ បព្វតស្ស កូដានិ ទស្សនីយានិ

តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កាសំ ។

ស្ទឹងលើភ្នំ ទាំងស្ទឹងក្នុងព្រៃទាំងឡាយ មានទឹកដ៏ថ្លាកាលហូរទៅ មានផ្កាឈើអណ្ដែតទៅតាមខ្សែទឹកព្រោងព្រាត បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ខៀវ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌លឿង គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ក្រហម គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានចុងស្រួច គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត ដែលមានពណ៌ស គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត វិចិត្រ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។

យេ ចក្ខុកណ្ណេ បរិតេ ភវន្តាបេ ទិស្វានេ ហោ សញ្ញតេ
ពុទ្ធំ តំ អចលស្មិំ តិដ្ឋិតេ ភវិំ អហំ ធាតុំ ។
ភិក្ខុនិសេ បរិតេ ភវន្តាបេ ទិស្វានេហិ សញ្ញតេ
ពុទ្ធំ តំ អចលស្មិំ តិដ្ឋិតេ ភវិំ អហំ ធាតុំ ។

(១៨) អក្ខាតេ(តាតេ)អយំ ព្រហ្មោ យោ នេ វត្តិ ចិត្តេ វិក្កមោ
អចរេន អតិសិក្ខំ សព្វាកាមស្មិំ បិយការេន ។

(១៩) វិតក្កមនានំ ឥតិ ឧទានំ យោ តុស្សុមាតិ ភណ្ណុ សោភាយោ
តានានុតស្សតាយោ ចិយំ វតា អញ្ញមញ្ញស្សុតិ ។

ចូឡនន្ទិយជាតកំ ទុតិយំ ។

មហាកុក្កុសជាតកំ

[២០] ឥក្កា មិលាចា កុន្តិ ធីរេ
ជនា មម ទានិតំ បត្តយត្តិ
ចិត្តំ សហាយញ្ញា កិលមំ សេចកា

---

* អដ្ឋកថា ព្រះពុទ្ធ ឧទ្ទិសាយ វិស្សជ្ជ ។ ២ ម. ចំណាំ ។

បពិត្រកិន្នរ ខ្ញុំកាលមិនឃើញនូវការលើកឡើងនូវធម៌ដែលពួក
ក្អែកនាំសេពហើយ ជាក្តីជាប់លាប់យកសេចក្តីទាំងឡាយ តើគឺ
ធ្វើដូចម្តេច ។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញនូវការលើកឡើងនូវធម៌
នោះ ដែលពួកក្អែកសេពហើយ ជាក្តីជាប់លាប់យកសេចក្តីទាំង
ឡាយ តើគឺធ្វើដូចម្តេច ។

(១៨) បពិត្រព្រះម្ចាស់ ខ្ញុំសូមថ្វាយបង្គំនូវព្រះបាទទាំងឡាយរបស់
លោក ព្រោះលោកបានគ្រោងថ្មី ដែលខ្ញុំបានស្រឡាញ់ព្រះធ្វើហើយ
ដោយទឹកអម្រឹត ដែលជាទីស្រឡាញ់ដោយវាសនា គួរទីដែល
លោកឲ្យបាន ។

(១៩) សត្វនោះ លើកទាំងឡាយគឺត្រូវទៅកាន់ស្ថានព្រៃ គឺជ
ស្ថិតនៅព្រៃទាំងឡាយ ដែលមានផ្កាឈើនៅណានៅ តាមទៅ
ទឹក ព្រោះក្រោក ទាំងមានឈើផ្សេងៗដុះទៅវិញ លើកទាំងឡាយ
គឺកោលនូវពាក្យជាទីស្រឡាញ់ទៅវិញទៅមក ។

ចប់ ចុល្លនន្ទិយជាតក ទី ១ ។

មហាកុក្កុសជាតក

(២០) (ព្រះឥន្ទ្រត្រាស់ថា) ម្នាលវិសេសណា ពួកអ្នកដទៃ
ពតិតយកដើមទាំងឡាយ គួរតោទទួល ប្រាជ្ញាតឹងស៊ីនូវកូន
ត្រូវរបស់ខ្ញុំ ពួកអ្នកទៅនូវចិត្តផង សំឡាញ់ផង

អាចិក្ខ ញាតិព្យសនំ ធនជានិំ ។

(៦១) ធនេជា ធនជានិំ បវេកសិ បញ្ញោ ច

ទុក្ខសោកជំ សរណំ ទិ ទុរេធម៌

ឋនា ឋម[១] ទានំ ទិ បត្តយន្តិ

សុត្វា ធិឈាតា កវ វេ សុកាយ ។

(៦២) ទត្តិ សមោយញ្ញ កាលេន្តិ បណ្ឌិតា

កាលេ អកាលេ សុខមេសមានា[២]

កាលេ ទេ សេវកា នឹមត្តិ

អរិយោ ហិ អរិយស្ស កាលេ កតំ ។

(៦៣) យំ ហោតិ កត្វា អនុកម្បកោ ច

អរិយស្ស អរិយេន កតំ កយិនំ[៣]

អត្ថានុសិទ្ធី កតំ ហា អនុរូបិ

លទ្ធាម បុត្តេ កយិ ធីវោនេ ។

(៦៤) កាមេ រក្ខាវណ៍ កាលេន្តិ

សកិរេកាចិ ច សត្តសាធិ

១ ជ. ឥ. ទំ ១២ ២. សុខមេសមានា ១៣ ៣. ពាំ ផលំ ១ ៤. កង់ កយិនំ ។

ក្នុងចូរក្រោចខ្លួន ខ្ញុំសេចក្តីវិនាសរបស់ពួកញាតិ ជាញាតិ

(និងលើកដល់ស្ដេចអាក្រក់) ។

(៦១) (រឿងនេះឈ្មោះ គឺទៅក្រោចខ្លួនស្ដេចអាក់) ចាប់ក្រសួងអាក

ព្រះអង្គជា ទំនងជាធំ ជាចក្រព្រាហ្ម៍ ជាដើមនិងជាធំ

ខ្ញុំសូមយកព្រះអង្គជាទីពឹង ផ្ទៃ ពួកអ្នកដទៃ អាក្រក់

ណាស់ ប្រាថ្នានឹងស៊ីកូនខ្លួន ១ របស់ខ្ញុំ សូមព្រះអង្គ

(អង្គារក្រោចប្រាជ្ញ) ខ្ញុំឲ្យបានសេចក្តីសុខ ។

(៦២) (ស្ដេចអាក្រោលថា) បណ្ឌិតទាំងឡាយជាអ្នកស្វែងរកសេចក្តី

សុខ ក្នុងកាលគួរនិងកាលមិនគួរ តែងចងមិត្រនឹងសំឡាញ់

ផង ព្រោះរឿងនេះឈ្មោះ យើងនឹងធ្វើនូវប្រយោជន៍ដល់អ្នក

បាន ព្រោះអរិយជនតែងធ្វើនូវកិច្ចដល់អរិយជន (ជួយ) ។

(៦៣) (រឿង...) អំពើណាដែលអរិយជនជាអ្នកអនុគ្រោះ គប្បីធ្វើ

ដល់អរិយជន អំពើនោះព្រះអង្គបានធ្វើហើយ សូមទ្រង់ក្សា

នូវព្រះអង្គចុះ សូមទ្រង់ កុំខ្លាចក្រោយឡើយ ការដើ

ព្រះអង្គរស់នៅ យើងនឹងនឹងបាននូវកូនទាំងឡាយ (១៨) ។

(៦៤) (ស្ដេចអក . . .) យើងនឹងធ្វើនូវការរក្សានិងការពារ

ការនោះឯង ក្រៅតែពួកយើងនូវសេចក្តី: គឺមិនគង់សូរដែរ

កាមេត្តិ ហោតិ សចេ សមាគ

តាណំ ចជន្តា សមាលេស[១] ឧទ្ធោ ។

(២៤) សុខុមាលំ កាមូបកាសំ អណ្ណវោជាយំ វិហាតូមោ

អក្ខាយ កាយោ ចុត្តេ អនុយុត្តេ អលាភតេ ។

(២៥) ចុតាបិ ហោតិ ចលិតា សកាយុតា

និត្តាចុកម្មាយេ ឋតិដ្ឋហត្ថិ

ចុត្តា ឧមន្តា[២] កតិមាតលោស្មិ

អត្ថំ ចរេថ មម ភរតោ[៣] ។

(២៦) ចរេថ ចរេថ ចក្កតា ច

មិត្តំ សហាយេ កាលេត្តិ ចណ្ឌិតា

កាលេមិ ទេ សេចតា និគមត្ថំ

អរិយោ ហិ អរិយស្ស កាលេតិ កាត្តំ ។

(២៧) អព្ភាសស្សុវេត្តោ តាត ត្វំ និសីទ

ចុត្តា ចិត្ត ចាតំ សក្កច្ចំ

អយំ ចរិស្សាមិ តវេ អត្ថំ

សេចស្ស ចុត្តេ បរិត្តាយមានោ ។

---

១ ម. ចនុ្ធ សមាលេស ។ ម. ចន្ធា សមាលេស ។ ២ មន្តា ចតិ អទ្ធភាសំ
បិស្សុតិ ។ ៣ ម. សិរិធុ ។

ដ្បិតសំឡេងញាតិទាំងឡាយនោះ តែងសាយភាយទៅនិងជួយធ្វើ (កិច្ចការ)
ដល់សំឡេងញាតិនោះ នេះជាធម៌របស់សប្បុរសទាំងឡាយ ។

(២៤) (អភិសម្ពុទ្ធគាថា) ស្ដេចអាគន្តនេះជាសត្វស្ទាបកើតក៏កើតសុខ ចុះ
ធ្វើនូវអំពើដែលទៅឆ្ងាយ ដោយកម្លាំងក្រពើ ដើម្បីប្រយោជន៍ (ដឹង
កាយ) ខ្លួនផ្ទៃទាំងឡាយ ដែលផលជាតិគណ្ឋាលាតម្រេច ។

(២៥) (វិទ្ធ...) បុគ្គលពួកខ្លះឃ្លានចាក (យស ញ្ញាណ) ក៏ធាន
ភ្ញាក់ក្រវាត់ដោយកម្លាំងរបស់ខ្លួនក៏មាន ហើយត្រឡប់តាំងខ្លួនចុះ
ដោយសារសេចក្ដីអនុគ្រោះរបស់ពួកមិត្ត ក្នុងទាំងឡាយរបស់
ខ្ញុំ មានសេចក្ដីត្រៀមក្រោយ ខ្ញុំមក (យកម្ហូប) ជាអតិ (ទីពឹង)
ជាគ្រួសារក្រោលទៅក្នុងទឹក ខ្ញុំនាំប្រព្រឹត្តប្រយោជន៍ដល់ខ្ញុំ ។

(២៦) (អណ្ណវេ...) បណ្ឌិតទាំងឡាយ តែងចងមិត្រនឹងសំឡេងញ
ដោយព្រមព្រៀង ដោយស្រឡាញ់ ដោយខ្លួនឯង ព្រោះ
វិទ្ធ យើងនឹងធ្វើប្រយោជន៍នោះដល់អ្នកចុះ ដ្បិតអរិយជន
តែងធ្វើកិច្ចដល់អរិយជនដូចគ្នា ។

(២៧) (ក្នុងការណ៍...) បពិត្រព្រះតុក អ្នកចូរជាបុគ្គលមានសេច-
ក្ដីក្រៀមក្រាយនិង អង្គុយស្ងៀមចុះ ខ្ញុំនឹងប្រព្រឹត្តប្រយោជន៍
ដល់ព្រះតុក ខ្ញុំនឹងជួយការពារខ្លួនក្នុងវិទ្ធ ហើយប្រព្រឹត្តនូវ
ប្រយោជន៍ដល់ខ្លួនសេណក ។

(២៩) អត្ថា ហិ កាម សកមេវ ចរេក្ខ

ពុទ្ធោ ចិត្តំ ចរេ អត្ថចរិយំ

អបេក្ខំ មំ តំ សុខំ ចរន្តុកាយំ

សេចស្ស ពុទ្ធានំ ច ហោតិយេយ្យំ ។

(៣០) ឯស្ស មនុស្សា មិតក៌សេដ្ឋ

កយន្តិកា សេដ្ឋមុចព្វជន្តិ

ពុទ្ធា មមង្គា កតិមាតគោស្មិំ

ត្វំ ហោសិ កជា ករ មេ សុតាយ ។

(៣១) កាភេមិ តេ សេចក បវត្តមត្ថំ

សយាមិ តេ តំ ឆិសតំ វោយ

កាចំ ហិ វញ្ញំ ចហុ សម្បជានោ

ឋ ភិយមេ អត្ថជនស្ស ក្តុតិយា ។

(២៩) (អត្តាហិ . . .) ម្នាលកូន គេរកមិនរបស់សប្បុរសជាតិ

ឲ្យឃ្លា ក្នុងត្រូវតែប្រព្រឹត្តប្រយោជន៍ ដើម្បីខ្លួន តិតតែង

ហើយ តែក្នុងគុណនេះ មិនគប្បីរៀនរៀនខ្លួនកូនរបស់ខ្លួន

ព្រោះឃើញខ្លួនពេញដែលមានកោយតំ ។

(៣០) (ខ្ទង់...) បរាក្រមព្រះឥន្ទ្រប្រសើរ ដោយសេចក្តីព្យាយាម

… ពួកសត្វចិត្តមនុស្ស ត្រូវដោយប្រសើរ

ហើយ … ប្រសើរ ក្នុងទាំងឡាយ

របស់ខ្ញុំ មានសេចក្តីក្តៅក្រហាយ (ព្រោះហេតុនោះ) ខ្ញុំមក

(យកព្រះឥន្ទ្រ) ជាគតិ ព្រះឥន្ទ្រជាស្តេចរបស់យើង សូមព្រះ

… (ព្រោះប្រសើរ) ខ្ញុំឲ្យបានសេចក្តីសុខ ។

(៣១) (សីតា:...) … យើងនឹងធ្វើនូវប្រយោជន៍

ខ្លួនដល់អ្នក យើងនឹងទៅសម្លាប់ពួកសត្រូវរបស់អ្នក

… ជាអ្នកអាចនឹងសម្លាប់នូវសត្រូវបាន ដឹង

ច្បាស់ (នូវកិច្ចការ…) មិនគប្បីប្រើប្រែ

… ផ្តួលផ្តើក ។

(៣២) មិត្តំ ការយិរាថ សុហទយញ្ច
អយិរញ្ច ការយិរាថ សុខាគមាយ
និវត្ថកោចោវ សរេភិហន្ត្វា
មោទាម បុត្តេហិ សមន្តិភូតា ។

(៣៣) សកមិត្តស្ស[១] កម្មេន សហាយស្សាបលាយិនោ
កូជន្តមុបកូជន្តិ លោមហំសា[២] ហទយង្គមំ ។

(៣៤) មិត្តំ សហាយំ អធិគម្ម បណ្ឌិតោ
សោ ភុញ្ជតិ បុត្តំ បសុំ ធនំ វា
អហញ្ច បុត្តា ច បតី ច មយ្ហំ
មិត្តានុកម្បាយ សមន្តិភូតា ។
រាជវតា សូរវតា ច អត្ថោ
សម្បន្នសខិស្ស ភវន្តិ ហេតេ
សោ មិត្តវា យសវា ឧគ្គតត្តោ
អស្មិញ្ច លោកេ មោទតិ កាមកាមី ។

១ ម. សកំ មិត្តស្ស ។ ២ ម. យ. លោមហំសា ។

(៣២) (ក្ងោកញីនិយាយនឹងក្ងោកឈ្មោលថា) បុគ្គលគួរធ្វើ (នូវ
បុគ្គលណាមួយ) ឲ្យជាមិត្រផង ឲ្យជាសំឡាញ់ផង គួរធ្វើ (នូវ
បុគ្គលណាមួយ) ឲ្យជាចាស់ផង ដើម្បីបាននូវសេចក្ដីសុខ
យើងទាំងពីរនាក់ (កាលគិតដល់បង្កើតទីពឹងសម្រាប់ខ្លួន ដោយ
កំឡាំងពីរនាក់) ហើយនឹងបានឆ្លងភ័យ ក៏ដោយជាមួយ
នឹងកូនទាំងពីរ ដូចជាបុគ្គលដែលពាក់នូវក្រោះពាក់ហើយ
កាលការពារនូវកូនរបស់ទាំងពីរនាក់បានផុតភ័យ ។

(៣៣) កូនខ្លួនទាំងពីរនាក់ (បានធ្វើសម្លេងពីរៗ) គួរឲ្យត្រេកចិត្ត
ហើយនៅស្រែកហៅ (ខ្ញុំ) ដែលកំពុងស្រែកយំ ដោយការសេចក្ដី
ក្លាហាររបស់សីហៈជាមិត្ររបស់ខ្លួន ជាសំឡាញ់ ជាសម្ដេចតាំ ។

(៣៤) បណ្ឌិតបានពឹងពាក់នូវមិត្រ នូវសំឡាញ់ហើយ ទើបបរិភោគនូវ
ព្រោះតែស្រលាញ់មិត្រសំឡាញ់ ខ្ញុំ កូនទាំងពីរ ប្ដីរបស់ខ្ញុំ បាន
ផុតភ័យ ដោយសេចក្ដីអនុគ្រោះរបស់កូនមិត្រ ។ បុគ្គល
មាន មានមិត្រនិងក្បៀកផង (ជាមិត្រហើយ) កាល
ប្រយោជន៍បាន ព្រោះសំឡាញ់ទាំងនុ៎ះ រំងាប់
ខុសរបស់បុគ្គល ដែលបរិបូណ៌ដោយសំឡាញ់ មានមិត្រល្អ
ជាប្រាជ្ញនៅក្នុង បុគ្គលអ្នកមានមិត្រ មានយស មាន
សេចក្ដីខ្ពង់ខ្ពស់នោះ រមែងរីករាយក្នុងលោកនេះ ។

(៣៥) ការស្សិយានំ មិត្តានំ ផលិទេទានំ សេវកា
បស្ស មិត្តានុកម្បាយ សមគ្គម្ហា សញាតកោ
សុវេន ពលវន្តេន យោ មិត្តំ កុរុតេ ធិរោ
បរិសោ សុចិរោ ហោតិ យថាហំ គ្ញាសេនកាតិ ។

មហាសុកជាតកំ តតិយំ ។

ខុទ្ទាលកជាតកំ

(៣៦) ខរាជិនា ជដិលា បង្កទន្តា
ទុម្មក្ខរូបា[១] យេ មន្តំ ជបន្តិ
កច្ចិ នុ តេ មានុសកេ បយោគេ
ឥទំ វិទូ បរិមុត្តា អបាយា ។

(៣៧) បាបានិ កម្មានិ ករេយ្យ រាជ
ពហុស្សុតោ ចេ ន ចរេយ្យ ធម្មំ
សហស្សវេទោបិ ន តំ បដិច្ច
ទុក្ខា បមុច្ចេ ចរណំ អបត្វា ។

---

១ ម. ទុម្មក្ខា ។

(៣៥) បពិត្រខ្ទីងឈ្មោល បុគ្គលសូម្បីក្រឡុក ក៏គួរធ្វើនូវមិត្តធម៌ អ្នកចូរមើលចុះ យើងទាំងឡាយបានព្រមព្រៀងគ្នាជាមួយនឹងញាតិទាំងឡាយ ដោយសេចក្តីអនុគ្រោះរបស់មិត្រ ។ បពិត្រខ្ទីងឈ្មោល បក្សីណាធ្វើនូវមិត្រជាមួយនឹងបុគ្គលក្លៀវក្លា ជាមួយនឹងបុគ្គលមានកំឡាំង បក្សីនោះរមែងបាននូវសេចក្តីសុខយ៉ាងនេះ ដូចខ្ញុំនឹងឯង ។

ចប់ មហាសុកជាតក ទី ៣ ។

ខុទ្ទាលកជាតក

(៣៦) (ព្រះរាជាទ្រង់ត្រាស់ថា) ពួកជនដែលណាជណ្តប់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រឡាក់ដោយមន្ទិល មានក្លៀកមិនបន្តក់ មានរូបកាក្រក់ កំពុងរកយកនូវមន្ត ជនដែលទាំងនោះ បានដឹងនូវការប្រព្រឹត្តិនូវតបៈ និងការស្វាធ្យាយនូវមន្តនេះ ក្នុងសេចក្តីព្យាយាមជារបស់មនុស្ស នឹងបានរួចចាកអបាយដែរឬ ។

(៣៧) (បុរោហិតក្រាបទូលថា) បពិត្រមហារាជ បើបុគ្គលជាពហុស្សូត មិនប្រព្រឹត្តធម៌ គប្បីធ្វើនូវអំពើលាមកទាំងឡាយ បុគ្គលនោះសូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បានសម្រេច នូវចរណៈ (សមាបត្តិប្រាំបី) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ ។

(៣៨) សហស្សវេទោបិ ន តំ បដិច្ច
ទុក្ខា បមុច្ចេ ចរណំ អបត្វា
មញ្ញាមិ វេទា អផលា ភវន្តិ
សសំយមំ ចរណញ្ញេវ សច្ចំ ។

(៣៩) ន ហេវ វេទា អផលា ភវន្តិ
សសំយមំ ចរណញ្ញេវ សច្ចំ
កិត្តិញ្ច បប្បោតិ អធិច្ច វេទេ
សន្តិំ បុណាតិ ចរណេន ទន្តោ ។

(៤០) ភច្ចា មាតា បិតា ពន្ធូ យេន ជាតោ ស្វេវ សោ
ឧទ្ទាលកោ អហំ ភោតោ សោត្ថិយកុលវំសតោ ។

(៤១) កថំ ភោ ព្រាហ្មណោ ហោតិ កថំ ភវតិ កេវលី
កថញ្ច បរិនិព្វានំ ធម្មដ្ឋោ កិន្តិ វុច្ចតិ ។

(៣៨) (ឧទ្ទាលកមាណពពោលថា) បុគ្គលបើសូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សុតនោះ តែមិនទាន់បាន សម្រេចនូវចរណៈ (សមាបត្តិប្រាំបី) ទេ ក៏មិនគប្បីរួចចាកទុក្ខ ឡើយ ខ្ញុំសំគាល់ថាវេទទាំងឡាយជាសភាពឥតផល មានតែ ចរណៈដែលប្រកបដោយការសង្រួម ទើបជាការពិតប្រាកដ ។

(៣៩) (បុរោហិត...) ខ្ញុំមិនមែនពោលថា វេទទាំងឡាយ ជា សភាពឥតផលទេ តែចរណៈដែលប្រកបដោយការសង្រួម ជារបស់ពិតមែន ឯបុគ្គលរៀននូវវេទទាំងឡាយ គ្រាន់តែ បាននូវកិត្តិសព្ទ បុគ្គលទូន្មានខ្លួនដោយចរណៈហើយ ទើប បានដល់នូវការស្ងប់រម្ងាប់ (និព្វាន) ។

(៤០) (ឧទ្ទាលក...) មាតាបិតានឹងផៅពង្ស ត្រូវតែគួរចិញ្ចឹម តាតាកើត អំពីបុគ្គលណា បុគ្គលនោះឯង នៅជាបុគ្គលនោះដដែល តាតា ឈ្មោះឧទ្ទាលកៈ ជាអ្នកនៅក្នុងត្រកូលនៃសោត្ថិយព្រាហ្មណ៍ដ៏ចំរើន ។

(៤១) (បុរោហិត...) ម្នាលអ្នកដ៏ចំរើន បុគ្គលឈ្មោះថា ព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលមានគុណធម៌បរិបូណ៌ តើដោយ ប្រការដូចម្តេច មួយទៀត ការរលត់កិលេសតើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថាអ្នកតាំងនៅក្នុងធម៌ តើដោយប្រការដូចម្តេច ។

(៦២) ចិរំ កាត្វា អគ្គិមាធាយ ព្រាហ្មណោ

អាហោសិត្វា យជំ ចរេស្សតិ យញ្ញំ

សព្វត្ថកោ ព្រាហ្មណោ ហោតិ ខេមី

ធម្មំ ឋិតំ តេន អនាមយីសុ ។

(៦៣) ន សុទ្ធិ សេចនេន អត្ថិ ន បិ កេវលី ព្រាហ្មណោ

ន ចេវ ខន្តិ សោរច្ចំ ន បិ សោ បរិនិព្វុតោ ។

(៦៤) កថំ សោ ព្រាហ្មណោ ហោតិ កថំ ភវតិ កេវលី

កថញ្ច បរិនិព្វានំ ធម្មដ្ឋោ កិន្តិ វុច្ចតិ ។

(៦៥) អខេត្តពន្ធុ អមមោ និរាសោ

និល្លោភបាបោ ភវលោភខីណោ

សព្វត្ថកោ ព្រាហ្មណោ ហោតិ ខេមី

ធម្មំ ឋិតំ តេន អនាមយីសុ ។

(៦២) (ចិរំ កាត្វា...) បុគ្គលកាន់យកនូវភ្លើងហើយ ធ្វើនូវការបំរើមិនឲ្យមានចន្លោះ ឈ្មោះថាព្រាហ្មណ៍ ព្រាហ្មណ៍កាលស្រោចទឹក(អភិសេក)បូជា (នូវយញ្ញ) ហើយលើកនូវសសរយញ្ញ ព្រាហ្មណ៍ធ្វើយ៉ាងនេះ ឈ្មោះថាជាអ្នកមានសេចក្តីក្សេម (ផុតពីឧបទ្រព) ហៅ(ព្រាហ្មណ៍នោះ)ថាជាអ្នកស្ថិតនៅក្នុងធម៌ដោយហេតុនោះ ។

(៦៣) (ន សុទ្ធិ...) សេចក្តីបរិសុទ្ធិក៏មិនមានដោយការស្រោចទឹកទេ បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ អ្នកបរិបូណ៌ដោយគុណធម៌ ខន្តិ សោរច្ចៈ ទាំងបុគ្គលអ្នករលត់ទុក្ខបាននោះ មិនមាន (ដោយការស្រោចទឹកជាដើមទេ) ។

(៦៤) (កថំ សោ...) តែអ្នកដ៏ចំរើន បុគ្គលដែលឈ្មោះថាព្រាហ្មណ៍កើដោយប្រការដូចម្តេច បុគ្គលដែលជាអ្នកមានគុណធម៌បរិបូណ៌កើដោយប្រការដូចម្តេច មួយទៀត ការរលត់កិលេសកើតដោយប្រការដូចម្តេច បុគ្គលដែលគេហៅថាជាអ្នកឋិតនៅក្នុងធម៌កើដូចម្តេច ។

(៦៥) (អខេត្ត...) បុគ្គលមិនមានស្រែចំការ មិនមានផៅពង្ស មិនមានសេចក្តីប្រកាន់ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីលោភដ៏លាមក អស់សេចក្តីជាប់ជំពាក់ក្នុងភព ព្រាហ្មណ៍ធ្វើយ៉ាងនេះ ទើបឈ្មោះថាជាអ្នកដល់នូវសេចក្តីក្សេម (ផុតពីឧបទ្រព) ហៅ (ព្រាហ្មណ៍នោះ) ថាជាអ្នកឋិតនៅក្នុងធម៌ដោយហេតុនោះ ។

(៦៦)ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
សព្វេ សោរតា ទន្តា សព្វេ បរិនិព្វុតា
សព្វេសំ សីតិភូតានំ អត្ថិ សេយ្យោ[១] វា បាបិយោ ។

(៦៧)ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
សព្វេ សោរតា ទន្តា សព្វេ បរិនិព្វុតា
សព្វេសំ សីតិភូតានំ នត្ថិ សេយ្យោ វា បាបិយោ ។

(៦៨)ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
សព្វេ សោរតា ទន្តា សព្វេ បរិនិព្វុតា ។
សព្វេសំ សីតិភូតានំ នត្ថិ សេយ្យោ វា បាបិយោ
[២]បសទ្ធំ ការសិ ព្រហ្មញ្ញំ សោត្ថិយកុលវំសតំ ។

---

១ ម. សេយ្យោ ។ ២ ម. ចត្តំ ។

(៦៦) (ទុត្តិលក...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកចណ្ឌាលនិងជនអ្នកកើតសម្រាម ពួកជនទាំងអស់នោះជាជាអ្នកស្លូតបូត ជាអ្នកទូន្មានឥន្ទ្រិយបានហើយ ពួកជនទាំងអស់នោះជា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរនិងទោសដ៏លាមក មានដល់ជនទាំងអស់ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំ (ដែរឬ) ។

(៦៧) (ខុរភាតិក...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាលនិងជនអ្នកកើតសម្រាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់នោះជា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមកមិនមានដល់ពួកជនទាំងអស់ ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំឡើយ ។

(៦៨) (ទុត្តិលក...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាលនិងជនអ្នកកើតសម្រាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់នោះជាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមក មិនមានដល់ជនទាំងអស់ដែលមានសេចក្តីត្រជាក់ត្រជំឡើយ (កាលបើយ៉ាងនេះ) អ្នកប្រព្រឹត្តខូចកាពនៃខ្លួនជាព្រាហ្មណ៍ គួរឲ្យគេសរសើរ ហើយញ៉ាំងវង្សត្រកូលនៃសោត្ថិយគោត្រ (ឲ្យវិនាស) ។

(៦៩) នានារត្តេហិ វត្ថេហិ   វិហារំ ករោន្តិ ជានិតំ

ន តេសំ ឆាយា វត្ថានំ   សោ រាគោ អនុបជ្ជថ

ឯវមេវ មនុស្សេសុ   យទា សុជ្ឈន្តិ មាណវា

ន តេសំ ជាតិ បុច្ឆន្តិ[១] ធម្មមញ្ញាយ សុព្វតា ។

ខុល្លកជាតកំ ចតុត្ថំ ។

ភិសជាតកំ

(៨០) អស្សំ គវំ រជតំ ជាតរូបំ

ភរិយញ្ច សោ ឥធ លភតំ មនាបំ

បុត្តេហិ ទារេហិ សមង្គិ ហោតុ

ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៨១) មាលញ្ច សោ កាសិកចន្ទនញ្ច[២]

ធារេតុ បុត្តស្ស ពហូ ភវន្តុ

កាមេសុ តិព្វំ ករុតំ អបេក្ខំ

ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

១ ម. ជាតិ បុច្ឆន្តិ ។ ម. ជាតិសុត្តំ ។ ២ ម. កាសិយ ចន្ទនំ ។

(៦៩) (ម្នាលមាណព...) វិហារដែលគេច្រក់ដោយសំពត់ទាំងឡាយ មាន ពណ៌ក្រហមផ្សេងៗ ស្រមោលរបស់សំពត់ទាំងនោះ មិនផ្សេងគ្នា ឡើយ (មានសម្បុរតែមួយបែប) ការជ្រលក់នោះ ក៏មិនផ្សេងគ្នា ដែរ (យ៉ាងណាមិញ) សូម្បីមនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ ពួកមាណពបរិសុទ្ធ (ដោយអរិយមគ្គ) ក្នុងកាលណា ពួកជនមាន វត្តល្អ បានដឹងនូវនិព្វានធម៌ ក៏មិនសាកសួរនូវជាតិរបស់មាណព ទាំងនោះ (ក្នុងកាលនោះ) ឡើយ ។

ចប់ ខុល្លកជាតក ទី ៤ ។

ភិសជាតក

(៨០) (មហាកាញ្ចនតាបសស្បថថា) ម្នាលព្រាហ្មណ៍ បុគ្គលណាលួច ក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបាននូវសេះ ផង គោផង ប្រាក់ផង មាសផង ប្រពន្ធដ៏គាប់ចិត្តក្នុងលោកនេះ ផង ចូរនៅព្រមព្រៀង ដោយកូននឹងប្រពន្ធទាំងឡាយចុះ ។

(៨១) (តាបសទី២ស្បថថា) ម្នាលព្រាហ្មណ៍ បុគ្គលណាលួចក្រអៅ ឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរទ្រទ្រង់នូវផ្កាកម្រង ផង នូវសំពត់ដែលគេនាំមកអំពីដែនកាសីនិងខ្លឹមចន្ទន៍ផង ចូរឲ្យ បុគ្គលនោះមានកូនច្រើនផង ចូរឲ្យ(បុគ្គលនោះ) ធ្វើនូវសេចក្តី អាឡោះអាល័យដ៏ក្រៀវក្រា ក្នុងកាមទាំងឡាយផង ។

(៨២) បហូតធញ្ញោ កសិមា យសស្សី
បុត្តេ គិហី ធនិមា សព្វកាមេ
វយំ អបស្សំ ឃរមាវសាតុ
កិសោធិ តេ ព្រាហ្មណ យោ អហាសិ ។

(៨៣) សោ ខត្តិយោ ហោតុ បសយ្ហការី
ភូមាធិភូមា ពលវា យសស្សី
ស ចាតុរន្តំ មហិមាវសាតុ
កិសោធិ តេ ព្រាហ្មណ យោ អហាសិ ។

(៨៤) សោ ព្រាហ្មណោ ហោតុ អវីតរាគោ
មុហុត្តនក្ខត្តបថេសុ យុត្តោ
បូជេតុ នំ រដ្ឋបតី យសស្សី
កិសោធិ តេ ព្រាហ្មណ យោ អហាសិ ។

(៨៥) អជ្ឈាយកំ សព្វសមន្តវេទំ[១]
តបស្សិនំ មញ្ញតុ សព្វលោកោ
បូជេន្តុ[២] នំ ជានបទា សមេច្ច
កិសោធិ តេ ព្រាហ្មណ យោ អហាសិ ។

១ ម. សព្វសមន្តវេទិំ ។ ២ ម. ឱ. បូជេន្តុ ។

(៨២) (តាបសទី ៣ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូករបស់លោក (បុគ្គលនោះ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស (បាន) នូវកូនទាំងឡាយ ជាគ្រហស្ថ មានទ្រព្យ ចូរ(បាន) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ (របស់ខ្លួន) នៅគ្រប់គ្រងផ្ទះចុះ ។

(៨៣) (តាបស ទី ៤ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជាភូមាធិបតី មានពល មានយស ចូរបានគ្រប់គ្រងផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុតចុះ ។

(៨៤) (តាបសទី ៥ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរជាព្រាហ្មណ៍មិនប្រាសចាករាគៈ ចូរប្រកបក្នុងគន្លងឫក្សពេលនិងនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន (ស្ដេច) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ ។

(៨៥) (តាបសទី ៦ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក លោកទាំងអស់ ចូរសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកស្វាធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមានតបៈ ពួកអ្នកជនបទ ចូរប្រជុំហើយបូជានូវបុគ្គលនោះចុះ ។

(៤៦) ចតុស្សទំ គាមវរំ សមិទ្ធំ
ទិន្នញ្ហិ សោ ភុញ្ជតុ វាសវេន
អវីតរាគោ មរណំ ឧបេតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៧) សោ គាមណី ហោតុ សហាយមជ្ឈេ
នច្ចេហិ គីតេហិ បមោទមានោ
មា រាជតោ ព្យសនមលត្ថ កិញ្ចិ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៨) យំ ឯករាជា បថវី វិជិត្វា
ឥត្ថីសហស្សាន ឋបេតុ អគ្គំ
សីមន្តិនីនំ បវរា ភវាតុ
ភិសានិ តេ ព្រាហ្មណ យា អហាសិ ។

(៤៩) ឥសីនំ(១) ហិ សា សព្វសមាគតានំ
ភុញ្ជេយ្យ សាទុំ អវិកម្បមានា
ចរាតុ លាភេន វិកត្ថមានា
ភិសានិ តេ ព្រាហ្មណ យា អហាសិ ។

១ ម. ឥសីនំ ។

(៤៦) (តាបសជាសំឡាញ់ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបរិភោគនូវស្រុកសួយដ៏សម្បូរ ដែលព្រះរាជាឲ្យ(១)ហើយ ហាក់ដូចស្ដេចវាសវៈប្រគានឲ្យ ចូរដល់នូវមរណៈ ទាំងមិនទាន់បានប្រាសចាករាគៈចុះ ។

(៤៧) (តាបសជាខ្ញុំប្រុសស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបានជាធំក្នុងស្រុក ចូររីករាយដោយការរាំ និងច្រៀងក្នុងកណ្ដាលនៃសំឡាញ់ កុំឲ្យបាននូវសេចក្ដីវិនាសតិចតួចអំពីស្ដេចឡើយ ។

(៤៨) (នាងកញ្ញាទេវីស្បថថា) បពិត្រព្រាហ្មណ៍ ស្រីណាលួចក្រអៅឈូកទាំងឡាយរបស់លោក សូមឲ្យស្ដេចឯករាជដែលទ្រង់ឈ្នះនូវផែនដីលើកតំកើង(ស្រីនោះ)ឲ្យប្រសើរលើសជាងស្រីទាំងមួយពាន់ សូមឲ្យ(ស្រីនោះ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ ។

(៤៩) (នាងទាសីស្បថថា) បពិត្រព្រាហ្មណ៍ ទាសីណាលួចក្រអៅឈូកទាំងឡាយរបស់លោក កំពុងណាទាសីទាំងឡាយ ទាសីនោះចូរកុំញាប់ញ័រ (ក្នុងកណ្ដាល) នៃពួកឥសីទាំងឡាយដែលប្រជុំគ្នាទាំងអស់ ចូរបរិភោគនូវវត្ថុមានរសឆ្ងាញ់ (ទាសីនោះ) ចូរប្រព្រឹត្តនិយាយកុហក ព្រោះហេតុតែលាភចុះ ។

១- ស្រុកសម្បូរដោយ មនុស្ស ១ ស្រូវ ១ ឧស ១ ទឹក ១ ។ អដ្ឋកថា ។

(៦០) អាវាសិកោ ហោតុ មហាវិហារេ
នវកម្មិកោ ហោតុ កជង្គលាយំ
អាលោកសន្ធិំ ទិវសា(១) ករោតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៦១) សោ ពជ្ឈតុ បាសសតេហិ ឆហិ
រម្មា វនា និយ្យតុ រាជធានី
តុត្តេហិ សោ ហញ្ញតុ បាចនេហិ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៦២) អលក្ខមាលី តិបុកណ្ណវិទ្ធោ
លដ្ឋិហតោ សប្បមុខំ ឧបេតុ
សកច្ឆពន្ធោ(២) វិសិខំ ចរាតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៦៣) យោ វេ អនដ្ឋំ នដ្ឋន្តិ ចាហ
កាមេវ សោ លភតុ ភុញ្ជតុ ច
អគារមជ្ឈេ មរណំ ឧបេតុ
យោ វា ភោន្តោ សង្កតិ កញ្ចិទេវ ។

១. ឧ. អាលោកសន្ធិំ ទិវសំ ។ ២ ម. សក្កច្ច ពន្ធោ ។ ឱ. សក្ខពន្ធោ ។

(៦០) (ទេវកាស្សបថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក (បុគ្គលនោះ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរធ្វើនូវនវកម្ម ក្នុងនគរឈ្មោះកជង្គលៈចុះ ចូរធ្វើនូវបង្អួចឲ្យហើយរាល់ៗថ្ងៃចុះ ។

(៦១) (អ៊ីរស្សបថា) បពិត្រព្រាហ្មណ៍ អ៊ីរណាលួចក្រអៅឈូកទាំងឡាយរបស់លោក អ៊ីរនោះ ចូរជាប់ចំណងអន្ទាក់ច្រើនក្រសឹកវ៉ូនទាំង៦ (គឺជាប់ទាំង៦ គន់ចង្កៀ) ចូរឲ្យគេនាំអំពីព្រៃ ដ៏រីករាយទៅកាន់រាជធានីចុះ អ៊ីរនោះចូរឲ្យគេវាយដោយកន្ត្រៃទាំងឡាយ ដែលមានផលដែកមានបន្លាក៏ចុះ ។

(៦២) (ស្វាស្សបថា) បពិត្រព្រាហ្មណ៍ ស្វាណាលួចក្រអៅឈូកទាំងឡាយរបស់លោក (ស្វានោះ) ចូរមានប្រមាត់ឡៀក ហើយគេចោះត្រចៀកបំពាក់សំណាចុះ ឲ្យហ្លួងសេកយាដោយកាត់ ហើយចូរទៅរកពស់ចុះ ឲ្យគេចងដោយដីម៉ា ហើយដើរទៅកាន់ច្រកល្ហកចុះ ។

(៦៣) (ព្រះមហាសត្វស្សបថា) ម្នាលអ្នកដ៏ចំរើនទាំងឡាយ បុគ្គលណា ពោលនូវវត្ថុណាដែលមិនបាត់ថាបាត់ ម្យ៉ាងទៀត បុគ្គលណារង្កៀសចំពោះនរណាមួយ (ចំពោះអ្នកទាំងឡាយ) បុគ្គលនោះ ចូរបាន ដ៏ឥតនូវបរិភោគនូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្ដាលផ្ទះចុះ ។

(៦៤) យមេសមានា វិចរន្តិ លោកេ
ឥដ្ឋញ្ច កន្តញ្ច ពហូនមេតំ
បិយំ មនុញ្ញំ ចិរធ ជីវលោកេ
កស្មា ឥសយោ នប្បសំសន្តិ កាមេ ។

(៦៥) កាមេសុ វេ ហញ្ញរេ ពជ្ឈរេ ច
កាមេសុ ទុក្ខញ្ច ភយញ្ច ជាតំ
កាមេសុ ភូតាធិបតី បមត្តា
បាបានិ កម្មានិ ករោន្តិ មោហា ។
តេ បាបធម្មា បសវេត្វ បាបំ
កាយស្ស ភេទា និរយំ វជន្តិ
អាទីនវំ កាមគុណេសុ ទិស្វា
តស្មា ឥសយោ នប្បសំសន្តិ កាមេ ។

(៦៦) វីមំសមានោ ឥសិនោ ភិសានិ
តីរេ គហេត្វាន ថលេ និធេសឹ
សុទ្ធា អបាបា ឥសយោ វសន្តិ
ឯតានិ តេ ព្រហ្មចារី ភិសានិ ។

(៦៤) (សក្កទេវរាជត្រាស់ថា) (សត្វទាំងឡាយ) រមែងស្វែងរកនូវវត្ថុកាមទាំងកិលេសកាមណា ហើយត្រាច់ទៅក្នុងលោក តែកាមទាំងកិលេសកាមនុ៎ះ ជាទីប្រាថ្នាផង ជាទីត្រេកអរផង ជាទីស្រឡាញ់ផង ជាទីពេញចិត្តរបស់ទេវតានិងមនុស្សច្រើនគ្នាក្នុងជីវលោកនេះ ចុះហេតុអ្វីក៏ពួកឥសីមិនសរសើរនូវកាមទាំងឡាយ ។

(៦៥) (មហាសត្វពោលថា) ជនទាំងឡាយ ត្រូវគេវាយ ត្រូវគេចង ព្រោះតែកាមទាំងឡាយ សេចក្តីទុក្ខផង ភ័យផង ដែលកើតឡើងក៏ព្រោះតែកាមទាំងឡាយ បពិត្រព្រះភូតាធិបតី សត្វទាំងឡាយស្រវឹង ព្រោះកាមទាំងឡាយ ធ្វើនូវអំពើទាំងឡាយដ៏លាមក ព្រោះវង្វេង ។ ជនមានធម៌ដ៏លាមកទាំងឡាយនោះ ទទួលនូវបាប លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ព្រោះហេតុនោះ បានជាពួកឥសីមិនសរសើរនូវកាមទាំងឡាយ ព្រោះឃើញទោស ក្នុងកាមគុណទាំងឡាយ ។

(៦៦) (សក្ក...) ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសីក្បែរឆ្នេរទៅកប់ទុកលើគោក (ឥឡូវនេះ ខ្ញុំជឿហើយថា) ឥសីទាំងឡាយ ជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោកជាព្រហ្មចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក ។

(៦៧) ន តេ នដា នោ បន កីឡនេយ្យា
ន ពន្ធវា នោ បន តេ សហាយា
កិស្មឹ វត្ថុម្ហិ[១] សហស្សនេត្ត
ឥសីហិ តុវំ កីឡសិ ទេវរាជ ។

(៦៨) អាចរិយោ មេសិ បិតា ច មយ្ហំ
ឯសា បតិដ្ឋា ខលិតស្ស ព្រហ្មេ
ឯកាបរាធំ ខម ភូរិបញ្ញ
ន បណ្ឌិតា កោធពលា ភវន្តិ ។

(៦៩) សុកុសលី ឥសិនំ ឯករត្តំ
យំ វាសវំ ភូតបតិទ្ទសាម
សព្វេវ ភោន្តោ សុមនា ភវន្តុ
យំ ព្រាហ្មណោ បច្ចុទាទិ ភិសានិ ។

(៧០) អហញ្ច សារីបុត្តោ ច មោគ្គល្លានោ ច កស្សបោ
អនុរុទ្ធោ បុណ្ណានន្ទោ តទាសុំ សត្ត ភាតរោ ។

១ ម. បវត្ថុ ។ ឧ. វត្ថុ ។

(៦៧) (មហាសត្វ...) ម្នាលទេវរាជ ជាសហស្សនេត្ត (ពួកយើង) មិនមែនជាអ្នករបាំរបស់អ្នកទេ ពាំងមិនមែនជាបុគ្គលគួរអ្នកលេងទេ មិនមែនជាផៅពង្ស ពាំងមិនមែនជាសំឡាញ់របស់អ្នកទេ ហេតុអ្វីក៏អ្នក (ធ្វើ) នូវសេចក្តីមើលងាយចំពោះបុគ្គលនោះ ហើយលេងជាមួយនឹងពួកឥសី ។

(៦៨) (សក្ក...) បពិត្រព្រាហ្មណ៍ប្រសើរ លោកម្ចាស់ជាអាចារ្យរបស់ខ្ញុំផង ជាបិតារបស់ខ្ញុំផង ម្លប់ព្រះបាទរបស់លោកម្ចាស់នេះសូមជាទីពឹង (របស់ខ្ញុំ) ដែលមានសេចក្តីភ្លាំងភ្លាត់ហើយ បពិត្រព្រាហ្មណ៍ មានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់ទោសនូវកំហុសមួយ បណ្ឌិតទាំងឡាយ មិនមានសេចក្តីក្រោធជាកំឡាំងទេ ។

(៦៩) (មហាសត្វ...) ការដែលពួកឥសី(នៅកន្លែង) សម្រាកមួយយប់ក៏ឈ្មោះថាបាននៅល្អហើយ ព្រោះថាយើងទាំងឡាយ បានឃើញនូវព្រះឥន្ទ្រជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចំរើនទាំងអស់គ្នា ចូរមានចិត្តរីករាយចុះ ព្រោះព្រាហ្មណ៍ (ជាអាចារ្យរបស់អ្នកទាំងឡាយ) បាននូវក្រអៅឈូកវិញហើយ ។

(៧០) (អភិសម្ពុទ្ធគាថា) បងប្អូនប្រាំពីរនាក់ក្នុងកាលនោះ គឺ តថាគត ១ សារីបុត្ត ១ មោគ្គល្លាន ១ កស្សប ១ អនុរុទ្ធ ១ បុណ្ណ ១ អានន្ទ ១ ។

ភគិនី ឧប្បលវណ្ណា ទាសី ខុជ្ជុត្តរា តទា
ចិត្តោ គហបតិ ទាសោ យក្ខោ សាតាគិរោ តទា
បាលិលេយ្យោ តទា នាគោ មធុទោ សេដ្ឋវានរោ
កាឡុទាយី តទា សក្កោ ឯវំ ធារេថ ជាតកន្តិ ។

ភិសជាតកំ ចតុត្ថំ ។

សុរុចិជាតកំ

(៧១) មហេសី រុចិនោ ភរិយា អានីតា បឋមំ អហំ
ទស វស្សសហស្សានិ យំ មំ សុរុចិ អានយិ[១] ។
សាហំ ព្រាហ្មណ រាជានំ វេទេហំ មិថិលគ្គហំ
នាភិជានាមិ កាយេន វាចាយ ឧទ ចេតសា
សុរុចឹ អតិមញ្ញិត្ថ អាវិ វា យទិ វា រហោ ។
ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ ឥសេ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។
(៧២) ភត្តុ មមាតា សស្សុ បិយា មាតា បិតា ច សស្សុរោ[២]

១ ឱ. ម. សុរុចិមានយិ ។ ២ ឱ. ភត្តុ មមស្សុ ចិតា មាតា ចាបិ សស្សុរោ ។ ម. ភត្តុ មម សស្សូ មាតា បិតា ចាបិ សស្សុរោ ។

ប្អូនស្រីក្នុងកាលនោះ គឺនាងឧប្បលវណ្ណា ទាសីគឺនាងខុជ្ជុត្តរា ក្នុងកាលនោះ ខ្ញុំប្រុសគឺគហបតីឈ្មោះចិត្តៈ ទេវតា គឺសាតាគិរយក្ខ ។ ក្នុងកាលនោះ ដំរីប្រសើរ គឺដំរីឈ្មោះបាលិលេយ្យ ស្វាប្រសើរ គឺមធុទៈ ក្នុងកាលនោះ ទេវេន្ទ ឈ្មោះសក្កៈ គឺកាឡុទាយី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ភិសជាតក ទី ៤ ។

សុរុចិជាតក

(៧១) (នាងសុមេធាទេវី ពោលថា) ខ្ញុំជាមហេសីភរិយារបស់ព្រះបាទសុរុចិ ដែលព្រះអង្គទ្រង់នាំមកមុនដំបូង ព្រះបាទសុរុចិនាំខ្ញុំមកអស់មួយម៉ឺនឆ្នាំហើយ ។ បពិត្រព្រាហ្មណ៍ ខ្ញុំនោះមិនដែលដឹងថា ខ្ញុំបានមើលងាយព្រះរាជាសុរុចិជាធំក្នុងដែនវិទេហៈ ព្រះអង្គគ្រប់គ្រងនូវក្រុងមិថិលា ដោយកាយ ដោយវាចា ឬដោយចិត្ត ក្នុងទីកំបាំង ក្នុងទីចំពោះមុខឡើយ ។ បពិត្រឥសី សូមឲ្យបុត្រកើត (ក្នុងផ្ទៃរបស់ខ្ញុំ) ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧២) ព្រះភស្តាផង ព្រះមាតាក្មេកផង ព្រះបិតាក្មេកផង ព្រះមាតាបង្កើតនិងបិតាបង្កើតផង ជាទីគាប់ចិត្ត ជាទីស្រឡាញ់ (របស់ខ្ញុំ)

តេ មំ ព្រហ្មេ វិជានាហិ យាវ អដ្ឋស្ស ជីវិតំ ។
សាហំ អហឹសារតិនី កាមេសា ធម្មចារិនី
សត្តក្ខត្តុំ តេ ឧបដ្ឋាសិ រត្តិន្ទិវមតន្ទិតា ។
ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ តវ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។

(៩៣) សោឡសិត្ថីសហស្សានំ សហភរិយានំ ព្រាហ្មណ
តាសុ ឥស្សា វា កោធោ វា នាហុ មយ្ហំ កុទាចនំ ។
ហិតេន តាសំ នន្ទាមិ ន ច មេ កាចិ អប្បិយា
អត្តានំវានុកម្បាមិ សទា សព្វា សបត្តិយោ ។
ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ តវ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។

(៩៤) ទាសេ កម្មករេ ទោសេ យេ ចញ្ញេ អនុជីវិតា
បោសេមិ សហធម្មេន សទា បមុទិតិន្ទ្រិយា ។

បពិត្រព្រាហ្មណ៍ ព្រះបិតាក្មេកនិងព្រះមាតាក្មេកទាំងពីរនោះ រស់នៅដរាបណា ក៏ខ្ញុំនៅដរាបនោះ ។ ខ្ញុំនោះជាស្រីប្រកបដោយសេចក្ដី មិនត្រេកអរនឹងការមិនបៀតបៀន ជាអ្នកប្រព្រឹត្តធម៌ ដោយពិតប្រាកដ មិនខ្ជិលច្រអូស បានចិញ្ចឹមព្រះមាតាក្មេកនិងព្រះបិតាក្មេកនោះដោយសេចក្ដីគោរព ទាំងយប់ទាំងថ្ងៃ ។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៩៣) បពិត្រព្រាហ្មណ៍ ខ្ញុំមិនមានសេចក្ដីប្រច័ណ្ឌ ឬសេចក្ដីក្រោធចំពោះពួកស្ត្រីទាំងមួយមុឺនប្រាំមួយពាន់ ដែលជាភរិយាជាមួយគ្នាក្នុងកាលណាមួយឡើយ ។ ខ្ញុំត្រេកអរ ចំពោះស្ត្រីទាំងនោះ ដោយប្រយោជន៍ ស្រីណាមួយ មិនជាទីស្រឡាញ់របស់ខ្ញុំនោះមានឡើយ ខ្ញុំអនុគ្រោះពួកស្ត្រីរួមប្ដីទាំងអស់ សព្វ ៗ កាលដូចជាខ្លួនឯង ។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៩៤) ខ្ញុំមានឥន្ទ្រិយស្រស់ស្រាយសព្វកាល បានចិញ្ចឹមនូវទាសៈទាំងឡាយផង កម្មករទាំងឡាយផង បុគ្គលដែលត្រូវចិញ្ចឹមទាំងឡាយផង ពួកជនដទៃដែលរស់នៅដោយអាស្រ័យផង តាមសមគួរដល់ហេតុ

ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ ឥសេ

មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។

(៧៥) សមណេ ព្រាហ្មណេ ចាបិ អញ្ញេ ចាបិ វនិព្វកេ

តប្បេមិ អន្នបានេន សទា បយតបាណិនី ។

ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ ឥសេ

មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។

(៧៦) ចាតុទ្ទសី បញ្ចទសី យា ច បក្ខស្ស អដ្ឋមី

បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ

ឧបោសថំ ឧបវសាមិ[1] សទា សីលេសុ សំវុតា ។

ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ ឥសេ

មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។

(៧៧) សព្វេវ តេ ធម្មគុណា រាជបុត្តិ យសស្សិនិ

សំវិជ្ជន្តិ តយិ ភទ្ទេ យេ ត្វំ កិត្តេសិ អត្តនិ ។

---

១ ឧ. ឧបវសិំ ។

បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧៥) ខ្ញុំមានចិត្តរាបទាបហើយ បានផ្គត់ផ្គង់នូវពួកសមណៈផង នូវពួកព្រាហ្មណ៍ផង នូវពួកវណិព្វកៈដទៃផង ដោយបាយនិងទឹកសព្វកាល ។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧៦) ខ្ញុំជាស្ត្រីសង្រួមក្នុងសីលទាំងឡាយសព្វកាល បានរក្សានូវឧបោសថ ប្រកបដោយអង្គទាំង ៨ អស់ថ្ងៃទី ១៤ ផង អស់ថ្ងៃទី ១៥ ផង អស់ថ្ងៃទី ៨ នៃបក្សផង អស់បាដិហារិយបក្សផង ។ បពិត្រឥសី សូមឲ្យបុត្រ កើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧៧) (សក្កទេវរាជពោលថា) ម្នាលនាងរាជបុត្រី មានយសដ៏ចំរើន នាងបានពោលនូវធម្មគុណទាំងឡាយណា (ដែលមាន) ក្នុងខ្លួន ធម្មគុណទាំងនោះទាំងអស់ មានចំពោះនាងដ៏ចំរើនហើយ ។

ខត្តិយោ ជាតិសម្បន្នោ អភិជាតោ យសស្សិមា
ធម្មរាជា វិទេហានំ បុត្តោ ឧប្បជ្ជតេ តវ ។

(៥៤) ទុម្មិ[១] រជោជល្លធរេ អឃេ វេហាយសណ្ឋិតោ
មនុញ្ញំ ភាសសេ វាចំ យំ មយ្ហំ ហទយង្គមំ ។
ទេវតា នុសិ សគ្គម្ហា ឥសី វាសិ មហិទ្ធិកោ
កោ វាសិ ត្វំ អនុប្បត្តោ អត្តានំ មេ បវេទយ ។

(៥៥) យំ ទេវសង្ឃា វន្ទន្តិ សុធម្មាយ សមាគតា
សោហំ សក្កោ សហស្សក្ខោ អាគតោស្មិ តវន្តិកេ ។
ឥត្ថិយោ ជីវលោកស្មឹ យា ហោន្តិ សមចារិនី
មេធាវិនី សីលវតី សស្សុទេវា បតិព្វតា ។
តាទិសាយ សុមេធាយ សុចិកម្មាយ នារិយា
ទេវា ទស្សនមាយន្តិ មានុសិយា អមានុសា ។
ត្វញ្ច ភទ្ទេ សុចិណ្ណេន បុព្វេ សុចរិតេន ច
ឥធ រាជកុលេ ជាតា សព្វកាមសមិទ្ធិនី ។

១. [illegible]

ព្រះរាជបុត្រជាក្សត្របរិបូណ៌ដោយជាតិ កើតបរិសុទ្ធអំពីចំណែកទាំងពីរ មានយស ជាស្ដេចប្រកបដោយធម៌ របស់ជនទាំងឡាយអ្នកនៅក្នុងដែនវិទេហៈ នឹងកើតដល់នាង ។

(៥៤) (នាងសុមេធាទៅ...) អ្នកមានក្នុងក្ដីផ្សា ប្រេចនឹងនៅលំអង ឋិតនៅលើអាកាសខាង ពោលពាក្យជាទីពេញចិត្ត ដែលជាកំពូលនៅក្នុងហឫទ័យរបស់ខ្ញុំ ។ ចុះអ្នកជាទេវតា ទើបចេញមកអំពីឋានសួគ៌ ឬជាឥសីអ្នកមានឫទ្ធិច្រើន មួយទៀត អ្នកជាអ្វី បានមកដល់ (ក្នុងទីនេះ) ចូរអ្នកប្រកាសខ្លួនឲ្យជាក់ដល់ខ្ញុំ ។

(៥៥) (សក្កទេវរាជ...) ពួកទេវតាប្រជុំគ្នាក្នុងរោងឈ្មោះសុធម្មាហើយ ថ្វាយបង្គំនូវខ្ញុំណា ខ្ញុំនោះឈ្មោះសក្កៈ ជាអ្នកឃើញនូវហេតុមួយពាន់(ដោយមួយរំពេច)បានមកក្នុងសំណាក់នាង ។ ស្ត្រីទាំងឡាយណា ក្នុងជីវលោក ដែលជាអ្នកប្រព្រឹត្តស្មើ មានប្រាជ្ញា មានសីល ទុកម្ដាយក្មេកដូចជាទេវតា មានវត្តចំពោះប្ដី ។ ទេវតាទាំងឡាយមិនមែនជាមនុស្ស មកជួបនឹងនាងនារី ជាមនុស្សដែលមានបញ្ញាល្អ មានការងារដ៏ស្អាត ប្រាកដស្មើដោយស្ត្រីទាំងនោះ ។ ម្នាលនាងដ៏ចំរើន នាងបានមកកើតក្នុងត្រកូលនេះ ជាស្ត្រីកាចសម្រេចនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ដោយសារតែសុចរិត ដែលនាងបានសាងសន្សំមកក្នុងកាលមុន ។

អយញ្ច តេ គជយុត្តំ ឧគយុត្តំ ការជក្កហោ

ទោសលោភបច្ចត្តិ ច កាមំ ច អជ ជីវិតេ ។

ចិរំ សុខេន សុទិដ្ឋំ ឧម្មុគ្គិ ចាលយ

បសាទំ តិធិរំ យាមិ ចយំ ទេ តវ ឧស្សុក្កំ ។

សត្តិគុម្ពជាតកំ ឆដ្ឋំ ។

បញ្ចុបោសថិកជាតកំ

(៨០) អប្បោស្សុក្កោ ទានិ តុវំ កបោត

វិហង្គម ន តវ ភោជនត្ថោ

ខុទ្ទំ បិបាសំ អធិវាសយន្តោ

កស្មា ភវំ ឧបោសថិកោ[1] កបោត ។

(៨១) អហំ បុរេ គិទ្ធិគតោ[2] កបោតិយា

អស្មឹ បទេសស្មឹ ឧភោ រមាម

អថគ្គហី សាកុណិកោ កបោតឹ

អកាមកោ តាយ វិនា អហោសឹ ។

---

១ អដ្ឋកថាសីហឡបោត្ថកេ ឧបោសថិកោ ។ ២ សី. គិទ្ធិគតោ ។

ម្នាលនាគរាជបុត្រ យើងនឹងធ្វើកិរិយាកាន់យកនូវផ្លែឈើនោះ ក្នុង

លោកទាំងពីរ នឹងកិរិយាកើតក្នុងទេវលោក ។ កើតឈ្មោះក្នុងជីវិតនេះ

១ ។ ម្នាលនាគរាជ សូមឲ្យនាគមានសេចក្តីសុខសប្បាយ

នាគនូវរក្សានូវអាត្មាក្នុងខ្លួនចុះ យើងនឹងទៅកាន់ហិមពាន្តវិញ

ការបានជួបនឹងនាគ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ។

ចប់ សត្តិគុម្ពជាតក ទី ៦ ។

បញ្ចុបោសថិកជាតក

(៨០) (តាបសពោលថា) ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្តី

ខ្វល់ខ្វាយតិច ម្នាលបក្សី អ្នកមិនមានសេចក្តីត្រូវការដោយ

ចំណីអាហារ ម្នាលព្រាប អ្នកទ្រាំអត់នូវសេចក្តីឃ្លាននឹងស្រេក

ជាសត្វរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(៨១) (ព្រាបពោលថា) ក្នុងកាលមុន ខ្ញុំមានចិត្តជាប់ជំពាក់នឹងមេ

ព្រាប យើងទាំងពីរនាក់ក៏ត្រេកអរ (ក្នុងកាល) ក្នុង

ប្រទេសនោះ គ្រានោះសត្វស្លាប មកចាប់យកមេព្រាប

ទៅ ខ្ញុំក៏អស់សេចក្តីប្រាថ្នា ព្រោះព្រាត់ចាកមេព្រាបនោះ ។

នានាភាវា វិប្បយោគេន តស្សា

មនោមយំ វេទនំ វេទយាមិ

តស្មា អហុបោសថំ បាលយាមិ

រាគោ មមំ មា បុនរាគមាសិ ។

(៨៦) អនុជ្ជុគាមិ ឧរគ ទុជិវ្ហ

ទាឋាវុធា ឃោរវិសោសិ សប្ប

ខុទ្ទំ បិបាសំ អធិវាសយន្តោ

កស្មា តុវំ បោសថិកោ នុ ទីឃ ។

(៨៧) ឧសភោ អហុ ពលវា គាមិកស្ស

ចលក្កកូ(១) វណ្ណពលូបបន្នោ

សោ មំ អក្កមិ តំ កុបិតោ អឌំសិ

ទុក្ខាភិតុន្នោ មរណំ ឧបាគា ។

តតោ ជនា និក្ខមិត្វាន គាមា

កន្ទិត្វា រោទិត្វា អបក្កមឹសុ

តស្មា អហុបោសថំ បាលយាមិ

កោធោ មមំ មា បុនរាគមាសិ ។

(១) ចលក្កកូតិ អដ្ឋកថាយំ ទិស្សតិ ។ យុត្តតរំ ។ សេសាយ-
[illegible] ចលក្កកូតិ [illegible] ទិស្សតិ ។

ខ្ញុំដឹងនូវវេទនាកើតក្នុងចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

(៨៦) (តាបស...) ម្នាលពស់ ជាសត្វមានគតិលូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ក្លៀវក្លា ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំនូវឃ្លាននឹងស្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(៨៧) (ពស់...) គោឈ្មោលរបស់អ្នកស្រុក ជាគោមានកំលាំង មានបូកញ័រយោរ ប្រកបដោយសម្បុរនឹងកំលាំង គោនោះដើរជាន់ខ្ញុំ ខ្ញុំខឹង បានចឹកវា ។ គោនោះត្រូវសេចក្ដីទុក្ខគ្របសង្កត់ហើយក៏ស្លាប់ទៅ ។ លំដាប់នោះ ពួកជនចេញអំពីស្រុក កន្ទក់កន្ទេញ យំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្ដីក្រោធ គ្របសង្កត់ខ្ញុំបានទៀតឡើយ ។

(៨៥) មតាន មំសានិ ពហុ សុសានេ
ពនុញ្ញាកំ តវ គោជនេសិ
ទុដ្ឋី ចីតាសំ អនិកស យាន្តា
តស្មា អកាតាសជិតោ សិគាល ។

(៨៦) បរិស្ស កុដ្ឋិ មហាតោ តជស្ស
តុណាបេ តោ ជាតុវិសេសុ តត្ថា
នុណ្ណោ ច ភតោ តិទិណោ ច វស្សិយោ
តេ សោសយិ តស្ស តាវីសមត្តំ ។
តាសោ ច បណ្ណា ច អហំ កដេត្វា
ចរេ អហុ ចិត្តមហាយ មេត្តា
មហា ច មេឃោ សហសា បវស្សិ
សោ ទេមយិ តស្ស តាវីសមត្តំ ។
តតោ អហំ ចិត្តមិមំ កដេត្វា
ចរេ យថា កហុមុខា បទុគ្គា
តស្មា អហំ តោសជ តាលយាមិ
លោកោ មមំ មា បុណកតមាសិ ។

(៨៥) (គេសេសៈ...) ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនុះជាគោជនជាទីគាប់ចិត្តរបស់អ្នក ម្នាលបបក អ្នកទំនេរទាំងខ្ទង់លានលឹងសម្រេក ហើយរក្សាទុំ ១ ឧបោសថ តើព្រោះហេតុអ្វី ។

(៨៦) (បបក...) ខ្ញុំជាសត្វត្រេកអរក្នុងសាកសព ញាំមក្នុងសាច់ដ៏ទាំងឆ្ងាយ បានចូលទៅក្នុងរោងនៃដំរីធំ ឈ្លប់ដំរីក្តៅផង ស្ងួតព្រោះតាមតិច្ចដឹងភ្លៀងក្តៅផង របស់ទាំងនោះញុំាងខ្ញុំពាក់ហារ តាស់នៃដំរីនោះឲ្យស្ងួតគ្រៀម ។ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំស្ងួមស្ញើង (ក្នុងពោះនៃដំរីនោះ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះមក (ក្នុងពេលនោះ) ភ្លៀងនោះធ្វើគ្រាក់ហារពាស់នៃដំរីនោះឲ្យទទឹកសើម ។ បពិត្រលោកម្ចាស់ដ៏ចំរើន លំដាប់នោះ ទើបខ្ញុំចេញមកដូចជាព្រះចន្ទ ដែលរួចអំពីមាត់នៃរាហុ ព្រោះហេតុនោះ បានជាខ្ញុំរក្សាឧបោសថ កុំឲ្យលោកៈ ត្រូវសង្កត់ខ្ញុំបានទៀតឡើយ ។

(៤៦) វម្មិកថូបស្មឹ កិបិល្លិកានិ
និប្បោថយន្តោ តុវំ បុរេ ចរាសិ
ទុដ្ឋំ បិតាសិ អធិភាសយន្តោ
កស្មា ឧបោសថិកោ នុ អជ្ជ ។

(៤៧) សកំ និកេតំ អតិហេឡយានោ
អត្រិច្ឆតាយ មល្លគាមំ[១] អគច្ឆឹ
តតោ ជនា និក្ខមិត្វាន គាមា
កោទណ្ឌកេន បរិបោថយឹសុ មំ ។
សោ ភិន្នសីសោ រុហិរមក្ខិតង្គោ
បច្ចាគមាសឹ សកំ និកេតំ
តស្មា អហំ បោសថំ បាលយាមិ
អត្រិច្ឆតា មា បុនរាគមាសិ ។

(៤៨) យំ នោ អបុច្ឆិត្ថ តុវំ ភទន្ត
សព្វេវ ព្យាករិម្ហា យថាបជានំ
មយម្បិ បុច្ឆាម តុវំ ភទន្ត
កស្មា ឧបោសថិកោ នុ ព្រហ្មេ ។

---

១ ឱ. អត្រិច្ឆតា មល្លយតិ ។

(៤៦) (កបស...) កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្តៀរទាំងឡាយ លើក្បាលដំបូក ចាលក្នាយ៉ុ អ្នកទំអក់ព្រាំនូវតំណាងទឹង សម្រេចហើយក្បានូវទោសជ តើព្រោះហេតុអ្វី ។

(៤៧) (ភ្នាយ៉ុ...) ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមនុស្សជន ព្រោះតែសេចក្តីប្រាថ្នាលើសលប់ គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏ឃើញខ្ញុំ ចាប់ខ្ញុំ ខ្ញុំនោះ បែកក្បាលប្រឡាក់ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ព្រោះហេតុនោះ បានជាខ្ញុំក្បាលទោសជ កុំឡើងសេចក្តីប្រាថ្នាលើសលប់ ត្រឡប់មកបានទៀតឡើយ ។

(៤៨) (សត្វទាំងឡាយ...) បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់បានសាកសួរនូវសេចក្តីណាចំពោះយើងទាំងឡាយ យើងទាំងអស់គ្នាក៏បានឆ្លើយនូវសេចក្តីនោះ តាមចំណេះដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចំរើន ពួកយើងសូមសួរលោកម្ចាស់វិញ បពិត្រព្រាហ្មណ៍ លោកម្ចាស់បានក្បាលទោសជ តើព្រោះហេតុអ្វី ។

(៤៨) អនុបលិត្តោ មម អស្សមម្ហិ
បច្ចេកពុទ្ធោ មុហុត្តំ និសីទិ
សោ មំ អវេទី គតិមាគតិញ្ច
នាមញ្ច គោត្តំ ចរណញ្ច សព្វំ ។
ឯវម្បហំ វន្ទិ ន តស្ស បាទេ
ន ចាបិនំ មានគតេន បុច្ឆិំ
តស្មា អហំ បោសថំ បាលយាមិ
មានោ មមំ មា បុនរាគមាសិតិ ។

បញ្ចុបោសថិកជាតកំ សត្តមំ ។

មហាមោរជាតកំ

(៤៩) សចេ ហិ ត្យាហំ ធនហេតុ គហិតោ
មា មំ អវធី ជីវគាហំ គហេត្វា
រញ្ញោ ច មំ សម្ម ឧបន្តិ នេហិ
មញ្ញេ ធនំ លច្ឆសិនប្បកំ ។
(៥០) ន មេ អយំ តុយ្ហ វធាយ អជ្ជ
សមាហិតោ ចាបវរេ ខុរប្បោ
បាសញ្ច ត្យាហំ អធិបាតយិស្សំ
យថាសុខំ គច្ឆតុ មោររាជា ។

(៤៨) (តាបស...) ព្រះបច្ចេកពុទ្ធ មិនប្រឡាក់ (ដោយកិលេស) គង់ក្នុងអាស្រមរបស់យើងមួយរំពេច ព្រះអង្គបានញុំាងយើងឲ្យដឹងនូវទី ដែលត្រូវទៅនិងទីដែលត្រូវមកផង នូវនាមផង នូវគោត្រផង នូវសេចក្តីប្រព្រឹត្តទាំងអស់ផង ។ បើទុកជាយ៉ាងនេះ ក៏យើងនៅតែមិនថ្វាយបង្គំព្រះបាទ នៃព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ ព្រោះលុះក្នុងអំណាច មានះ ហេតុនោះ បានជាយើងរក្សាឧបោសថ កុំឲ្យមានះត្រឡប់មកកាន់យើងបានទៀតឡើយ ។

ចប់ បញ្ចុបោសថិកជាតក ទី ៧ ។

មហាមោរជាតក

(៤៩) (ស្តេចក្ងោកពោធិសត្វពោលថា) ម្នាលសំឡាញ់ ប្រសិនបើអ្នកចាប់ខ្ញុំ ព្រោះហេតុនៃទ្រព្យ អ្នកកុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ ហើយនាំខ្ញុំទៅកាន់សំណាក់ព្រះរាជាចុះ អ្នកមុខជានឹងបាននូវទ្រព្យដ៏ច្រើន ។

(៥០) (ព្រានព្រៃពោលថា) ធ្នូប្រសើរនឹងព្រួញនេះ ខ្ញុំមិនមែនយកមកប្រើដើម្បីនឹងបាញ់អ្នកក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកចេញ (ដោយគិតថា) ស្តេចក្ងោក ចូរទៅតាមសប្បាយចុះ ។

(៩២) យំ សត្ត វស្សានិ មមានុពន្ធិ
រត្តិន្ទិវំ ខុប្បិបាសំ សហន្តោ
អថ កិស្ស មំ បាសវសូបនីតំ
បមុត្តវេ ឥច្ឆសិ ពក្ខនាស ។
បាណាតិបាតា វិរតោ នុសជ្ជ
អភយន្នុ តេ សព្វភូតេសុ ទិន្នំ
យំ មំ តុវំ បាសវសូបនីតំ
បមុត្តវេ ឥច្ឆសិ ពក្ខនាស ។

(៩៣) បាណាតិបាតា វិរតស្ស ព្រូហិ
អភយញ្ច យោ សព្វភូតេសុ ទេតិ
បុច្ឆាមិ តំ មោររាជេតមត្ថំ
ឥតោ(១) ចុតោ កិំ លភតេ សុខំ សោ ។

(៩៤) បាណាតិបាតា វិរតស្ស ព្រូមិ
អភយញ្ច យោ សព្វភូតេសុ ទេតិ
ទិដ្ឋេវ ធម្មេ លភតេ បសំសំ
សគ្គញ្ច សោ យាតិ សរីរភេទា ។

---

១ ឱ. ម. ឥតោ ។

(៩២) (ស្តេចក្ងោក...) អ្នកទំអត់ទ្រាំនូវសេចក្តីស្រេកឃ្លាន ទាំងយប់ទាំងថ្ងៃ ដើរជាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វីក៏អ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចអំពីអន្ទាក់វិញ ។ អ្នកទើបនឹងវៀរចាកបាណាតិបាតក្នុងថ្ងៃនេះ ឬក៏អ្នកឲ្យអភ័យដល់សត្វទាំងពួង បានជាអ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចចាកអន្ទាក់វិញ ។

(៩៣) (កូនព្រានព្រៃ...) ម្នាលស្តេចក្ងោក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួងផង ខ្ញុំសូមសួរអ្នកនូវសេចក្តីនុ៎ះ បុគ្គលនោះច្យុតអំពីលោកនេះទៅ នឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ ។

(៩៤) (ស្តេចក្ងោក...) ខ្ញុំនឹងប្រាប់អំពីបុគ្គល ដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យ ដល់សត្វទាំងពួង បុគ្គលនោះរមែងបាននូវសេចក្តីសរសើរ ក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង ។

(៤៥) ន សន្តិ ទេវា ឥតិ អាហុ ឯកេ
ឥធេវ ជីវោ វិភវំ ឧបេតិ
តថា ផលំ សុកតទុក្កដានំ
ទត្តុបញ្ញត្តំ វទន្តិ ទានំ
តេសំ វចោ អរហតំ សទ្ទហានោ
តស្មា អហំ សកុណេ ឃាតយាមិ ។

(៤៦) ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
គច្ឆន្តិ ឱភាសយមន្តលិក្ខេ
ឥមស្ស លោកស្ស បរស្ស វា តេ
កថន្នុ តេ អាហុ មនុស្សលោកេ ។

(៤៧) ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
គច្ឆន្តិ ឱភាសយមន្តលិក្ខេ
បរស្ស លោកស្ស ន តេ ឥមស្ស
ទេវាតិ តេ អាហុ មនុស្សលោកេ ។

(៤៥) (កូនព្រាន...) សមណព្រាហ្មណ៍ពួកខ្លះបានពោលថា ទេវតាទាំងឡាយ មិនមានទេ ជីវៈក្នុងលោកនេះ រមែងដល់នូវសេចក្ដីដាច់សូន្យ ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្ដីដាច់សូន្យដូចគ្នា ទាំងនោះពោលថា ទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះ បានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ ។

(៤៦) (ស្ដេចក្អាក...) ព្រះចន្ទនឹងព្រះអាទិត្យទាំងពីរ ជាលំអឃើញងាយ ភ្លឺរុងរឿង ទៅក្នុងអាកាស ព្រះចន្ទនឹងព្រះអាទិត្យទាំងនោះ (ជារបស់) លោកនេះឬលោកដទៃ (ពួកជន) ក្នុងមនុស្សលោកហៅព្រះចន្ទនឹងព្រះអាទិត្យទាំងនោះថាជាអ្វី ។

(៤៧) (កូនព្រាន...) ព្រះចន្ទនឹងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿង ទៅក្នុងអាកាស ព្រះចន្ទនឹងព្រះអាទិត្យទាំងនោះ (ជារបស់) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជន ក្នុងមនុស្សលោក ហៅព្រះចន្ទនឹងព្រះអាទិត្យទាំងនោះថាជាទេវតា ។

(៩៨) ធិរត្ថុ តេ ជិហកា ហិតភកា
អហេតុកា យេ ន វទន្តិ កម្មំ
តថា ផលំ សុកតទុក្កដានំ
ឧត្តប្បញ្ញត្តិ យេ ច វទន្តិ ធាមំ ។

(៩៩) អត្ថា ហិ សច្ចំ វចនំ តវេតំ
កាបញ្ញំ ឆាណំ អផលំ ភវេយ្យ
តថា ផលំ សុកតទុក្កដានំ
ឧត្តប្បញ្ញត្តំ ការិ ភវេយ្យ ។
កាបដ្ឋកេ កិត្តិកាកេ កិមាចរី
កឹ សេវមានោ កេន តបោគុណេន
អក្ខាហិ [១]មេ មោរភាដមត្តំ
យថា អហំ នោ និរយំ បតេយ្យំ ។

(១០០) យេ កេចិ អត្ថិ សមណា បថព្យា
កាសាយវត្ថា អនគារិយំ ចរន្តិ
បាតោវ បិណ្ឌាយ ចរន្តិ កាលេ
វិកាលចរិយា វិរតា ហិ សន្តោ ។

---

១ ម. [illegible]

(៩៨) (ស្តេចកោត...) សមណព្រាហ្មណ៍ណាមិនពោលការកម្ម មិនពោលការផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណា ពោលថា មានជាគុណជាត ដែលមនុស្សល្ងង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកមិនកេ ជាអ្នកសាបសូន្យ ត្រូវគេរជញ្ជាលឲ្យពល់ ក្នុងលោកណៈនេះ មិនខាន ។

(៩៩) (កូនក្រាបព្រ...) ពាក្យរបស់អ្នកនុះទៀតពិត ព្រោះមានជាគុណជាតនៃផលផ្លូវល្អកើត ផលនៃអំពើដែលសត្វធ្វើល្អធ្វើអាក្រក់ក៏ផ្លូវល្អ ម្យ៉ាងទៀត (មាន) ជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ ផ្លូវល្អកើត ។ ទំរង់អំពើផ្លូវល្អ ធ្វើដោយហេតុផ្លូវល្អ ប្រព្រឹត្តផ្លូវល្អ សេពប៉ុរី ដោយគុណនៃតបៈផ្លូវល្អ មិនគប្បីធ្លាក់ទៅក្នុងនរកយ៉ាងណា ខ្ញុំសូមអ្នកសូមប្រាប់សេចក្តីនុះដល់ខ្ញុំ ដោយ●ប្រាយយ៉ាងនោះ ។

(១០០) (ស្តេចពុក...) ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្លៀកសំពត់កាសាវៈ ប្រព្រឹត្តក្នុងរបៀបទុត្តលញាតផ្ទះ ក្រាប់ទៅបិណ្ឌបាតអំពីព្រឹក ក្នុងកាលគួរ វៀរចាកការយាត្រាប់ទៅក្នុងកាលខុស ជាអ្នកស្ងប់ស្ងាត់ ។

តេ តត្ថ កាលេន ឧបសង្កមិត្វា
បុច្ឆាហិ យំ តេ មនសោ បិយំ សិយា
តេ តំ បវក្ខន្តិ យថាបជានំ
ឥមស្ស លោកស្ស បរស្ស ចត្ថំ ។

(១០១) [illegible] ជិណ្ណំ [illegible] ទុក្ខំ
បណ្ឌុបលាសំ ហរិតោ ទុមោវ
និសព្ភហីនោ មម លុទ្ធកោ
ជហាមហំ លុទ្ធកកម្មំ ។

(១០២) យេ តាចិ មេ សមណា អត្ថិ តត្ថ
សមាធិតេ [illegible] ធិរកាលញ្ញូ
តេសំ អហំ ជីវិតមេត្តំ ចត្តំ
តោតញ្ញ តេ អត្ថិសាតំ ចិតោតិ ។

១ [illegible] ទំព័រ ១០ ... ១២ ...

អ្នកចូលទៅរកសមណៈទាំងនោះ តាមកាលគួរ ក្នុងទីនោះ ហើយ ចូរសាកសួរចុះ ព្រោះផលណា ដែលនាំពេញចិត្ត របស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍នោះ ជាប្រយោជន៍ ក្នុងលោកនេះ និងក្នុងលោកខាងមុខ (ដល់អ្នក) តាមទំនង នៃការចម្រើន (របស់លោក) ។

(១០១) (ក្មេងប្រុសនោះក្រោកចាកព្រះរាជាក្នុងទាំងហើយក៏សំដែង ថា) ការកាត់ក្រចកក្រញ៉ាំ ខ្ញុំមានសក់រលីងហើយ ខ្ញុំ មានក្បាលទំពែក ស្លៀកពាក់ដោយសំពត់ព្រែគ្រលៀវ ដូច ពស់ស្រកស្បែកចាស់ចាំមុខ ឬក៏ដូចដើមឈើមានស្លឹក ទៀវ (ស្រពោន) ស្ងួតស្លេកស្លាំង ។

(១០២) (បាប្អូនទាំងឡាយស្លូតត្រង់) ពួកបក្សីណាច្រើនឆ្ងាយ ដែល ខ្ញុំមានកម្មពីមុនក្លែងបោក (របស់ខ្ញុំ) ខ្ញុំមានចិត្ត ឲ្យផ្តល់នូវសត្វទាំងឡាយនោះ ក្នុងទីប៉ុណ្ណោះ ខ្ញុំ មានរូបពាក្យកិលេសហើយ សត្វទាំងនោះ ចូលទៅកាន់ លំនៅរបស់ខ្លួនចុះ ។

(១០៣) លុទ្ទោ ចរី អាសហត្ថោ អរញ្ញេ

ពាធេតុ មោរាធិបតិំ យសស្សឹ

ពន្ធិត្វា មោរាធិបតិំ យសស្សឹ

ទុក្ខា បមុញ្ចិ យថាហំ បមុត្តោតិ ។

មហាមោរជាតកំ អដ្ឋមំ ។

តច្ឆសូករជាតកំ

(១០៤) យេ នេសមានា វិចរិម្ហ បព្ពតានិ វនានិ ច

អន្វេសំ វិបុលេ ញាតី តេមេ អធិគតា មយា ។

ពហុញ្ចិទំ មូលផលំ ភក្ខោ ចាយំ អនប្បកោ

រម្មា ចិមា គិរិនទ្យោ ផាសុវាសោ ភវិស្សតិ ។

ឥធេវាហំ វសិស្សាមិ សហ សព្វេហិ ញាតិភិ

អប្បោស្សុក្កោ និរាសង្កី អសោកោ អកុតោភយោ ។

(១០៣) (អភិសម្ពុទ្ធគាថា) ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រាច់ទៅក្នុងព្រៃ ដើម្បីចាក់ទ្រូស្ដេចក្ងោក ដែលមានយស លុះចាក់ទ្រូស្ដេចក្ងោក ដែលមានយសបានហើយ ក៏បានរួចចាកសេចក្ដីទុក្ខ ដូចអាត្មា-អញដែលបានរួច (ចាកទុក្ខដោយសារបញ្ញាញាណ) ដូច្នោះដែរ ។

ចប់ មហាមោរជាតក ទី៨ ។

តច្ឆសូករជាតក

អាគមិស្សុ តេ សន្តេ សកាំ និកេតំ

បុរក្ខតា បភាសិ សព្វកម្មំ ។

(៤៧៨) អាទាយ ឆត្តានំ តថុត្តមស្ស

វត្ថុ សុតេ អព្ភុដ្ឋាយ បវេត្យា

សុវណ្ណកនិក្ខំ សមន្តតោ ចោរ

សោ លុទ្ធកោ កោសិយោ ឧបាគមិ

ឧបាគសិ សោ ភទ្ទកញ្ញាយ ទត្វា

ទាតោ ទាតោ ហត្ថ សមស្ស ឧត្តា ។

(៤៧៩) ទិស្វាន ឆត្តានំ តថុត្តមស្ស

ភត្តុ បិយស្ស បុរិមាយ ជាតិយា

គន្ធេ គសុ្ប ហោសិ សជាសិ

សោ សា កាលមកាសិ តាណា ។

(៤៨០) សម្ពោធិបត្តោ ច មហាមុនាទេ

សិរិ មោកាសិ បរិសាយ មជ្ឈេ

បុព្វេ កិច្ចំ សុវិមុត្តចិត្តា

តាតាលោ តមុតាភេត្តុំ ពុទ្ធា ។

នាំទៅកាន់សេពទរ កីឡាមេឃ៉ែ ជាមហាលាភ ឈ្មោះសព្វសុភត្ថា

ដើម្បីន មកកាន់ទីនៅរបស់ខ្លួន ។

(៤៧៨) ព្រាហ្មណ៍នោះ បាននាំយកគ្រឿងតាក់តែងយានដ៏ប្រសើរ ជា

គ្រឿងល្អ ស្អាត មិនមានគ្រឿងលាបក្រៀងប្រឡាក់បាន ហើយថែងជី

ក្បិលក្បាច់យ៉ាងល្អ មានតម្លៃថ្លៃជាងមាស ហើយចូលទៅកាន់

កោសិយ៉ា ព្រាហ្មណ៍នោះ ក៏បានថ្វាយគ្រឿងតាក់តែងយានថ្វាយ

ព្រះភទ្ទកញ្ញា ដ៏ធំប្រសើរ ទូលព្រះបង្គំថាខ្ញុំសង្ឃាប់បាន

ហើយ សូមព្រះនាងទទួលយក នេះជាគ្រឿងរបស់អំពីនោះ ។

(៤៧៩) ព្រះភទ្ទកញ្ញានោះ ទតឃើញគ្រឿងតាក់តែងយានដ៏ប្រសើរ

ដែលផ្ទាប់ផ្គុំជាច្រើនឡាញ់ភ្លឺដោយកែវមណីជាតិមុខ ក៏ពេញចិត្តមួយគ្រឿង

ទីនោះឯង ហេតុនោះ ព្រះនាង ជាស្រីល្អ បានសោយ

ត្រេកអរលាលើយានទៅ ។

(៤៨០) (ព្រះពុទ្ធសម្ដែងថា...) ព្រះពុទ្ធព្រះអង្គបានសម្ដែងប្រាប់

សាវ័កទាំងឡាយថា មានតាមការច្រើនផង បានធ្វើនូវការ

ញញឹម ក្នុងកណ្ដាលពួកបរិស័ទ ភិក្ខុ មានចិត្តរួច

ស្រឡះ ក៏ក្រាបបង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយ មិន

ដែលធ្វើ នូវការញញឹមឲ្យប្រាកដ ដោយឥតហេតុទេ ។

យមេតំ សោច ធិហរី កុមារី
កាសាវវត្ថំ អធការិយំ ចរន្តំ
សា ទេវ ឥធ ក ជាតញ្ញា អហោសិ
អហំ ឥធ តាកកជា អហោសិ ។
អានាយ ធន្វានិ កដុក្ខមស្ស
វក្ខ សុរេ អប្បដិមេ ចវញ្ញា
យោ សទ្ទកោ កាសិបុរំ ទុវាគមំ
សោ ទេវ ឥធ ទេវទត្តោ អហោសិ ។
អាតាវស្សំ ចិរវត្ថសំសិតំ
ទុប្បាចំ ចរិតមិធំ [illegible]
វិតដ្ឋេ វិតសោកោ វិសល្លោ[១]
សយំ អភិញ្ញាយ អភាសិ ពុទ្ធោ ។
អហំ តេន សមយេន អហោសិ ឥធ ភិក្ខវេ
តាកកជា ឥធ អហោសិ បរិ ជាតកន្តិ ។

ខុទ្ទកាភាណំ ចប្បំ ។

សម្ពុលាជាតកំ

[៤៨០] វេធមានា គិរិកន្ទរាយំ
ឯកា តុវំ តិដ្ឋសិ សំហិតូរុ ។

១ ម. វិសល្លោ ។

អ្នកទាំងឡាយ បានឃើញនាងកុមារិកានៅជាំងដី ស្លៀកសំពត់កាសាវៈ ជាអ្នកបួស នាងកុមារិនោះ គឺការបេនោះ គឺព្រះនាងឧប្បលវណ្ណា ឯស្តេចដំរីក្តីការបេនោះ គឺតថាគតឯង ព្រះពៃណា កាន់យកធ្នូក្តាំងឡាយនៃដំរីប្រាសិរ ជាភ្នកដីស្តុក មិនមានអ្នកឯទៀតប្រៀបផ្ទឹមបានលើផែនដី ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះក្តីការនោះ គឺទេវ-ទត្ត ។ ព្រះពុទ្ធ ព្រះអង្គប្រាសចាកសេចក្តីក្រៅល់ក្រវាយ ប្រាសចាកសេចក្តីសោក ប្រាសចាកផ្លូវសរកិកៈ បាន ត្រាស់ដឹងច្បាស់ដោយព្រះអង្គឯង ហើយទ្រង់សំដែង នូវចរិតនុស់ដីនិងទាំងពីរនេះ ដែលនៅអស់កាលដ៏យូរ ជាក់ជួបមិនកន្លងបីថ្ងៃ ។

ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតនៅក្នុងនោះ កាលនោះ តថាគតជាស្តេចដំរី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ឆទ្ទន្តជាតក ទី ៦ ។

សម្ពុលជាតក

(៤៨១) (ព្រះបាទ ... ត្រាស់សួរថា) នែសុចីរៈ យើងបានឮនាងសម្បត្តិដែល បានធ្លាកចុះដំណើរ យើងព្រាហ្ម ដើម្បី ផល់ផ្លែកដាក់ ព្រោះដើម្បីទ្រទ្រង់ ផ្លែផ្លាដីនេះ ។

ជាប្ញូន ចោ អជាប្ញូន អជាម្នោ ទេ ន រត្តិ

កាំ ច្បាប់ ជាម្នោ ចរិត នេត្តា យោតិ សុចិរ ។

ឥទ ពេកចិន្តិត យេន បេត្ត យេន អចិន្តិត

យសំ នេវមនុស្សេសុ យេន ជាប្បាមុ ព្រាហ្មណា ។

យោ ហំ អត្តញ្ញ ធម្មញ្ញ កាតុមិច្ឆាមិ ព្រាហ្មណ

តំ ត្វំ អត្តញ្ញ ធម្មញ្ញ ព្រាហ្មណស្សាហំ បុច្ឆិតោ ។

(៤៨៦) ជាតញ្ញុត្រ វិទុក ភជ តតន្តាគុមរោតិ

យំ ត្វំ អត្តញ្ញ ធម្មញ្ញ កាតុមិច្ឆសិ ទក្ខិយ ។

(៤៨៧) បំហំ ហោ បហំពោ ពជ្ជ វិទុស្ស ទុបត្តិកាំ

ធិត្តាតុំ សុវណ្ណស្ស យារំ ពជ្ជ សុចិរ

អគិហារិ ឥធំ ជជ្ជ អត្តជន្មានុសិទ្ធិយា ។

(៤៨៨) សុខិទ្យោគ កាវត្ថាយោ វិទុស្ស ទុបត្តិកាំ

តមធុស ឥតោព្រហ្ម អសមានំ សរោ យោរ ។

(ហើយប្រកប) ដោយឧបធិ មិនប្រកបដោយអាសវៈ ព្រោះមានមិន កេញចំនួនដល់ហើយឡើយ ម្នាលសុន្ទរិកៈ អម៉ាចារបស់ព្រះគោ ត្តមជាត្រូវតែធ្វើ ។ ម្នាលព្រាហ្មណ៍ ហើយមិនមានបុគ្គលមិនមនិត្ត គួរ លោកនេះ ដោយអគ្គិហោមណាមួយ មិនមិត្តគួរលោក ដោយ អគ្គិហោមណាមួយ ពោរពេញដោយសេចក្តីល្អ គួរឲ្យលោកនឹង មនុស្សលោក ដោយអគ្គិហោមណាមួយ ។ ម្នាលព្រាហ្មណ៍ ហើយ ប្រាថ្នាដើម្បីធ្វើនូវអគ្គិហោមនោះ ម្នាលព្រាហ្មណ៍ អ្នកដែលហើយ សួរហើយ ចូរប្រាប់នូវអគ្គិហោមនោះ ។

(៤៨៦) (សុន្ទរិកព្រាហ្មណ៍ ក្រាបទូលថា) បពិត្រព្រះគោតមដ៏ចំរើន ព្រះអង្គ ប្រាថ្នាដើម្បីធ្វើនូវអគ្គិហោមណា តែរៀបចាត់ទុកព្រាហ្មណ៍ហើយ បុគ្គលឯង មិនគួរនឹងប្រាប់នូវអគ្គិហោមនោះបាន ។

(៤៨៧) (ព្រះថា ..) ម្នាលសុន្ទរិកៈ អ្នកចូរមកនេះ អ្នកឯងប្រាថ្នាយញ្ញប្រើ ទៅ អ្នកចូរទៅកាន់សំណាក់នៃពួកព្រាហ្មណ៍ ចូរតាំងអង្គនៃភ្លើង នៃមាសនោះទៅចុះ អ្នកចូរឲ្យនូវភ្លើងនៃមាសនោះ ជាគ្រឿងបូជា ដល់ការប្រៀនប្រដៅនូវអគ្គិហោម ។

(៤៨៨) (គតិសម្ពន្ធថា) សុន្ទរិកព្រាហ្មណ៍ ជាការទ្វារដែលត្រូវនោះ ចូលទៅកាន់សំណាក់នៃពួកព្រាហ្មណ៍ សុន្ទរិកៈ ជាមហាព្រាហ្មណ៍ ក៏បានឃើញនូវព្រាហ្មណ៍នោះ កំពុងតែចាំការអគ្គិជូរបស់ខ្លួន ។

(៦៨៥) រញ្ញាហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ
អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច វិទុរក្ខាហិ បុច្ឆិតោ ។

(៦៨៦) គង្គំ មេ បិទហិស្សន្តិ ន តំ សក្កោមិ ព្រាហ្មណ
អបិធេតុំ មហាសិន្ធុំ តំ កថំ សោ ភវិស្សតិ
ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។
ភទ្រការោ ច មេ បុត្តោ ឱរសោ មម អត្រជោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

(៦៨៧) ស្វាធិប្បាគា ភារទ្វាជោ ភទ្រការស្ស សន្តិកំ
តមទ្ទស មហាព្រហ្មា និសិន្នំ សម្ហិ វេស្មនិ ។

(៦៨៨) រញ្ញាហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ
អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច ភទ្រការ បព្រូហិ មេ ។

(៦៨៥) (សុចីរព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់មានព្រះបន្ទូលថា អ្នកចូរសួរនូវអត្ថនិងធម៌ បណ្ឌិតវិទុរៈ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌នោះ ។

(៦៨៦) (វិទុរព្រាហ្មណ៍ .) ម្នាលព្រាហ្មណ៍ ខ្ញុំ (គិតថា) អញនឹងបិទនូវទន្លេគង្គា តែមិនអាចបិទនូវទន្លេធំនោះបាន ព្រោះហេតុនោះ ឱកាសនោះ នឹងមានដូចម្តេចកើត ខ្ញុំដែលអ្នកសួរហើយមិនអាចដើម្បីប្រាប់នូវអត្ថនិងធម៌បានទេ ។ តែខ្ញុំមានកូនប្រុសមួយឈ្មោះ ភទ្រការ ជាឱរស ជាកូនបង្កើតរបស់ខ្ញុំ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរអត្ថនិងធម៌ ចំពោះភទ្រការនោះចុះ ។

(៦៨៧) (អភិសម្ពុទ្ធគាថា) សុចីរព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់ភទ្រការកុមារ សុចីរៈ ជាមហាព្រាហ្មណ៍ បានឃើញភទ្រការកុមារនោះ កំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ។

(៦៨៨) (សុចីរព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលភទ្រការកុមារ ព្រោះហេតុនោះ អ្នកចូរប្រាប់នូវអត្ថនិងធម៌ ដល់ខ្ញុំ ។

(៦៨៩) មំសកាជំ អវហាយ គោធំ អនុបតាមហំ
ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។
សញ្ជយោ នាម មេ ភាតា កនិដ្ឋោ មេ សុចីរត
តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

(៦៩០) ស្វាធិប្បាគា ភារទ្វាជោ សញ្ជយស្ស ឧបន្តិកំ
តមទ្ទស មហាព្រហ្មា និសិន្នំ សម្ហិ បរិសតិ ។

(៦៩១) រញ្ញោហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ
អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច សញ្ជយក្ខាហិ បុច្ឆិតោ ។

(៦៩២) សទា មំ គិលតេ មច្ចុ សាយំ បាតោ សុចីរត
ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។
សម្ភវោ នាម មេ ភាតា កនិដ្ឋោ មេ សុចីរត
តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

(៦៨៩) (ភទ្ទការកុមារ...) ខ្ញុំទំលាក់ចោលនូវសែងសាច់ហើយ ដេញតាមត្រកួត ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់ នូវអត្ថនិងធម៌បានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសញ្ជ័យ បពិត្រសុចីរតព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរ នូវអត្ថនិងធម៌ ចំពោះសញ្ជ័យនោះចុះ ។

(៦៩០) (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់សញ្ជយកុមារ សុចីរតៈជាមហាព្រាហ្មណ៍ បានឃើញនូវសញ្ជយកុមារនោះ អង្គុយកណ្តាលបរិស័ទរបស់ខ្លួន ។

(៦៩១) (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូត ព្រះបាទធនញ្ជយកោរព្យៈ មានយសទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ បានត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលសញ្ជយកុមារ ព្រោះហេតុនោះ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌ ។

(៦៩២) (សញ្ជយកុមារ...) បពិត្រសុចីរតព្រាហ្មណ៍ មច្ចុតែងលេបខ្ញុំ រាល់ល្ងាចរាល់ព្រឹក សព្វ ៗ កាល ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថនិងធម៌ ដល់អ្នកបានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសម្ភវៈ បពិត្រព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរ នូវអត្ថនិងធម៌ ចំពោះសម្ភវៈនោះចុះ ។

(៤៨៣) អត្ថោ វេ កោ ជហេយ្យ ចាយំ អស្មាក វុត្តំ
ភយោ ជតា ចិតាបុត្តា តេ សុបញ្ញាយ គោរិត្វា ។
ន តំ សមេក្ខាច អត្តាតំ អត្ថំ ធម្មំ បុច្ឆិតា
កាមំ ច ទហរោ ជញ្ញា អត្ថំ ធម្មំ បុច្ឆិតោ ។

(៤៨៤) មា នំ ទហរោតិ ឧញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មំ ព្រាហ្មណ ។
យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ អាភាយ អតិរោចតិ
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ ឧញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មំ ព្រាហ្មណ ។
យថាបិ រម្មកោ មាសោ គិម្ហានំ ហោតិ ព្រាហ្មណ
អតេវញ្ញេហិ មាសេហិ ទុមបុប្ផេហិ សោភតិ ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ

(៤៨៣) សុចីរតព្រាហ្មណ៍..) ម្នាលអ្នកដ៏ចំរើន បញ្ហាធម៌ កំសត្វប្រ ម៉្លេះ សម្ភវកុមារនេះ យើងមិនពេញចិត្តទេ ព្រោះជនណាដឹង ចូរ ទីកន្លែងតាំងនោះ មិនដឹងច្បាស់ដោយប្រាជ្ញាទៅហើយ ។ អ្នកតាំង ឡាយដែលខ្ញុំសួរហើយ មិនអាចប្រាប់នូវអត្ថនិងធម៌បាន ចំណង់ បើក្មេងក្មេង ដែលខ្ញុំសួរអត្ថនិងធម៌ហើយ គប្បីដឹងដូចម្ដេចកើត ។

(៤៨៤) (សញ្ជយកុមារ...) បពិត្រសុចីរតព្រាហ្មណ៍ លោកកុំសំគាល់ សម្ភវកុមារនោះថា ជាក្មេង ហើយមិនសួរ គួរតែសួរនូវសម្ភវ-កុមារ ទើបដឹងនូវអត្ថនិងធម៌ ។ ព្រះចន្ទ្រ ប្រាសចាកមន្ទិល កាលដើរទៅតាមអាកាសធាតុ រុងរឿងកន្លងនូវពួកផ្កាយទាំងអស់ ក្នុងលោក ដោយពន្លឺ យ៉ាងណាមិញ បពិត្រសុចីរតព្រាហ្មណ៍ សម្ភវកុមារ ក៏ជាក្មេងដែរ (តែរុងរឿងកន្លងនូវពួកបណ្ឌិតដទៃ សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ លោកកុំ សំគាល់នូវសម្ភវកុមារនោះថាជាក្មេង ហើយមិនសួរ គួរតែសួរ នូវសម្ភវកុមារ ទើបដឹង នូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ចេត្តមាសរមែងល្អលើសខែទាំងឡាយ ដទៃក្នុងរដូវក្ដៅ ដោយផ្កាឈើ ទាំងឡាយ ជាទីរីករាយដទៃទៀត យ៉ាងណាមិញ ។ សម្ភវកុមារ ក៏នៅក្មេងដែរ (តែរុងរឿងកន្លង នូវពួក បណ្ឌិតដទៃសេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ

មា នំ ទហរោតិ ឧញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។
យថាបិ ហិមវា ព្រហ្មេ បព្វតោ គន្ធមាទនោ
នានារុក្ខេហិ សញ្ឆន្នោ មហាភូតគណាលយោ
ឱសធេហិ ច ទិព្វេហិ ទិសា ភាតិ បវាតិ ច ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ ឧញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។
យថាបិ បាវកោ ព្រហ្មេ អច្ចិមាលី យសស្សិមា
ជលមានោ វនេ គច្ឆេ អនលោ កណ្ហវត្តនី
ឃតាសនោ ធូមកេតុ ឧត្តមាហេវនន្ទហោ
និសីថេ[1] បព្វតគ្គស្មឹ បហុតេជោ វិរោចតិ ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

១ ឱ. និស្សីថេ ។

បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្នំគន្ធមាទនៈជាចំណែកហិមវន្ត ជាលំនៅនៃពពួកទេវតា ដេរដាសដោយដើមឈើផ្សេងៗ ទាំងឡាយផង ដោយឱសថជាទិព្វទាំងឡាយផង រមែងញុំាងទិសទាំងឡាយឲ្យភ្លឺច្បាស់ផង ផ្សាយទៅកាន់ទិសទាំងឡាយ(ដោយក្លិនក្រអូប)ផង យ៉ាងណាមិញ ។ សម្ភវ-កុមារ ក៏ពិតមែនតែនៅក្មេង (តែរុងរឿងក្នុងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្លើងប្រាកដ ប្រកបដោយអណ្ដាត មានអំណាច កាលឆេះនូវគុម្ពឈើក្នុងព្រៃ មិនចេះឆ្អែត រមែងញុំាងផ្លូវខ្មៅឲ្យប្រព្រឹត្តទៅ ជាសភាវៈឆេះនូវខ្លាញ់ មានផ្សែងជាទង់ នៅលើកំពូលព្រះស្តុក មានតេជសម្រាប់នៅដ៏ច្រើន រមែងរុងរឿងលើកំពូលភ្នំ ក្នុងវេលាយប់ យ៉ាងណាមិញ ។ សម្ភវកុមារ ក៏ពិតមែនតែនៅក្មេង (តែរុងរឿងក្នុងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។

ជវេន ភទ្រំ ជានន្តិ   ពលិពទ្ទញ្ច វាហិយេ[១]

ទោហេន ធេនុំ ជានន្តិ   ភាសមានញ្ច បណ្ឌិតំ ។

ឯវម្បិ ទហរូបេតោ   បញ្ញាយោគេន សម្ភវោ

មា នំ ទហរោតិ មញ្ញាសិ   អបុច្ឆិត្វាន សម្ភវំ

បុច្ឆិត្វា សម្ភវំ ជញ្ញា   អត្ថំ ធម្មញ្ច ព្រាហ្មណ ។

(៤៨៥) ស្វាធិប្បាគា ភារទ្វាជោ   សម្ភវស្ស ឧបន្តិកំ

តមទ្ទស មហាព្រហ្មា   កីឡមានំ ពហី បុរេ ។

(៤៨៦) រញ្ញោហំ បហិតោ ទូតោ   កោរព្យស្ស យសស្សិនោ

អត្ថំ ធម្មញ្ច បុច្ឆេសិ   ឥច្ចព្រវិ យុធិដ្ឋិលោ

តំ ត្វំ អត្ថញ្ច ធម្មញ្ច   សម្ភវក្ខាហិ បុច្ឆិតោ ។

(៤៨៧) តគ្ឃ តេ អហមក្ខិស្សំ   យថាបិ កុសលោ តថា

រាជា ច ខោ តំ ជានាតិ   យទិ កាហតិ វា ន វា ។

១ ម. វាហេន ។

ជនទាំងឡាយ ស្គាល់សេះដ៏ចំរើនដោយល្បឿនផង ស្គាល់គោបម្រើក្នុងការដឹកផង ស្គាល់មេគោដោយរឹតនូវទឹកដោះផង ស្គាល់អ្នកប្រាជ្ញកាលនិយាយផង យ៉ាងណាមិញ ។ សម្ភវកុមារ ទោះនៅក្មេង (តែរុងរឿងក្នុងនូវគុណបណ្ឌិតដ៏សេស) ដោយបញ្ញានឹងការព្យាយាម ក៏យ៉ាងនោះដែរ ម្នាលព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថា នៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។

(៤៨៥) (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់នៃសម្ភវកុមារ សុចីរតៈ ជាមហាព្រាហ្មណ៍ បានឃើញនូវសម្ភវកុមារនោះ កំពុងលេងខាងក្រៅទីលំនៅ ។

(៤៨៦) (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈ ដែលមានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ នៃសម្ភវកុមារ ព្រោះហេតុនោះ អ្នកឯង ដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌ ។

(៤៨៧) (សម្ភវកុមារ...) បើដូច្នោះ អ្នកឈ្លាសវៃ (និយាយ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នក យ៉ាងនោះ ព្រះរាជាទ្រង់ជ្រាបនូវប្រស្នានោះ ទោះបីព្រះអង្គធ្វើតាមក្ដី មិនធ្វើតាមក្ដី ។

(៤៩៨) អដ្ឋ សុវេតិ សិសេយ្យ វញ្ញា ឫដ្ឋា សុចិរត
ធាតាត្វា អសេរី ភជា អគ្គេ ជាតេ យុតិដ្ឋិលោ
អជ្ឈត្តញ្ញោ សិសេយ្យ វញ្ញា ឫដ្ឋា សុចិរត
តុម្ពត្តិ ច ចិវេសេយ្យ យថាឧទ្ធេហ្វ អចេតសោ ។
អត្តានំ ធាតិវត្តេយ្យ អនន្ទំ ច សមាចរេ
អតិវេត្ត ចប្បតាវេយ្យ អចវេត្ត យុតោ សិយា ។
យោ ចមិតានំ ហិតានំ តាត្តំ ជាតានំ ចត្តិយេហ
សទា សោ វឌ្ឍតេ ភជា សុត្តបញ្ញោ កត្តិមា ។
ញាតីនញ្ចបិ យោ ហោតិ មិត្តេសុ ច វិរោចតិ
កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជតីតិ ។

សត្តុភត្តជាតកំ បញ្ចមំ ។

មហាកបិជាតកំ

(៤៩៩) ពារាណស្យំ អហុ រាជា កាសីនំ រដ្ឋវឌ្ឍនោ
មិត្តាមច្ចបរិព្យូឡ្ហោ អគមាសិ មិគាជិនំ ។

(៤៩៨) បពិត្រសុចិរតព្រាហ្មណ៍ បុគ្គលដែលព្រះរាជាសួរថា (យើងត្រូវ កុសល) ក្នុងថ្ងៃនេះឬ គប្បីក្រាបទូលថា ក្នុងថ្ងៃស្អែកវិញ កាលប្រយោជន៍ត្រូវការកើតឡើងហើយ ព្រះរាជាត្រាស់ការព្យៈ ជាយុត្តិផ្លូវតាម កុំធ្វើតាមពាក្យ(នោះ)ហើយទៅស្ងៀមនៅឡើយ បុគ្គលដែលព្រះរាជសួរហើយ គប្បីក្រាបបង្គំទូលនូវខ្លួនបញ្ញត្តិៈ ជាមនុស្សដែលប្រាជ្ញ សូមព្រះរាជាកុំសេពខ្ជិលច្រអូស ដូចបុគ្គលល្ងង់ដែលជាយក្សទេវតា ។ ព្រះរាជាកុំប្រព្រឹត្តកន្លងនូវអគតិ កុំប្រព្រឹត្តនូវអធម៌ កុំបង្កើតនូវក្ដីមិនមែនជាកិច្ចៈ កុំប្រកបក្នុងសេចក្ដីវិនាសឡើយ ។ បុគ្គលណាប្រណា ទ្រង់ត្រាប់តាមហើយធ្វើនូវហេតុទាំងឡាយនេះ ព្រះរាជានោះរមែងចំរើនរាល់ពេល ដូចជាព្រះចន្ទក្នុងសុក្កបក្ស ។ ព្រះរាជានោះប្រកបដោយប្រាជ្ញា រមែងជាទីស្រឡាញ់នៃពួកញាតិផង រុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងឋានសួគ៌ ។

ចប់ សត្តុភត្តជាតក ទី៥ ។

មហាកបិជាតក

(៤៩៩) (ព្រះសាស្ដាទ្រង់សំដែងថា) ព្រះរាជា ក្នុងក្រុងពារាណសី ព្រោះអង្គញ៉ាំងដែន របស់ពួកជនអ្នកដែនកាសីឲ្យចំរើន ព្រះអង្គមានពួកមិត្តនិងអាមាត្យហែហមហើយ ស្ដេចទៅកាន់មិគាជិនឧទ្យាន ។

តត្ថ ព្រាហ្មណមទ្ទក្ខិំ សេតំ ចិត្រំ កិលាសិនំ
វិទ្ធស្តំ កោវិឡារំវ កិសំ ធមនិសន្ថតំ ។
បរមការុញ្ញតំ បត្តំ ទិស្វា កិច្ឆគតំ នរំ
អវចំ ព្យម្ហិតោ ភីតា យក្ខានំ កតមោ នុសិ ។
បាទូទរា ច តេ សេតា ឥតោ សេតតរំ សិរោ
គត្តំ កម្មាសវណ្ណន្តេ កិលាសពហុលោ ចសិ ។
វដ្ដនាវលិសង្កាសា បិដ្ឋិ តេ និន្នតុន្នតា
កាឡបព្វា ច តេ អង្គា នាញ្ញំ បស្សាមិ ឯទិសំ ។
ឧគ្ឃដ្ដបាទោ តសិតោ កិសោ ធមនិសន្ថតោ
ឆាតោ អតិត្តរូបោសិ កុតោសិ កត្ថ គច្ឆសិ ។
ទុទ្ទសី អប្បការោសិ ទុព្វណ្ណោ ភីមទស្សនោ
ជនេត្តី យាបិ តេ មាតា ន តំ ឥច្ឆេយ្យ បស្សិតុំ ។
កិំ កម្មមការំ បុព្វេ កំ អវជ្ឈំ អឃាតយិ
កិព្ពិសំ យំ ករិត្វាន ឥទំ ទុក្ខំ ឧបាគមិ ។

ខ្ញុំបានឃើញព្រាហ្មណ៍ម្នាក់ កើតឃ្លង់ស ឃ្លង់ពពាល កើតស្រែង មានសាច់ស្លៀរចេញ ដូចជាផ្កាល្ហុងស្អុំ ស្គមឡើងសរសៃ ក្នុងទីជាទីចេញឡើងនោះ ។ ព្រោះខ្ញុំទតឃើញ ជនមានសេចក្តីលំបាក ដល់នូវភាពគួរអាណិតក្រៃលែង ខ្ញុំស្ញើប ខ្ញុំក្រាស់សួរថា បណ្តាពួកយក្ស អ្នកជាយក្សអ្វី ដៃនិងជើងរបស់អ្នកសផង ក្បាលរបស់អ្នក សលើសជាងដៃនិងជើងនោះផង ខ្លួនរបស់អ្នក មានសម្បុរពព្រុះផង មានស្រែងដ៏ច្រើនផង ។ ខ្នងរបស់អ្នក រវេចរវុច ដូចជាល្អូសដែលរៀបគ្នាផង អវយវៈរបស់អ្នក ដូចជាថ្នាំងរែងខ្មៅផង យើងមិនដែលឃើញបុគ្គលដទៃដូចអ្នកនេះឡើយ ។ អ្នកមានជើងប្រឡាក់ដោយធូលី ជាអ្នកស្រេកស្ងួត ស្គម ឡើងសរសៃពាស ស្រេកឃ្លាន មានសភាពជាអ្នកមិនឆ្អែត តើអ្នកមកអំពីទីណា នឹងទៅកាន់ទីណា ។ អ្នកជាបុគ្គលលំបាកមើល មិនមានទ្រង់ទ្រាយ មានសម្បុរមិនល្អ មើលទៅគួរខ្លាច សូម្បីតែមាតាបង្កើតរបស់អ្នក ក៏មិនចង់ឃើញអ្នកដែរ ។ អ្នកបានធ្វើនូវអំពើដូចម្តេចក្នុងកាលមុន អ្នកបានបៀតបៀន នូវសត្វដែលមិនគួរសម្លាប់ដូចម្តេច អ្នកធ្វើនូវអំពើអាក្រក់ណា ក៏បាននូវសេចក្តីទុក្ខនេះ ។

(៨០០) ហន្ទ តេ អហំ អក្ខិស្សំ យថាហិ កុសលោ តថា

សច្ចវាទិំ ហិ លោកស្មិំ បសំសន្តីធ បណ្ឌិតា ។

ឯកោ ចរំ គោគវេសោ មូឡ្ហោ អច្ចសរិំ វនេ

អរញ្ញេ ឥរីណេ វិវនេ នានាកុញ្ជរសេវិតេ ។

វាឡមិគានុចរិតេ វិប្បនដ្ឋោស្មិ កាននេ

អចរិំ តត្ថ សត្តាហំ ខុប្បិបាសាសមប្បិតោ ។

តត្ថ តិន្ទុកមទ្ទក្ខិំ វិសមដ្ឋំ ពុភុក្ខិតោ

បបាតមភិលម្ពន្តំ សម្បន្នផលធារិនំ ។

វាតស្សិតានិ ភក្ខេសិំ តានិ រុច្ចឹសុ មេ ភុសំ

អតិត្តោ រុក្ខមារុយ្ហ តត្ថ ហេស្សាមិ អាសិតោ ។

ឯកំ មេ ភក្ខិតំ អាសិ ទុតិយំ អភិបត្ថិតំ

តតោ សា ភញ្ជថ សាខា ឆិន្នា ផរសុនា វិយ ។

សោហំ សហាវ សាខាហិ ឧទ្ធំបាទោ អវំសិរោ

អប្បតិដ្ឋេ អនាលម្ពេ គិរិទុគ្គស្មិំ បាបតំ[1] ។

[1] ម. គិរិទុគ្គស្មិំ បបាតំ ។

(៨០០) (ព្រាហ្មណ៍ក្រាបបង្គំទូលថា) បើដូច្នោះ អ្នកណាស្គាល់ (និយាយ) ហើយណា ទូលព្រះបង្គំជាខ្ញុំនឹងទូល ហើយនោះ ព្រោះថា ក្នុងលោកនេះ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលអ្នកនិយាយពាក្យពិត ។ ទូលព្រះបង្គំជាខ្ញុំតែម្នាក់ឯង កាលដើរតទៅ ក៏ពិនិត្យមើលផ្លូវទៅ ក្នុងព្រៃស្ងប់ស្ងាត់ ជាព្រៃជាទីត្រជាក់ ព្រៃស្ងាត់ឈឹង ដែលពួកម្រឹគ ផ្សេងៗនៅហើយ ។ ទូលព្រះបង្គំជាខ្ញុំ វង្វេងផ្លូវក្នុងព្រៃ ដែលពួក ម្រឹគសាហាវដើរទៅមក ជាអ្នកមានសេចក្តីស្រេកឃ្លាន អស់៧ថ្ងៃ ដើរ ទៅក្នុងព្រៃនោះ ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវសេចក្តីស្រេកឃ្លានគ្រប សង្កត់ ក៏បានឃើញដើមទន្លាប់ក្នុងព្រៃនោះ ដុះនៅក្នុងទីមិនស្មើ សំយុងទៅកាន់ជ្រោះ ជាឈើទ្រទ្រង់នូវផ្លែមានសភាពផ្អែម ។ ទូល ព្រះបង្គំជាខ្ញុំ បានបរិភោគផ្លែឈើទាំងឡាយ ដែលខ្យល់បក់ធ្លាក់ ចុះមក ផ្លែឈើទាំងនោះ ពេញចិត្តទូលព្រះបង្គំជាខ្ញុំ ហើយក្រៃលែង ទូលព្រះបង្គំជាខ្ញុំមិនឆ្អែត ក៏ឡើងទៅលើដើម ដោយគិតថានឹងស៊ីឲ្យ ឆ្អែតស្កប់ស្កល់លើដើមនោះ ។ ទូលព្រះបង្គំជាខ្ញុំបរិភោគផ្លែបាន មួយហើយ ប្រាថ្នាផ្លែជាគំរប់ពីរទៀត លំដាប់នោះ មែកឈើនោះ ក៏បាក់ ហាក់ដូចជាគេកាប់នឹងពូថៅ ។ ទូលព្រះបង្គំជាខ្ញុំនោះ ក៏ជាប់ មកជាមួយនឹងមែកឈើ មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ដែលមិនមានទីពឹង មិនមានទីតោង ។

យស្មា ច ភរិ កម្ពីរំ   តស្មា ច សមបជ្ជិសំ
តត្ថ សេសឹ និរាសង្កោ   អនូនា ទសរត្តិយោ ។
អថេត្ថ កបិ មាគញ្ឆិ   គោលង្គុលោ ទរីចរោ
សាខាហិ សាខំ វិចរន្តោ   ខាទមានោ ទុមប្ផលំ
សោ មំ ទិស្វា កិសំ បណ្ឌុំ   ការុញ្ញមការី មយិ ។
អម្ភោ កោ នាម សោ ឯត្ថ   ឯវំ ទុក្ខេន អដ្ដិតោ
មនុស្សោ អមនុស្សោ វា   អត្តានំ មេ បវេទយ ។
តស្សញ្ជលឹ បណាមេត្វា   ឥទំ វចនមព្រវឹ
មនុស្សោហំ ព្យសនប្បត្តោ   ន មេ អត្ថិ ឥតោ គតិ
តំ តេ វទាមិ ភទ្ទន្តេ   ត្វញ្ច មេ សរណំ ភវ ។
គរុំ សិលំ គហេត្វាន   វិចរី បព្វតេ កបិ
សិលាយ យោគ្គំ កត្វាន   និសភោ ឯតទព្រវិ ។
ឯហិ មេ បិដ្ឋិមារុយ្ហ   គីវំ គណ្ហាហិ ពាហុភិ
អហន្តំ ឧទ្ធរិស្សាមិ   គិរិទុគ្គត វេគសា ។
តស្ស តំ វចនំ សុត្វា   វានរិន្ទស្ស សិរីមតោ
បិដ្ឋិមារុយ្ហ ធីរស្ស   គីវំ ពាហាហិ អគ្គហិ ។

ទឹកជ្រៅ មានត្រើយណា ខ្ញុំព្រះបង្គំជាខ្ញុំមិនធ្លាក់ដល់ត្រើយណោះទេ មិនមានសេចក្តីត្រេកអរ មិនមានទីពឹង ដេកក្នុងជ្រោះនោះអស់ ១០ រាត្រីគត់ ។ គ្រានោះស្វាមានកន្ទុយដូចជាកន្ទុយគោ ត្រាច់ទៅតាមជ្រោះភ្នំ មកដល់ទីនោះ លោតពីមែកមួយ ទៅកាន់មែកមួយ បានស៊ីផ្លែឈើ ស្វានោះបានឃើញនូវខ្ញុំព្រះបង្គំជាខ្ញុំ ដែលស្គមស្លេកស្លាំង ក៏ធ្វើនូវសេចក្តីករុណាចំពោះខ្ញុំព្រះបង្គំជាខ្ញុំ ។ ស្វាថា ម្នាលអ្នកដ៏ចំរើន អ្នកឯណានេះជាអ្វី ត្រូវទុក្ខគ្របសង្កត់ក្នុងទីនេះ យ៉ាងនេះ អ្នកជាមនុស្ស ឬមិនមែនមនុស្ស ចូរប្រាប់ខ្លួនដល់យើង ។ ខ្ញុំព្រះបង្គំជាខ្ញុំ ក៏ប្រណម្យអញ្ជលី ចំពោះស្វានោះ ហើយពោលនូវពាក្យនេះថា ខ្ញុំជាមនុស្សដល់នូវព្យសនៈ (សេចក្តីវិនាស) ខ្ញុំទៅអំពីទីនេះមិនបានទេ ព្រោះហេតុនោះ ខ្ញុំជំរាបអ្នក សូមសេចក្តីចំរើន មានដល់អ្នក សូមអ្នកជាទីពឹងរបស់ខ្ញុំ ។ ស្វាដ៏ប្រសើរ ត្រាច់ទៅលើភ្នំ ក៏យកនូវថ្មដ៏ធ្ងន់ ចងខ្សែនឹងថ្ម ហើយពោលនូវពាក្យនេះថា អ្នកចូរមក ចូរឡើងជិះខ្នងខ្ញុំ ហើយតោងកខ្ញុំដោយដៃទាំងពីរ ខ្ញុំនឹងស្រង់អ្នកចាកជ្រោះភ្នំ ដោយរហ័ស ។ ខ្ញុំព្រះបង្គំជាខ្ញុំ បានឮពាក្យស្តេចស្វាមានសិរីនោះ ក៏ឡើងជិះខ្នង នៃស្វាជាអ្នកប្រាជ្ញ ហើយតោងកដោយដៃទាំងពីរ ។

សោ មំ តតោ សមុទ្ធាសិ   វេធសី ពលសា កបិ
វិហញ្ញមានោ កិច្ឆេន   គិរិទុគ្គត វេគសា ។
ឧទ្ធរិត្វាន មំ សន្តោ   និសេកោ ឯកមព្រវិ
ត្វំ មំ សម្ម រក្ខស្សុ   បស្សុប្បិស្សំ មុហុត្តកំ ។
សីហា ព្យគ្ឃា ច ទីបិ ច   អច្ឆកោកតរច្ឆយោ
តេ មំ បមត្តំ ហិំសេយ្យុំ   តេ ត្វំ ទិស្វា និវារយ ។
ឯវំ មេ បរិត្តាតូន   បស្សុប្តិ សោ មុហុត្តកំ
តទាហំ បាបិកំ ទិដ្ឋិំ   បដិលត្ថំ អយោនិសោ ។
ភក្ខោ អយំ មនុស្សានំ   យថា ចញ្ញេ វនេ មិគា
យន្នូនិមំ វធិត្វាន   ឆាតោ ខាទេយ្យ វានរំ ។
អសិតោ ច គមិស្សាមិ   មំសមាទាយ សម្ពលំ
កន្តារំ និត្ថរិស្សាមិ   បាថេយ្យំ មេ ភវិស្សតិ ។
តតោ សិលំ គហេត្វាន   មត្ថកំ សន្និតាឡយឹ
មម ភត្តកិលន្តស្ស   បហារោ ទុព្ពលោ អហុ ។
សោ ច វេគេនុទប្បត្តោ   កបិ រុហិរមក្ខិតោ
អស្សុបុណ្ណេហិ នេត្តេហិ   រោទន្តោ មំ ឧទិក្ខតិ ។

ស្វានោះ មានសេចក្ដីលំបាកខ្លាំង ទៀបហត់ ដោយសេចក្ដីលំបាក បានស្រង់ខ្លួនព្រះបង្គំជាខ្ញុំចាកជ្រោះភ្នំ ដោយរហ័ស ។ ស្វាជាសប្បុរសដ៏ប្រសើរ លុះស្រង់ខ្លួនព្រះបង្គំជាខ្ញុំរួចហើយ ក៏ពោលនូវពាក្យនេះថា នែសំឡាញ់ អ្នកចូរការពារនូវខ្ញុំផង ខ្ញុំនឹងសម្រាកមួយរំពេច ។ បើពួកសត្វគឺសីហក្ដី ពួកខ្លាធំក្ដី ពួកខ្លាដំបងក្ដី ពួកខ្លាឃ្មុំក្ដី ពួកឆ្កែព្រៃក្ដី ពួកខ្លារខិនក្ដី ពួកសត្វទាំងនោះ មកបៀតបៀនខ្ញុំដែលធ្វេសប្រហែសហើយ បើអ្នកឃើញនូវសត្វណា ហាមឃាត់នោះចូរកំចាត់ផង ។ ស្វានោះ ឲ្យខ្លួនព្រះបង្គំជាខ្ញុំការពារយ៉ាងនេះ ហើយក៏ដេកលក់មួយស្របក់ទៅ គ្រានោះខ្លួនព្រះបង្គំជាខ្ញុំ បានទិដ្ឋិលាមក ដោយមិនត្រូវទំនងថា ស្វានេះ ជាអាហាររបស់ពួកមនុស្ស ដូចពួកម្រឹគដទៃ ក្នុងព្រៃដែរ បើដូច្នោះ គួរអាត្មាអញឃ្លានហើយ គប្បីសម្លាប់នូវស្វានេះស៊ី ។ អញស៊ីហើយ នឹងយកសាច់ជាស្បៀង ដើរទៅនឹងឆ្លងផ្លូវឆ្ងាយ ស្បៀងអញក៏មានស្រាប់ ។ លំដាប់នោះ ខ្លួនព្រះបង្គំជាខ្ញុំ ចាប់យកថ្មមកវាយក្បាល(ស្វានោះ) កាលខ្លួនព្រះបង្គំជាខ្ញុំ លំបាកដោយឃ្លាន ការប្រហារ ក៏មានកំឡាំងថយ ។ ឯស្វានោះ ក៏ស្ទុះក្រោកឡើងដោយរហ័ស ប្រឡាក់ដោយឈាម មានភ្នែកពេញដោយទឹកភ្នែក យំសម្លឹងមើលខ្លួនព្រះបង្គំជាខ្ញុំ ។

ហាយ្យា មំ អហិរីកន្តរេ   ត្វញ្ច អាបេមិសំ តាវ
ត្វញ្ច ទោ ធារ មិយាទុំ   អញ្ញ ករេកុមរោ ហសិ ។
អរេកោ វតរេ ធុវិសេ   ជារ ឧក្ការការក
ឯតិសោ វិសមោ ឧត្តា   បចាតា ទុក្ខតោ មយា ។
កាមីតោ បរលោកាវ   ទុក្ខេយ្យំ មំ អមញ្ញថ
កណ្តក តាវចវេន្ន   តាមំ តាវេន ចិត្តិតំ ។
មា ហោវ ត្វំ អធម្មដ្ឋ   វេទនំ កដុកំ ផុសិ
មា ហោវ តាវតាមន្តំ   ផលំ វេឡុវ តំ វធិ ។
តយិ មេ នត្ថិ វិស្សាសោ   តាបធម្ម អសញ្ញត
ឯហិ មេ បិដ្ឋិតោ គច្ឆ   ទិស្សមានោវ សន្តិកេ ។
មុត្តោសិ ហត្ថា វាឡានំ   បត្តោសិ មានុសិំ បជំ
ឯស មគ្គោ អធម្មដ្ឋ   តេន គច្ឆ យថាសុខំ ។
គិរិ វរា ចរិចរេ   រុហិរំ បគ្ឃរន្តិ
អស្សុនិ សន្ធមជ្ជិត្វា   ធាតោ បត្តមារុហិ ។

និយាយថា បពិត្រអ្នកដ៏ចំរើន អ្នកជាម្ចាស់ កុំធ្វើបាបខ្ញុំឡើយ អ្នកឯងធ្វើអំពើជាក្រៃលែងពេកនេះ ម្នាលអ្នកដែលមានអាយុវែង អ្នកឯងគួរតែហាមឃាត់នូវបុគ្គលដទៃ ៗ ដ៏សែនខ្លី តែខ្ញុំសេចក្តីថា ជាមនុស្សធ្វើអំពើអាក្រក់ផលយ៉ាងនេះ ឃើញបាននូវសេចក្តីទុក្ខពីជ្រោះជ្រៅក្រៃលែងនេះ ។ អញនាំអ្នកឯងមក(នេះ) ដូចជានាំមកពីបរលោក អ្នកឯងសំគាល់ឃើញថា គួរធ្វើទុក្ខ តាំងពីណាមកនោះ អ្នកឯងនោះជាមនុស្សលាមក ជាមនុស្សបាប គិតហើយ ។ នែអ្នកមិនប្រតិបត្តិធម៌ អ្នកឯងកុំប៉ះពាល់នូវទុក្ខវេទនា ដ៏ខ្លាំងក្លាឡើយ តាំងពីណាមកនោះ កុំសម្លាប់អ្នកឯងដូចជាផ្លែឫស្សី ដែលសម្លាប់ដើមឯងវិញឡើយ ។ នែអ្នកជាមនុស្សមានធម៌លាមក មិនសង្រួម សេចក្តីទុកចិត្តចំពោះអ្នក អ្នកឯងចូរមក អ្នកឯងចូរតាមខាងក្រោយយើងចុះ ។ អ្នកឯងរួចផុតអំពីកណ្តាប់ដៃ នៃពួកម្រឹគសាហាវហើយ អ្នកឯងបានដល់នូវបថពីជាខេត្តដែលមនុស្សហើយ នែអ្នកមិនប្រតិបត្តិធម៌ នុះផ្លូវអ្នកឯង ចូរដើរទៅឲ្យសុខសប្បាយតាមផ្លូវនោះចុះ ។ ស្វាដែលត្រាច់ទៅលើភ្នំ លុះបាននិយាយពាក្យនេះហើយ ទើបលាងឈាមក្បាលរបស់ខ្លួន ហើយជូតទឹកភ្នែកឲ្យជ្រះ ហើយលោតទៅកាន់ចុងឈើ ។

សោហំ គេលាតិសត្តស្មិំ បរិឡាហេន អដ្ដិតោ
ឧយ្ហមានេន គត្តេន វារឹ បាតុំ ឧទាគមឹ ។
អគ្គិ វិយ សន្តត្តោ រហទោ រុហិរមក្ខិតោ
បុព្វលោហិតសង្កាសោ សព្វោ មេ សមបជ្ជថ ។
យាវន្តោ ឧទពិន្ទូនិ កាយស្មិំ និបតិំសុ មេ
តាវន្តោ គណ្ឌ ជាយេថ អឌ្ឍបេលុវសាទិសា ។
បភិន្នា បគ្ឃរិំសុ មេ កុណបា បុព្វលោហិតា
យេន យេនេវ គច្ឆាមិ គាមេសុ និគមេសុ ច ។
ទណ្ឌហត្ថា និវារេន្តិ ឥត្ថិយោ បុរិសា ច មំ
ឱក្កិតា បូតិគន្ធេន មាស្សុ ឱរេន អាគមា ។
ឯតាទិសំ ឥទំ ទុក្ខំ សត្តវស្សានិ ទានិ មេ
អនុភោមិ សកំ កម្មំ បុព្វេ ទុក្កដមត្តនោ ។
តំ វោ វទាមិ ភទ្ទន្តេ យាវន្តេត្ថ សមាគតា
មាស្សុ មិត្តាន ទុព្ភិត្ថោ មិត្តទុព្ភោ ហិ បាបកោ ។

ខ្លួនព្រះបង្គំជាខ្ញុំនោះ ជាបុគ្គលដែលស្រេកទឹកជាសាហើយ ត្រូវសេចក្តីក្តៅក្រហាយរោលរាល មានខ្លួនក្តៅអន្ទះអន្ទែង បានចូលទៅរកចូលផឹកទឹក ។ អន្លង់ទឹកទាំងអស់ក៏ក្តៅសព្វ ហាក់ដូចជាភ្លើងនេះ ជាអន្លង់ហាក់ដូចជាប្រឡាក់ឈាម ហាក់ដូចជាខ្ទុះនឹងឈាមប្រាកដដល់ខ្ញុំ ។ ដំណក់ទឹកមានចំនួនប៉ុន្មាន ស្រក់លើកាយរបស់ទូលព្រះបង្គំជាខ្ញុំ បូសមានចំនួនប៉ុណ្ណោះ ប្រាកដស្មើដោយផ្លែព្នៅមួយចំហៀង ក៏កើតឡើង ។ ទូលព្រះបង្គំជាខ្ញុំ ទៅក្នុងស្រុកនិងនិគមទាំងឡាយ ណាម្តងណា ។ បូសទាំងឡាយក៏បែកធ្លាយខ្ទុះនឹងឈាម ដ៏ស្អុយ ហូរចេញ (គឺសាកៈ) របស់ទូលព្រះបង្គំជាខ្ញុំ (តាមផ្លូវនោះៗ) ។ ពួកស្ត្រីនិងបុរស មានដំបងក្នុងដៃ ដែលត្រូវក្លិនស្អុយគ្របសង្កត់ហើយ ឃាត់ទូលព្រះបង្គំជាខ្ញុំថា អ្នកឯងកុំចូលមកខាងនាយឡើយ ។ សេចក្តីទុក្ខលំបាកនេះប្រាកដដូច្នេះ បានដល់ទូលព្រះបង្គំជាខ្ញុំ អស់ ៧ ឆ្នាំ ហើយដល់មកឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំ នៅតែទទួលផលកម្មរបស់ខ្លួន ដែលខ្លួនធ្វើអាក្រក់ហើយក្នុងកាលមុន ។ ព្រោះហេតុនោះ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលចំពោះព្រះអង្គ សូមសេចក្តីចំរើនមានដល់ព្រះអង្គ ពួកអ្នកដែលមកប្រជុំគ្នាក្នុងទីនេះ សូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះថា បុគ្គលប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។

កុដ្ឋី កិលាសី ភវតិ យោ មិត្តានំ ទុព្ភតិ

កាយស្ស ភេទា មិត្តទ្ទុ និរយំ សោ ឧបបជ្ជតីតិ ។

មហាកបិជាតកំ ឆដ្ឋំ ។

ទករក្ខសជាតកំ

(៩០១) សចេ វោ វុយ្ហមានានំ សត្តន្នំ ឧទកណ្ណវេ
មនុស្សពលិមេសានោ នាវំ គណ្ហេយ្យ រក្ខសោ
អនុបុព្វំ កថំ ទត្វា មុញ្ចេសិ ទករក្ខសា ។

(៩០២) មាតរំ បឋមំ ទជ្ជំ ភរិយំ ទត្វាន ភាតរំ
តតោ សហាយំ ទត្វាន បញ្ចមំ ទជ្ជំ ព្រាហ្មណំ
ឆដ្ឋាហំ ទជ្ជមត្តានំ នេវ ទជ្ជំ មហោសធំ ។

(៩០៣) បោសេតា តេ ជនេត្តី ច ទីឃរត្តានុកម្បិកា
ឆព្ភិំ តយិ បទុស្សន្តិំ[១] បណ្ឌិតា អត្ថទស្សិនី
អញ្ញំ ឧបនិសំ កត្វា វធា តំ បរិមោចយិ

១ ម. បទុស្សតិ ។

(អភិសម្ពុទ្ធគាថា) បុគ្គលណា ប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

ចប់ មហាកបិជាតក ទី ៦ ។

ទករក្ខសជាតក

(៩០១) (តាំងពីនេះទៅព្រះរាជាសួរថា) កាលពួកយើងទាំង ៧ នាក់[១] របស់ព្រះអង្គ អណ្ដែតទៅក្នុងសមុទ្រធំជ្រៅ រាក្សសទឹកកាលស្វែងរកគ្រឿងបូជារបស់មនុស្ស គប្បីចាប់ទូក (ព្រះអង្គព្រះរាជទានខ្លួនអ្នកណាខ្លះ) តាមលំដាប់ដូចម្ដេច ទើបរួចអំពីរាក្សសទឹកបាន ។

(៩០២) (ព្រះបាទចូឡនីត្រាស់ថា) ខ្ញុំឲ្យមាតាជាមុន រួចឲ្យភរិយា ឲ្យប្អូន លំដាប់អំពីនោះ ឲ្យសំឡាញ់ ទីប្រាំឲ្យព្រាហ្មណ៍ជាគំរប់៥ ទើបឲ្យខ្លួនជាគំរប់៦ មិនឲ្យមហោសថទេ ។

(៩០៣) (តាំងពីនេះ...) ព្រះមាតាជាអ្នកចិញ្ចឹមព្រះអង្គផង ជាអ្នកបង្កើតផង អនុគ្រោះព្រះអង្គអស់កាលដ៏យូរផង កាលបើឆព្ភិព្រាហ្មណ៍ប្រទូស្តចំពោះព្រះអង្គ ព្រះមាតាជាបណ្ឌិត ជាអ្នកស្គាល់ប្រយោជន៍ ធ្វើឧបាយដទៃជាគ្រឿងបង្វៃ ហើយដោះព្រះអង្គឲ្យរួចអំពីការសម្លាប់

១ គឺមាតា១ ភរិយា១ និងព្រះអនុជ១ សំឡាញ់ឈ្មោះធនុសេខៈ១ បុរោហិត១ មហោសថ១ ស្ដេចចូឡនី១ ។ អដ្ឋកថា ។

តំ តាទិសំ បាណទទិំ ឱរសំ គព្ភធារិនិំ
មាតរំ កេន ទោសេន ទជ្ជាសំ ទករក្ខិនោ ។

(៨០៤) ទហរា វិយលង្ការំ ធារេតិ អបិលន្ធនំ
ទោវារិកេ អនីកដ្ឋេ អតិវេលំ បជគ្ឃតិ[១]
អថោបិ បដិរាជូនំ សយំ ទូតានិ សាសតិ
មាតរំ តេន ទោសេន ទជ្ជាហំ ទករក្ខិនោ ។

(៨០៥) ឥត្ថិគុម្ពស្ស បវរា អច្ចន្តំ បិយភាណិនី
អនុព្វតា សីលវតី ឆាយាវ អនុបាយិនី
អក្កោធនា បុញ្ញវតី បណ្ឌិតា អត្ថទស្សិនី
ឧព្ភរិំ កេន ទោសេន ទជ្ជាសំ ទករក្ខិនោ ។

(៨០៦) ខិឌ្ឌារតិសមាបន្នំ អនត្ថវសមាគតំ
សា មំ សកាន បុត្តានំ អយាចំ យាចតេ ធនំ
សោហំ ទទាមិ សារត្តោ ពហុំ ឧច្ចាវចំ ធនំ

១ ម. សញ្ជគ្ឃតិ ។

ព្រះអង្គព្រះរាជទានដល់អារក្សទឹកនូវព្រះមាតា ដែលមានព្រះគុណប្រាកដដូច្នោះ ជាអ្នកឲ្យនូវជីវិត ជាអ្នកឲ្យព្រះអង្គកើតអំពីទ្រូង ជាអ្នកទ្រទ្រង់នូវគភ៌នោះ តើព្រោះទោសដូចម្តេច ។

(៨០៤) (ព្រះរាជា...) ព្រះមាតាខ្ញុំ ទ្រទ្រង់គ្រឿងអលង្ការដែលមិនគួរតាក់តែងដូចស្ត្រីក្មេង សើចក្អាកក្អាយហួសវេលា (ជាមួយ) នឹងនាយឆ្មាំទ្វារ នឹងពួកពលសេនា មិនតែប៉ុណ្ណោះ ថែមទាំងបញ្ជូននូវទូតទាំងឡាយដល់ពួកបដិរាជ (ព្រះរាជានៅក្រោមអំណាច) ដោយខ្លួនឯង ខ្ញុំឲ្យព្រះមាតាដល់អារក្សទឹក ព្រោះទោសនោះឯង ។

(៨០៥) (នាងកែវ..) ឧត្តមមហេសី ជាស្ត្រីប្រសើរជាងពួកស្ត្រី ពោលពាក្យជាទីស្រឡាញ់ដ៏ក្រៃលែង ជាស្ត្រីមានសណ្តាប់ធ្នាប់ មានសីលធម៌ ប្រព្រឹត្តតាម(ព្រះអង្គ) ដូចជាស្រមោល ជាស្ត្រីមិនក្រោធ ជាអ្នកមានបុណ្យ ជាបណ្ឌិតឃើញនូវប្រយោជន៍ ព្រះអង្គព្រះរាជទាននាងនេះឲ្យដល់អារក្សទឹក តើព្រោះទោសដូចម្តេច ។

(៨០៦) (ព្រះរាជា...) នាងឧត្តមទេវីនោះ (បានដឹងច្បាស់) នូវខ្ញុំថាជាអ្នកប្រកបដោយសេចក្តីត្រេកអរក្នុងកីឡាល្បែង ទាំងជាអ្នកលុះអំណាចនៃកិលេស ដែលមិនមានប្រយោជន៍ នាងបានសូមចំពោះខ្ញុំ នូវទ្រព្យនៃកូនទាំងឡាយរបស់ខ្លួន ដែលជាទ្រព្យមិនគួរសូម ខ្ញុំនោះកំពុងតែត្រេកត្រអាល ក៏បានឲ្យទ្រព្យប្រសើរនិងថោកទាបច្រើនយ៉ាង

សុគន្ធិំ ចជិត្វាន ចន្ទា សោភាមិ ឥទ្ធោ

ទុក្ខី តេន ទោសេន ឧញ្ញាហំ ឧក្ការក្ខ តោ ។

(៨០៧) យោ តោ ចិតា ជាតបថា អាសីតា ច បដិក្ខហំ

អាភជិំ បរាជ្ជិក អភិជ្ជាយ ពហុខំ

ឧត្តុហានំ បរិំ សុវីំ កិច្ចិណាមត្តិកំ

កាតរី តេន ទោសេន ឧញ្ញាសិំ ឧក្ការក្ខ តោ ។

(៨០៨) យោ[១] តោ ចិតា ជាតបថា អាសីតា ច បដិក្ខហំ

អាភជិំ បរាជ្ជិក អភិជ្ជាយ ពហុជនំ

ឧត្តុហានំ បរាក សូរោ កិច្ចិណាមត្តិ ច[២]

មយាយិ សុចិតោ ភជា នតិ[៣] ម ញ្ញាតិ ធារតោ

ទុបដ្ឋានំបិ មេ អយ្យេ ន សោ បតិ យថា បុរេ

កាតរី តេន ទោសេន ឧញ្ញាហំ ឧក្ការក្ខ តោ ។

១ ម. យោតិកា ។ អដ្ឋកថា ។ ២ ម. តោ ។ ៣ ម. ឥតិ ។

សុគន្ធរបស់ខ្លួនចេញផ្សាយពេលនោះបានផ្សាយក្រហើយ ក៏មានចិត្ត តក់ស្លុតសោកស្តាយក្នុងកាលជាខាងក្រោយ ខ្ញុំឲ្យគេទំនាក់ផ្សែង ភាគីរថីក ព្រោះទោសនោះឯង ។

(៨០៧) (ភាគីរថី...) ខ្ញុំកើតជាបទចំរើនហើយ ព្រោះព្រះកន្ធកាក ណា ចាំងព្រះអង្គដែលព្រះកន្ធកាកណា ចាំមកកាន់ព្រះរាជ-ដំណាក់វិញ ព្រោះជម្ងឺព្រាប្រយ៉ាង ដែលព្រះកន្ធកាកណា រំលងចាំមកកាន់ក្នុងស្ពានដៃ ព្រោះទ្រង់ព្រះរាជនាំព្រះកន្ធកាក ជាបុគ្គលប្រសើរជាងក្នុងខ្ញុំ ជាអ្នកក្បៀវក្លា មានប្រាជ្ញាឆ្លៀត (នោះ) ដល់ភាគីរថីក តើព្រោះទោសដូចម្តេច ។

(៨០៨) (ព្រះរាជា...) ខ្ញុំកើតជាបទចំរើនហើយ ព្រោះកន្ធកាកណា ចាំងខ្ញុំ (ដែលកន្ធកាកណា) ចាំមកកាន់ដំណាក់វិញ ព្រោះជ-ម្ងឺព្រាប្រយ៉ាង (ដែលកន្ធកាកណា) រំលងនាំហើយចាំមក ក្នុងស្ពានដៃ កន្ធកាកនោះ មើលទៅយ៉ាង ឥតប្រសើរជាង ក្នុងខ្ញុំ ជាអ្នកក្បៀវក្លា មានប្រាជ្ញាឆ្លៀត ឯព្រះរាជានេះដូចជាក្មេង បានសេចក្តីសុខ ព្រោះតែឥតប្រក្រតីជាម្ចាស់ មិនតែប៉ុណ្ណោះ កន្ធកាកនោះ មិនមកកាន់ទីបំរើខ្ញុំដូចក្នុងកាលពីដើមទេ ខ្ញុំឲ្យ កន្ធកាក (នោះ) ដល់ភាគីរថីក ព្រោះទោសនោះឯង ។

(៨០៩) ឯករត្តេន ឧភយោ ត្វញ្ចេវ ធនុសេខក
ឧភោ ជាតេត្ថ បញ្ចាលា សហាយា សុសមាវយា
ចរិយា តំ អនុពន្ធិត្ថា(១) ឯកទុក្ខសុខោ តវ
ឧស្សុក្កោ តេ ទិវារត្តឹ សព្វកិច្ចេសុ ព្យាវដោ
សហាយំ តេន ពោសេន ឧញ្ញាសិ ចោរឃាតកោ ។

(៨១០) ចរិយា មំ អយំ អយ្យ សញ្ចរិត្វា(២) ឥធ សហ
អជ្ជាបិ តេន វណ្ណេន អតិវេលំ សញ្ចរតិ
ឧត្តរិយាបិហំ អយ្យ មន្តយាមិ រហោគតោ
អនាមន្តោ បវិសតិ បុព្វេ អប្បដិវេទិតោ
លទ្ធទ្វារោ កតោកាសោ អហិរិកំ អនាទរំ
សហាយំ តេន ទោសេន ឧញ្ញាហំ ចោរឃាតកោ ។

(៨១១) កុសលោ សព្វនិមិត្តានំ រុតញ្ញូ អាគតាគមោ
ឧប្បាតេ សុបិនេ យុត្តោ និក្ខមេ ច បវេសនេ

១ ម. ឧត្ថា ។ ២ ម. សញ្ញត្តោ ។

(៨០៩) (តាំងពី...) ជនទាំងពីរនាក់ គឺព្រះអង្គនឹងធនុសេខកុមារ ជាសំឡាញ់គ្នាល្មមស្មើគ្នា ព្រមទាំងកើតក្នុងបញ្ចាលនគរ ជាបុគ្គលពីរនាក់កើតក្នុងបញ្ចាលនគរនោះ ក្នុងរាត្រីតែមួយ ធនុសេខកុមារ មានទុក្ខសុខជាមួយគ្នានឹងព្រះអង្គ ជាប់តាមព្រះអង្គ ក្នុងការប្រព្រឹត្តទៅកាន់(ជនបទ) ជាអ្នកខ្មីឃ្មាតខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ដើម្បីព្រះអង្គ ទាំងថ្ងៃទាំងយប់ ព្រះអង្គក្រោធនឹងសំឡាញ់នេះដល់ការក្សេីក តើព្រោះហេតុដូចម្តេច ។

(៨១០) (ព្រះរាជា...) បពិត្រនាយម្ចាស់ ធនុសេខកុមារនេះ (ជាប់តាម) ខ្ញុំ ក្នុងការប្រព្រឹត្តទៅ (កាន់ជនបទ) ហើយក្អាកក្អាយជាមួយនឹងខ្ញុំ ក្នុងកាលមុន សូម្បីក្នុងថ្ងៃនេះ ក៏នៅតែរសើបក្អាកក្អាយ ហួសវេលា តាមទំនងនោះដែរ បពិត្រនាយម្ចាស់ ខ្ញុំនៅក្នុងទីស្ងាត់ កំពុងប្រឹក្សាជាមួយនឹងនាងទេវី ឯធនុសេខកុមារខ្ញុំមិនបានហៅ មិនបានឲ្យដំណឹងខ្ញុំជាមុនទេ ស្រាប់តែចូលមក ជាបុគ្គលមានទ្វារបានហើយ មានឱកាសធ្វើឲ្យហើយ ខ្ញុំឲ្យនូវសំឡាញ់ ជាមនុស្សមិនមានសេចក្តីអៀនខ្មាស មិនគោរព ដល់ការក្សេីក ព្រោះទោសនោះឯង ។

(៨១១) (តាំងពី...) ព្រាហ្មណ៍បុរោហិត ជាអ្នកឈ្លាសវៃក្នុងនិមិត្តទាំងពួង ជាអ្នកដឹងនូវសំឡេងនៃប្រេត ជាអ្នកឈ្លាសក្នុងទេក្ខារ ជាអ្នកទាយកាត់សុបិន ជាអ្នកឈ្លាសវៃក្នុងការចេញនិងការចូលផង

បហុ កុម្មគ្គលិក្ខស្មឹ ឧក្កដ្ឋបរោគារិកា

ព្រាហ្មណំ កេន ធោសេន ឆដ្ឋាសំ ឧការត្ថិតោ ។

(៨១២) បរិសាយំ តេ អយ្យេ ទុម្មិលំ ត្វា ទុដ្ឋិកម្ពិតំ

តស្មា អក្ខកំ សុម្មិំ ឧជ្ជាហំ ឧការត្ថិតោ ។

(៨១៣) សសមុទ្ទបរិយាយំ មហឹ សាគរកុណ្ឌលំ

វសុន្ធរំ អាវសសិ អមច្ចបរិវារិតោ

ចាតុរន្តោ មហារដ្ឋោ វិជិតាវី មហព្វលោ

បថព្យា ឯករាជាសិ យសោ តេ វិបុលំ គតោ

សោឡសិត្ថីសហស្សានិ អាមុត្តមណិកុណ្ឌលា

នានាជនបទា នារី ទេវកញ្ញូបមា សុភា

ឯវំ សព្វង្គសម្បន្នំ សព្វកាមសមិទ្ធិនំ

សុខិតានំ បិយំ ទីឃំ ជីវិតំ អាហុ ខត្តិយ

អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា

បណ្ឌិតំ អនុរក្ខន្តោ បាណំ ចជសិ ទុច្ចជំ ។

លើផែនដីនេះលើតាការសមុទ្រ ជាអ្នកឈ្លាសវៃ ក្នុងចំណោមពួកមន្ត្រី ព្រះអង្គព្រះរាជទានព្រាហ្មណ៍បុរោហិត ដល់ពួកសត្រូវ តើព្រោះតែហេតុដូចម្តេច ។

(៨១២) (ព្រះរាជា..) បពិត្រនាគដ៏ចំរើន ព្រាហ្មណ៍បុរោហិត មើលតែការសំរេចកិច្ចការទាំងពួងក្នុងបរិស័ទ ព្រោះហេតុនោះ ទើបខ្ញុំឲ្យបុរោហិតនាគ្រាន់ មានចំណេះច្រើន ដល់ការក្សត្រ ។

(៨១៣) (នាគកើត...) ព្រះអង្គគ្រប់គ្រងនូវផែនដីធំ មានសមុទ្រព័ទ្ធជុំវិញ ជាកុណ្ឌលរបស់សាគរ ព្រះអង្គមានអាមាត្យហែហម ជាម្ចាស់គ្រប់គ្រងលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានដែនដីច្រើន ជាអ្នកឈ្នះសង្គ្រាម មានពលច្រើន ជាព្រះរាជាឯក លើផែនដី យសរបស់ព្រះអង្គក៏ដល់នូវភាពដ៏ធំទូលាយ មានពួកនារីមកអំពីជនបទផ្សេង ១ ជាស្រីស្នំ ១៦ពាន់ ពាក់គ្រឿងកុណ្ឌលដែលធ្វើអំពីកែវមណី ល្អល្អះដូចស្រីទេពកញ្ញា បពិត្រក្សត្រ អ្នកប្រាជ្ញទាំងឡាយបាន ពោលថា ការរស់នៅដែលវែង ជារបស់ពួកជនដែលសម្បូណ៌ដោយអង្គទាំងពួង សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងជា ជាទីស្រឡាញ់របស់សត្វទាំងឡាយ អ្នកដល់នូវសេចក្តីសុខយ៉ាងនេះ កាលបើដូច្នោះ ព្រះអង្គរក្សាទុកនូវបណ្ឌិត ព្រោះបង់ជីវិតដែលគេលះបង់បានដោយកម្រ តើដោយអំណាចដូចម្តេច ឬក៏ដោយហេតុដូចម្តេច ។

(៨០៧) យតោបិ អាគតោ អយ្យោ មម ហត្ថំ មហោសធោ
នាភិជានាមិ ធីរស្ស អណុមត្តម្បិ ទុក្កដំ
សចេ ច កិស្មិញ្ចិ កាលេ មរណំ មេ បុរេ សិយា
បុត្តេ ច មេ បបុត្តេ[១] ច សុខាបេយ្យ មហោសធោ
អនាគតំ បច្ចុប្បន្នំ សព្វមត្ថំ វិបស្សតិ
អនាបរាធកម្មន្តំ ន ទជ្ជំ ទការក្ខិនោ ។

(៨០៨) ឥទំ សុណាថ បញ្ចាលា ចូឡនេយ្យស្ស ភាសិតំ
បណ្ឌិតំ អនុរក្ខន្តោ បាណំ ចជតិ ទុច្ចជំ
មាតុ ភរិយា ភាតុ ច សខិនោ ព្រាហ្មណស្ស ច
អត្តនោ ចាបិ បញ្ចាលោ ឆន្នំ ចជតិ ជីវិតំ
ឯវំ មហិទ្ធិយា[២] បញ្ញា និបុណា សាធុចិន្តិនី
ទិដ្ឋធម្មហិតត្ថាយ សម្បរាយសុខាយ ចាតិ ។

ទការក្ខសជាតកំ សត្តមំ ។

១ ម. សោធេ បុត្តេ បបុត្តេ ។ ២ ម. មហត្ថិកា ។

(៨០៧) (ព្រះរាជា..) បពិត្រនាងម្ចាស់ តាំងពីកាលដែលមហោសធបណ្ឌិត មកកាន់នៅក្នុងកណ្ដាប់ដៃនៃខ្ញុំ ខ្ញុំក៏មិនដែលឃើញនូវអំពើអាក្រក់ សូម្បីបន្តិចបន្តួចរបស់មហោសធបណ្ឌិតជាអ្នកប្រាជ្ញទេ ជាបើសេចក្ដីស្លាប់គប្បីមានដល់ខ្ញុំមុនក្នុងកាលណាមួយ មហោសធបណ្ឌិត គប្បីញុំាងកូនប្រុសទាំងឡាយ នឹងចៅទាំងឡាយរបស់ខ្ញុំឲ្យសុខ មហោសធបណ្ឌិត តែងពិចារណាឃើញនូវប្រយោជន៍ទាំងពួង ក្នុងកាលអនាគតនិងបច្ចុប្បន្ន (ព្រោះហេតុនោះ) ខ្ញុំមិនឲ្យនូវមហោសធបណ្ឌិតជាអ្នកមានការងារមិនដែលមានទោស (ដល់រាក្សសទឹកទេ)។

(៨០៨) (នាងភេរី...) អ្នកទាំងឡាយជាបញ្ចាលទាំងឡាយ ចូរស្ដាប់នូវភាសិតនេះរបស់ព្រះបាទចូឡនីនុះ ព្រះរាជាទ្រង់រក្សានូវបណ្ឌិត ស៊ូលះបង់នូវព្រះជន្មដែលគេលះបង់បានដោយក្រ ព្រះរាជាក្នុងបញ្ចាលជនបទលះបង់នូវជីវិតរបស់ជន ៦ រូបគឺ ព្រះមាតា១ ព្រះមហេសី១ ព្រះកនិដ្ឋភាតា១ សំឡាញ់១ ព្រាហ្មណ៍១ ព្រះអង្គ១ បញ្ញាជាគុណជាតិដ៏ល្អិត សម្រាប់គិតនូវប្រយោជន៍ដ៏ល្អ មានប្រមាណច្រើនយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ននេះផង ដើម្បីសេចក្ដីសុខក្នុងបរលោកផង ។

ចប់ ទការក្ខសជាតក ទី ៧ ។

បណ្ឌរកជាតកំ

(៨១៦) វិកិណ្ណវាចំ អនិគុយ្ហមន្តិំ
អសញ្ញតំ អបរិចក្ខិតារំ[១]
ភយន្តមន្វេតិ សយំ អពោធំ
នាគំ យថា បណ្ឌរកំ សុបណ្ណោ ។
យោ គុយ្ហមន្តំ បរិរក្ខណេយ្យំ
មោហា នរោ សំសតិ ហាសមានោ
តំ ភិន្នមន្តំ ភយមន្វេតិ ខិប្បំ
នាគំ យថា បណ្ឌរកំ សុបណ្ណោ ។
នានុមិត្តោ គរុំ អត្ថំ គុយ្ហំ វេទិតុមរហតិ
សុមិត្តោ ច អសម្ពុទ្ធំ សម្ពុទ្ធំ វា អនត្ថវា ។
វិស្សាសមាបជ្ជិមហំ អចេលំ
សមណោ អយំ សម្មតោ ភាវិតត្តោ
តស្សាហមក្ខឹ វិវរឹ គុយ្ហមត្ថំ
អតីតមត្ថោ កបណំ រុទាមិ ។
តស្សាហំ បរមំ ព្រហ្មេ គុយ្ហំ
វាចញ្ហិមំ នាសក្ខឹ សំយមេតុំ

១ ម. អបរិក្ខិតារំ ។

បណ្ឌរកជាតក

(៨១៦) (បណ្ឌរកនាគរាជពោលថា) ភ័យខ្លួនឯង រមែងជាប់តាម នូវបុគ្គលដែលមានវាចាល្អហាច មានមន្តមិនលាក់ទុក ជាអ្នកមិនសង្រួម មិនពិចារណា ជាអ្នកល្ងង់នោះ ដូចជាគ្រុឌចាប់យកនាគឈ្មោះបណ្ឌរកៈ ។ ជនណារីករាយ ប្រាប់មន្ត ដែលគួរលាក់ គួររក្សាទុក ព្រោះសេចក្តីវង្វេង ភ័យរមែងជាប់តាម នូវជននោះដែលមានមន្តបែកធ្លាយនោះដោយឆាប់ ដូចជាគ្រុឌចាប់យកនាគ ឈ្មោះ បណ្ឌរកៈ ។ មិត្តគ្រាន់តែបណ្តោយតាម មិនគួរឲ្យដឹងនូវហេតុជាខ្លាំងដែលគួរលាក់ ទាំងមិត្តល្អ ជាអ្នកមិនយល់ការ ឬយល់ការដែរ តែជាអ្នកមិនប្រាថ្នាប្រយោជន៍ (ក៏មិនគួរឲ្យដឹងដែរ) ។ អញដល់នូវសេចក្តីទុកចិត្តអចេល អចេលនេះ ជាសមណៈ គេគប់រកហើយ មានចិត្តចំរើនហើយ អញក៏ប្រាប់បើកនូវហេតុកំបាំងដល់អចេលនោះ ព្រោះជាអញមានប្រយោជន៍កន្លងហួស ហើយខ្ញុំយំ កំព្រាម្នាក់ឯង ។ បពិត្រគ្រុឌដ៏ប្រសើរ ព្រោះខ្ញុំមិនអាចនឹងសង្រួមវាចាដ៏ប្រសើរកំបាំងនេះ ដល់អចេលនោះ

តស្សក្ខាតោ ហិ ភយមាគតំ មម
អតីតមត្ថោ កបណំ រុទាមិ ។
យោ វេ នរោ សុហទំ មញ្ញមានោ
គុយ្ហមត្ថំ សំសតិ ទុក្កុលីនេ
ទោសា ភយា អថវា រាគរត្តោ
បល្លត្ថិតោ ពាលោ អសំសយំ សោ ។
តិរោក្ខវាចោ អសតំ បវិដ្ឋោ
យោ សង្គតីសុ ឧទីរេតិ វាក្យំ
អាសីវិសោ ទុម្មុខោត្យាហុ តំ នរំ
អារា អារា សំយមេ តាទិសម្ហា ។
អន្នំ បានំ កាសិកចន្ទនញ្ច
មនាបិត្ថិយោ មាលមុច្ឆាទនញ្ច
ឱហាយ គច្ឆាមសេ សព្វកាមេ
សុបណ្ណ បាណូបគតាវ ត្យម្ហា ។
[៥០៧] កោនីធ តិណ្ណំ គរហំ ឧបេតិ
អស្មឹ លោកេ បាណភូ នាគរាជ
សមណោ សុបណ្ណោ អថវា ត្វមេវ
កិំការណា បណ្ឌរកគ្គហីតោ ។

បានជាតែយកមកដល់ខ្ញុំ អំពីចំណែកនៃអាហារនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រា ហើយខ្ញុំយំ ។ ជនណាសំគាល់នូវបុគ្គលថា មានចិត្តល្អ ប្រាប់នូវការពិតកំបាំង ចំពោះជនមានត្រកូលអាក្រក់ ព្រោះតែទោសាគតិ ភយាគតិ ឬត្រេកអរដោយតម្រេកៈ ជននោះជាមនុស្សល្ងង់ឈ្មោះថា ភ្លាត់ហើយដោយឥតសង្ស័យ ។ ជនណាមានវាចាចេញទៅខាងក្រៅ ចប់ចូលក្នុងពួកអសប្បុរស ពោលនូវពាក្យ (កំបាំងរបស់គេ)ក្នុងទីប្រជុំ អ្នកប្រាជ្ញទាំងឡាយ ហៅជននោះថាជាអ្នកមានមាត់អាក្រក់ ដូចអាសិរពិស បុគ្គលគប្បីវៀរចាកបុគ្គលបែបនោះ ឲ្យឆ្ងាយចេញអំពីចំងាយ ។ យើងលះបង់នូវកាមទាំងពួង គឺ បាយ ទឹក សំពត់ក្នុងដែនកាសី ខ្លឹមចន្ទន៍ ពួកស្រីជាទីគាប់ចិត្ត គ្រឿងផ្កានិងគ្រឿងប្រស់ព្រំ បពិត្រសុបណ្ណៈ យើងសូមដល់នូវលោក (ជាទីពឹង) ស្មើដោយជីវិត ។

(៥០៧) (សុបណ្ណគ្រុឌសួរថា) ឈ្មោលនាគរាជ បណ្ដាជនទាំង ៣ នាក់ ក្នុងទីនេះ តើសត្វណានឹង សមណៈ ឬគ្រុឌ ឬអ្នកឯង គួរដល់នូវសេចក្ដីតិះដៀលបាន ក្នុងលោកនេះ ឈ្មោលបណ្ឌរកៈ (អ្នកឯងត្រូវខ្ញុំ) ចាប់បាន ព្រោះហេតុដូចម្ដេច ។

(៨១៨) សមណោ ហិ មេ សម្ភត្តោ អហោសិ
បិយោ ច មេ មនសា ភាវិតត្តោ
តស្សាហមក្ខឹ វិវរំ គុយ្ហមត្ថំ
អតីតមត្ថោ កាបុរិសោ វមាមិ ។

(៨១៩) ន ចត្ថិ សត្តោ អមរោ បថព្យា
បញ្ញាវិធា នត្ថិ ន និន្ទិតព្វា
សច្ចេន ធម្មេន ធិតិយា ទមេន
អលព្ភមព្យាហរតី នរោ ឥធ ។

មាតាបិតា បរមា ពន្ធវានំ
នាស្សុ តតិយោ អនុកម្បកត្ថិ
តេសម្បិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។

មាតាបិតា ភគិនី ភាតរោ ច
សហាយា វា យស្ស ហោន្តិ សបក្ខា
តេសម្បិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។

(៨១៨) (បណ្ឌរកៈ .) កាលណាសមណៈ ជាបុគ្គលមានសភាពដែលខ្ញុំរាប់អានហើយ ជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំ មានខ្លួនចំរើនហើយ ខ្ញុំប្រាប់បើកភាពដ៏កំបាំងដល់សមណៈនោះ ហើយ ខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រោះហើយខ្ជាយ ។

(៨១៩) (សុបណ្ណរាជ..) ធម្មតាសត្វលើផែនដី ឈ្មោះថា មិនស្លាប់ មិនមានទេ ចំណែកនៃបញ្ញា ជាធម្មជាតិដែលបុគ្គលមិនគួរតិះដៀល នរជនក្នុងលោកនេះ រមែងនាំមកនូវហេតុណាដែលបុគ្គលមិនគួរបាន ដោយសច្ចៈ១ ដោយសុចរិតធម៌១ ដោយធិតិបញ្ញា១ ដោយការទូន្មាននូវឥន្ទ្រិយ១ ។

មាតាបិតា ជាបុគ្គលប្រសើរជាងពួកញាតិទាំងឡាយ សត្វជាគំរប់ ៣ (ក្រៅអំពីមាតាបិតា) ឈ្មោះថាជាអ្នកអនុគ្រោះដល់បុគ្គលនោះមិនមានទេ បុគ្គលកាលរង្កៀសនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់ការសម្ងាត់ដ៏កំបាំងក្រៃលែងដល់មាតាបិតា ។

មាតាបិតា បងប្អូនស្រី បងប្អូនប្រុស នឹងសំឡាញ់ ឬញាតិទាំងពីរចំណែក របស់បុគ្គលនោះ បុគ្គលកាលរង្កៀសនូវការបែកធ្លាយមន្ត មិនគប្បីប្រាប់ នូវការសម្ងាត់ដ៏កំបាំងដ៏ក្រៃលែង ដល់មាតាបិតា ជាដើមនោះឡើយ ។

ភរិយា ចេ បុរិសំ វជ្ជា កោមារី បិយភាណិនី
បុត្តរូបយសូបេតា ញាតិសង្ឃបុរក្ខតា
តស្សាបិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។

(៤៦០) ន គុយ្ហមត្ថំ វិវរេយ្យ រក្ខេយ្យ នំ យថា និធឹ
ន ហិ បាតុកតោ សាធុ គុយ្ហោ អត្ថោ បជានតា ។
ថិយា គុយ្ហំ ន សំសេយ្យ អមិត្តស្ស ច បណ្ឌិតោ
យោ ចាមិសេន សំហីរោ ហទយត្ថេនោ ច យោ នរោ ។
គុយ្ហមត្ថមសម្ពុទ្ធំ សម្ពោធយតិ យោ នរោ
មន្តភេទភយា តស្ស ទាសភូតោ តិតិក្ខតិ ។
យាវន្តោ បុរិសស្សត្ថំ គុយ្ហំ ជានន្តិ មន្តិនំ
តាវន្តោ តស្ស ឧព្វេគា តស្មា គុយ្ហំ ន វិស្សជេ ។
វិវិច្ច ភាសេយ្យ ទិវា រហស្សំ
រត្តឹ គិរំ នាតិវេលំ បមុញ្ចេ

បើទុកជាភរិយា ជាស្រីក្មេង ពោលពាក្យជាទីស្រឡាញ់ មានបុត្រ [illegible] ។

(៨១៩) បុគ្គលកាលបើរៀរខ្លួនការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់នូវការលាក់កំបាំងដ៏ក្រៃលែង ដល់ភរិយានោះទេ ។

(៨៦០) បុគ្គលមិនគប្បីបើកនូវការលាក់កំបាំងទេ គប្បីរក្សានូវការលាក់កំបាំងឲ្យដូចជាកំណប់ ព្រោះការលាក់កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនប្រាប់គេ ជាការប្រពៃ ។ អ្នកប្រាជ្ញ មិនគប្បីនិយាយប្រាប់ការលាក់កំបាំងដល់ស្ត្រី ដល់ជនជាសត្រូវ ដល់ជនឡៀបឡប់ដោយអាមិសៈ ដល់ជនលួចគំនិត ។ ជនណាញុំាងអ្នកដទៃឲ្យដឹងការលាក់កំបាំងដែលគេមិនទាន់ដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចមនុស្សខ្ញុំគេ ។ ជនទាំងឡាយមានចំនួនប៉ុន្មាននាក់ ដឹងនូវមន្តជាការលាក់កំបាំងរបស់បុរស សេចក្តីតក់ស្លុតមានចំនួនប៉ុណ្ណោះ តែងកើតឡើង ដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីស្រាយនូវការលាក់កំបាំងឡើយ ។

នៅវេលាថ្ងៃ អ្នកប្រាជ្ញគប្បីនិយាយការលាក់កំបាំង ក្នុងទីស្ងាត់
នៅវេលារាត្រី មិនគប្បីបញ្ចេញសម្ដី ឲ្យហួសកម្រិត

ឧបស្សុតិកា ហិ សុណន្តិ មន្តំ
តស្មា មន្តោ ខិប្បមុបេតិ ភេទំ ។

[៨៦១] យថាបិ អយោឃរំ មហន្តំ
អទ្វារកំ អាយសំ ភទ្ទសាលំ[១]
សមន្តខាតបរិខាឧបេតំ
ឯវម្បិ មេ តេ ឥធ គុយ្ហមន្តា ។

យេ គុយ្ហមន្តា អវិកិណ្ណវាចា
ទឡ្ហា សទត្ថេសុ នរា ទុជិវ្ហ
អារា អមិត្តា ព្យវជន្តិ តេហិ
អាសីវិសា វារិ សត្តុសង្ឃា ។

[៨៦២] ហិត្វា ឃរំ បព្វជិតោ អចេលោ
នគ្គោ មុណ្ឌោ ចរតិ ឃាសហេតុ
តម្ហិ នុ ខោ វិវរិ គុយ្ហមត្ថំ
អត្ថា ច ធម្មា ច អបគ្គតម្ហា ។

កថំករោ ហោតិ សុបណ្ណរាជ
កិំសីលោ កេន វតេន វត្តំ

១ អដ្ឋកថា ភទ្ទសាលំ ។

ព្រោះថា ពួកជនអ្នកលួចស្តាប់ រមែងឮនូវមន្ត[១] ព្រោះហេតុនោះ មន្តក៏រមែងដល់នូវការបែកធ្លាយយ៉ាងឆាប់ ។

(៨៦១) ក្រុងដែលគេធ្វើដោយដែកដែលជាទីមិនមានទ្វារ (គេចូលមិនបាន) ក្នុងរោងដែលប្រកបដោយសាលា ដ៏មានកន្លែងល្អ ប្រកបដោយគូដែលគេជីកជុំវិញ យ៉ាងណា បុរសមានមន្តដែលខ្ញុំលាក់ទុកក្នុងហឫទ័យនេះ ព្រោះដល់ខ្ញុំយ៉ាងនោះដែរ ម្នាលអ្នកមានអណ្ដាតពីរ ពួកជនណាជាអ្នកមានមន្ត ទូលាក់ទុក មានវាចាមិនលួសលាយ ជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន សត្រូវទាំងឡាយ រមែងចៀសចេញឆ្ងាយអំពីពួកជននោះ ដូចពពួកនៃសត្វ ចៀសចេញអំពីអាសិរពិស ។

(៨៦២) (បណ្ឌារកៈ...) អចេល ជាអ្នកបួសលះបង់ផ្ទះ អាក្រាតត្រងោល ប្រព្រឹត្ត ព្រោះហេតុតែអាហារ ខ្ញុំបានបើកបង្ហាញនូវការទុកក្នុងចិត្តចំពោះអចេលនោះឯង (ព្រោះហេតុនោះ) បានជាខ្ញុំឃ្លាតចាកគុណនិងធម៌ ។ បពិត្រសុបណ្ណរាជ បុគ្គលធ្វើដូចម្ដេច មានសីលដូចម្ដេច ប្រព្រឹត្តនូវវត្តដូចម្ដេច

១ ពាក្យថា មន្តក្នុងទីនេះ សំដៅយកការប្រឹក្សាគ្នាអំពីកិច្ចការស្ងាត់កំបាំង ឬសំដៅយកមន្តអាគម ដែលគេរៀនហើយទន្ទេញទុក ។ អដ្ឋកថា ។

សមណោ ចរំ ហិត្វា មមាយិតានិ
កថំការកោ សគ្គមុបេតិ ឋានំ ។

(៨៦៣) ហិរិយា តិតិក្ខាយ ទមេន ខន្តិយា(១)
អក្កោធនោ បេសុណិយំ បហាយ
សមណោ ចរំ(២) ហិត្វា មមាយិតានិ
ឯវំការកោ សគ្គមុបេតិ ឋានំ ។

(៨៦៤) មាតាវ បុត្តំ តរុណំ តនុជ្ជំ
សម្ផស្សតា សព្វគត្តំ ផរេតិ
ឯវម្បិ មេ ត្វំ បាតុរហុ ទិជិន្ទ
មាតាវ បុត្តំ អនុកម្បមានោ ។

(៨៦៥) ធម្មំ ចរ ត្វំ ឥធ ទុជ្ជហំ
កាយោ ហិ ពុទ្ធា ធម្មា អញ្ញោ(២) អត្ថិ
អនេកភាសី ធិក្កោរា អត្រោជា ច
ឥជ្ឈន្តុ ពុទ្ធញ្ញាកោ មេ អហោសិ ។

(៨៦៦) ឥធេវ ភក្ខំ វិសជ្ជ សុវណ្ណា
ភុត្វា បតិដ្ឋាយ និធោ ទុជ្ជិ
ឧត្តដ្ឋ ត្វំ សព្វកាយោ ទិសត្ថា

១ ឱ. ទេវធម្មជាតកេ ។ អត្ថកថា ចរេ ។ ២ ឱ. អញ្ញោ ។

ឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីកង្វល់ (កណ្ហា) សមណៈនោះធ្វើដូចម្តេច ទើបទៅកាន់ឋានសួគ៌ ។

(៨៦៣) (សុវណ្ណកដ...) បុគ្គលប្រកបដោយហិរិ ដោយខន្តិ នឹងសេចក្តីអត់ធន់ ដោយការទូន្មាន (នូវឥន្ទ្រិយ) ជាអ្នកមិនខឹង លះបង់នូវពាក្យញុះញង់ ទើបឈ្មោះថាសមណៈប្រព្រឹត្តលះបង់នូវសេចក្តីកង្វល់ ឯសមណៈនោះធ្វើយ៉ាងនេះឯង ទើបចូលទៅកាន់ឋានសួគ៌បាន ។

(៨៦៤) (បណ្ឌក:) មាតាឃើញកូនខ្ចី ដែលកើតអំពីខ្លួន ហើយប៉ះពាល់នូវសម្ផស្សពេញកាយ យ៉ាងណាមិញ បពិត្រលោកជាព្រាហ្មណ៍ លោកជាអ្នកអនុគ្រោះ ប្រោសដល់ខ្ញុំ ដូចជាមាតា (អនុគ្រោះ) នូវបុត្រ យ៉ាងនោះ ។

(៨៦៥) (សុវណ្ណកដ...) នែអ្នកមានអណ្ណកតី អ្នកចូរវៀរចាកការសំឡាប់សត្វនៃបុគ្គលនេះ ព្រោះថាបុគ្គលមានគតិ ៣ យ៉ាង គឺកូនកើតអំពីខ្លួន ១ បុត្រក្រៅពីនេះមិនមានឡើយ អ្នកចូរគ្រប់គ្រងនូវអ្នកទាំងឡាយណាមួយ របស់ខ្ញុំហើយ ។

(៨៦៦) (អកិត្តិតាបស) ស្តេចស្រុកមានគ្រឿងអលង្ការ (ល្អដោយពាក្យ) យ៉ាងនេះហើយ ក៏បានទៅហើយផែនដី ដែលសត្វមានអណ្ណកតី ដោយពាក្យថា អ្នកចូរកសិកម្ម គឺនូវផ្លែឈើទាំងនេះហើយ

ជលូបគោ ហោតិ ឧយាតិកុត្តោ ។

អាតុរានំ យថា កុសលោ តិកិច្ឆកោ

បិបាសិតានំ រហទោវ សីតោ

វេស្មំ យថា ហិមសីតដ្ដិតានំ

ឯវម្បិ តេ សរណមហំ ភវាមិ ។

(៨៦៣) សន្ធឹ កត្វា អមិត្តេន អណ្ឌជេន ជលាពុជ

វិវរិយ ទាឋំ សេស្សសិ(*) កុតោ តំ ភយមាគតំ ។

(៨៦៤) សង្កេថេវ អមិត្តស្មឹ មិត្តស្មឹបិ ន វិស្សសេ

អភយា ភយមុប្បន្នំ អបិ មូលានិ កន្តតិ ។

កថំ នុ វិស្សសេ ត្យម្ហិ យេនាសិ កលហោ កតោ

និច្ចយត្តេន ហាតព្វំ សោ ទិសព្ភិ ន រជ្ជតិ ។

វិស្សាសយេ ន ច តំ វិស្សសេយ្យ

អសង្កិតោ សង្កិតោ ច ភវេយ្យ

តថា តថា វិញ្ញូ បរក្កមេយ្យ

យថា យថា ភាវំ បរោ ន ជញ្ញា ។

---

* [illegible]

ព្រោះត្រូវតែខ្ញុំគប់ត្រងក្នុងទីសោកនឹងទឹកហើយ ។

ខ្ញុំជាទីពឹងរបស់អ្នក ដូចជាពេទ្យដ៏ឈ្លាស (ជាទីពឹង) របស់ពួកអ្នកមានជម្ងឺ ឬដូចជាអន្លង់ទឹកត្រជាក់ (ជាប្រយោជន៍) របស់ពួកអ្នកស្រេកទឹក ឬក៏ដូចផ្ទះ (ជាទីត្រូវការ) របស់ពួកបុគ្គលដែលលំបាក ដោយសារត្រជាក់ ។

(៨៦៣) សុបណ្ណ (ក...) ម្នាលអ្នកជាជលាពុជៈ អ្នកធ្វើសេចក្តីសន្និស្មាល ជាមួយនឹងអណ្ឌជៈជាសត្រូវ ហើយនៅបើកចង្កូមដេក (ធ្វើអ្វីទៀត) ភ័យនឹងមកដល់អ្នក អំពីទីណា ។

(៨៦៤) (បណ្ឌរកៈ) បុគ្គលត្រូវតែរង្កៀសនូវបុគ្គលជាសត្រូវ មិនត្រូវទុកចិត្តបុគ្គលសូម្បីជាមិត្ត (ព្រោះ) ភ័យរមែងកើតឡើងអំពីបុគ្គលដែលមិនគួរភ័យ រមែងកាត់ សូម្បីឫសគល់ (ចោល) ។ បុគ្គលធ្វើឈ្លោះនឹងជនណា គប្បីទុកចិត្តជននោះដូចម្តេចកើត បុគ្គលគប្បីនៅ ដោយប្រុងប្រយ័ត្នជានិច្ច បុគ្គលនោះ រមែងមិនត្រេកអរនឹងសត្រូវ ។

បុគ្គលគប្បីធ្វើឲ្យគេទុកចិត្ត ប៉ុន្តែមិនត្រូវទុកចិត្តគេ បុគ្គលដែលគេមិនរង្កៀសហើយ ប៉ុន្តែគប្បីរង្កៀសនឹងគេ បុគ្គលដទៃ មិនដឹងនូវភាព (របស់ខ្លួន) ដោយហេតុណា ៗ វិញ្ញូបុរស គប្បីប្រឹងប្រែង ដោយប្រការយ៉ាងនោះ ៗ ។

(៤៦៩) តេ ទេវវណ្ណា សុខុមាលរូបា
ឧភោ សមា សុជវា បុញ្ញក្ខន្ធា
ឧបាគមុំ ការវិយំ[1] អចេលំ
មិស្សីភូតា អស្សវាហាវ នាគា ។

(៤៧០) ឥតោ ហវេ បណ្ឌរកោ អចេលំ
សយមេវុបាគម្ម ឥទំ អវោច
ឧត្តុប្ផហំ សច្ចកយាភិវត្តា
ន ហំ ទុន ភុញ្ជុំ មនសោ បិយត្តា ។

(៤៧១) បិយោ ហិ មេ អាសិ សុបណ្ណរាជា
អសំសយំ បណ្ឌរកេន សច្ចំ
សោ រាគរត្តោ ច អកាសិ មេតំ
បាបកម្មំ សម្បជានោ ន មោហា ។

(៤៧២) ន មេ បិយំ អប្បិយំ វាបិ ហោតិ
សម្បស្សតោ លោកមិមំ បរញ្ច
សុសញ្ញតានញ្ហិ វិយញ្ជនេន
អសញ្ញតោ លោកមិមំ ចរាសិ ។
អរិយាវកាសោសិ អនរិយោ វាសិ

---

[1] អដ្ឋកថាយំ ជន ការិយន្តិ បាឋោ ទិស្សតិ ។

(៤៦៩) (គរុឡសួរថា) បុរសទាំងនោះនាំឥសីអចេលកៈនោះ មានវណ្ណៈដូចជាទេវតា មានសរីរៈជាសុខុមាលជាតិស្មើគ្នា មានជ័យដ៏ល្អ មានគំនរនៃបុណ្យ គៀកនឹងគ្នា ដូចជាសេះទេះទឹម បានចូលទៅកាន់សំណាក់នៃអចេល ឯកពនឹការវិយៈ ។

(៤៧០) លំដាប់នោះឯង បណ្ឌរកនាគរាជ បានចូលទៅកាន់សំណាក់នៃអចេលដោយខ្លួនឯង ហើយពោលពាក្យនេះថា ខ្ញុំរួច (អំពីការសំឡាប់) កន្លងនូវភ័យតាំងពីក្នុងថ្ងៃនេះហើយ យើងមិនជាទីស្រឡាញ់របស់លោកដោយចិត្តពិតប្រាកដទេ ។

(៤៧១) (អចេល...) សុបណ្ណរាជ ជាទីស្រឡាញ់របស់ខ្ញុំ ជាងបណ្ឌរកនាគរាជមែន ឥតសង្ស័យ (នេះ) ជាពាក្យពិត ខ្ញុំនោះជាអ្នកត្រេកអរដោយរាគៈ ជាអ្នកដឹងច្បាស់ បានធ្វើនូវអំពើអាក្រក់នុ៎ះ មិនមែនព្រោះមោហៈទេ ។

(៤៧២) (បណ្ឌរកៈ...) បព្វជិត កាលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ រមែងមិនមានគំនិតថា វត្ថុជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ របស់អញដូច្នេះទេ អ្នកជាបុគ្គលមិនសង្រួមប្រព្រឹត្ត ក្នុងលោកនេះ ដោយភេទ របស់បុគ្គលអ្នកសង្រួមល្អ ៗ អ្នកឯងបង្អួតជាអរិយៈ តែមិនមែនជាអរិយៈទេ

អសព្ភាតោ សព្ភូតសម្មិកាសោ
កណ្ហាភិជាតិកោ អនរិយរូបោ
ការំ តហំ ទុក្កដំ អចារិ ។

[៤៣៣] អទុដ្ឋស្ស តុវំ ទុព្ភិ ទុព្ភី ច បិសុណោ ចសិ
ឯតេន សច្ចវជ្ជេន មុទ្ធា តេ ផលតុ សត្តធា ។

[៤៣៤] តស្មា ហិ មិត្តានំ ន ទុព្ភិតព្វំ
មិត្តទុព្ភា ហិ បាបិយោ នត្ថិ អញ្ញោ
អាសិត្តសត្តោ និហតោ បថព្យា
ឥន្ទស្ស វាក្យេន ហិ សំវរោ ហតោតិ ។

វណ្ណារោហជាតកំ អដ្ឋមំ ។

សម្ពុលាជាតកំ

[៤៣៥] កា វេធមានា គិរិកណ្ណិកាយំ
ឯកា តុវំ តិដ្ឋសិ សំហិតូរុ
បុដ្ឋាសិ មេ បាណិបមេយ្យមជ្ឈេ
អក្ខាហិ មេ នាមញ្ច ពន្ធវេ ច ។

អ្នកមិនសង្រួម តែមានភាពហាក់ដូចជាអ្នកសង្រួម មានជាតិខ្មៅ មានសភាពមិនប្រសើរ បានប្រព្រឹត្តនូវអំពើអាក្រក់ ទុច្ចរិតច្រើនយ៉ាង ។

(៤៣៣) ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្ត ដែលមិនបានប្រទូស្តទៀតផង ជាអ្នកញុះញង់ផង ដោយពាក្យសច្ចៈនេះ សូមឲ្យក្បាលរបស់អ្នកឯង បែកជា ៧ ភាគ ។

(៤៣៤) (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ បុគ្គលមិនត្រូវប្រទូស្តមិត្តទាំងឡាយឡើយ ព្រោះថា សភាវៈដទៃ ដែលអាក្រក់ជាងការប្រទូស្តមិត្ត មិនមានទេ អសុរឈ្មោះសំវរៈ ត្រូវសត្វកាចពិសប្រហារខ្ទាត ក៏ធ្លាក់ចេញអំពីផែនដី វិនាស តាមពាក្យរបស់ឥន្ទ្រដ៏ប្រសើរ ។

ចប់ វណ្ណារោហជាតក ទី ៨ ។

សម្ពុលាជាតក

(៤៣៥) (ទានវៈ[១]សួរថា) ម្នាលនាងមានភ្លៅល្អ នាងឈ្មោះអ្វី ញ័ររន្ធត់នៅជ្រោះនៃភ្នំ ឈរនៅតែម្នាក់ឯង ម្នាលនាងមានចង្កេះត្រង់កណ្តាលគួរកំណត់ដោយដៃ (បាតដៃ) យើងសួរហើយ នាងចូរប្រាប់ នូវនាមនិងផៅពង្ស ដល់យើង ។

១ [illegible] ។

ឱភាសយំ វនំ រម្មំ   សីហព្យគ្ឃនិសេវិតំ
កា វា ត្វមសិ កល្យាណី   កស្ស វា ត្វំ សុមជ្ឈិមេ
អភិវាទេមិ តំ ភទ្ទេ   ទានវាហំ នមត្ថុ តេ ។
(៥៣៦) យោ បុត្តោ កាសិរាជស្ស   សោត្ថិសេនោតិ តំ វិទូ
តស្សាហំ សម្ពុលា ភរិយា   ឯវំ ជានាហិ ទានវ
អភិវាទេមិ ភន្តេ   សម្ពុលាហំ នមត្ថុ តេ ។
វេទេហបុត្តោ ភទ្ទន្តេ   វនេ វសតិ អាតុរោ
តមហំ រោគសមាបន្នំ   ឯកា ឯកំ ឧបដ្ឋហិំ ។
អហញ្ច វនមុញ្ឆាយ   មធុមំសំ មិគាសិតំ
យទាហរាមិ តំ ភក្ខំ   តស្ស នូនជ្ជ ឆាទតិ ។

ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានចង្កេះកណ្ដាលដ៏ល្អ នាងជាធីតា របស់អ្នកណា នាងញុំាងព្រៃជាទីរីករាយ ដែលសីហៈនិងខ្លាធំអាស្រ័យនៅ ឲ្យភ្លឺរុងរឿង ម្នាលនាងដ៏ចំរើន យើងឈ្មោះទានវៈ សូមសំពះនាង សូមនមស្ការចំពោះនាង ។

(៥៣៦) (នាងសម្ពុលាឆ្លើយថា) អ្នកណាជាបុត្រ របស់ព្រះរាជាក្នុងដែនកាសី អ្នកដទៃតែងស្គាល់អ្នកនោះថា ព្រះនាម សោត្ថិសេន ខ្ញុំឈ្មោះនាងសម្ពុលា ជាភរិយា របស់ព្រះរាជបុត្រ ព្រះនាមសោត្ថិសេន នោះ បពិត្រទានវៈ លោកចូរដឹងយ៉ាងនេះចុះ បពិត្រលោកដ៏ចំរើន ខ្ញុំឈ្មោះសម្ពុលា សូមសំពះ សូមនមស្ការចំពោះលោក ។ បពិត្រលោកដ៏ចំរើន ព្រះរាជបុត្ររបស់ព្រះរាជាវិទេហៈ ប្រឈួនក្ដៅក្រហាយ គង់នៅក្នុងព្រៃ ខ្ញុំជាស្ត្រីម្នាក់ឯង បំរើព្រះរាជបុត្រ ដែលមានរោគបៀតបៀន មួយអង្គឯងនោះ ។ មិនតែប៉ុណ្ណោះ ខ្ញុំ (ត្រាច់ទៅ) ដើម្បីស្វែងរកផ្លែឈើ ក្នុងព្រៃ នាំមកនូវទឹកឃ្មុំនិងសាច់ដែលជាអាហាររបស់ម្រឹគណា (ស្វាមីរបស់ខ្ញុំ) មានទឹកឃ្មុំនិងសាច់ ជាអាហាររបស់ម្រឹគនោះ ជាអាហារ(កាល បើមិនបានអាហារនេះ)របស់ស្វាមីខ្ញុំនោះ ទឹងទ្រាំទ្រមិនបាន ក្នុងថ្ងៃនេះ ដោយពិត ។

(៤៣៧) កិំ វត រាជបុត្តេន រោគុវេន ការិស្សសិ
សម្ពុលេ បរិចិណ្ណេន អហំ ភត្តា ភវាមិ តេ ។
សោកដ្ឋាយ ទុរត្តាយ កិំ រូបំ វិន្ទតេ មម
អញ្ញំ បរិយេស ភទ្ទន្តេ អភិរូបតរំ មយា ។
ឯហិមំ គិរិមារុយ្ហ ភរិយា មេ ចតុស្សតា
តាសំ ត្វំ បវរា ហោហិ សព្វកាមសមិទ្ធិនី ។
ននុ តារកវណ្ណាភេ យង្កិញ្ចិ មនសិច្ឆសិ
សព្វន្តំ បចុរំ មយ្ហំ រមស្សុជ្ជ មយា សហ ។
នោ ចេ តុវំ មហេសេយ្យំ សម្ពុលេ ការយិស្សសិ
អលំ ត្វំ បាតរាសាយ បណ្ហេ ភក្ខា ភវិស្សសិ ។
តញ្ច សត្តជដោ លុទ្ទោ កឡារោ បុរិសាទកោ
វនេ នាថំ អបស្សន្តិំ សម្ពុលំ អគ្គហី ភុជេ ។
អធិបន្នា បិសាចេន លុទ្ទេនាមិសចក្ខុនា
សា ច សត្តុវសម្បត្តា បតិមេវានុសោចតិ ។

(៤៣៧) (ទេវតា...) ម្នាលនាងសម្ពុលា នាងធ្វើ (នូវការបួលចិត្ត) នឹងព្រះរាជបុត្រ ប្រហែលនឹងភ្លើងក្រហាយ ដែលគេដាក់ឲ្យឆេះនៅក្នុងព្រៃ ធ្វើអ្វី ខ្ញុំសូមជាភស្តារបស់នាង ។

(នាងសម្ពុលា...) ខ្ញុំកំសត់មានរូបដូចមនុស្សកើតទុក្ខ ព្រោះខ្ញុំជាស្ត្រីមានសេចក្តីសោកគ្របសង្កត់ មានខ្លួនដ៏លំបាក បពិត្រលោក ដើម្បីអ្វី លោកចូរស្វែងរកស្ត្រីឯទៀត ដែលល្អជាងខ្ញុំចុះ ។

(ទេវតា...) នាងចូរមកចុះ ចូរឡើងកាន់ភ្នំនេះ ប្រពន្ធរបស់ខ្ញុំមាន ៤០០ នាក់ នាងចូរជាស្ត្រីដ៏ប្រសើរជាងស្ត្រីទាំងនោះ ចូរសម្រេចការសេចក្តីប្រាថ្នា គ្រប់យ៉ាង ។ ម្នាលនាង មានពន្លឺដូចផ្កាយ នាងប្រាថ្នាក្នុងចិត្ត ចំពោះវត្ថុណាមួយ វត្ថុទាំងអស់នោះរបស់ខ្ញុំមានគ្រប់គ្រាន់ ចូរនាងត្រេកអរ ជាមួយនឹងយើង ក្នុងថ្ងៃនេះចុះ ។ ម្នាលនាងសម្ពុលា បើនាងមិនធ្វើនូវភាពជាមហេសីរបស់ខ្ញុំទេ នាងនឹងជាអាហារក្នុងវេលាព្រឹក នឹងជាចំណីរបស់ខ្ញុំក្នុងព្រហាម ។

ចំណែកយក្ខនោះ មានគន្ធីសក់ ៧ ជាន់ ជាជាតិកាចក្រៃ មានចង្កូម ជាអ្នកស៊ីនូវមនុស្ស ចាប់នាងសម្ពុលានោះ ត្រង់ដើមដៃ ដែលមិនឃើញនូវទីពឹង ក្នុងព្រៃ ។ នាងសម្ពុលា ដែលបិសាចកាចក្រៃ មានភ្នែកប្រកបដោយអាមិសគ្របសង្កត់ ជាស្ត្រីលុះក្នុងអំណាចនៃសត្រូវហើយ ក៏សោកសៅ រកតែស្វាមីជា

ន មេ ឥទំ តថា ទុក្ខំ យំ មំ ខាទេយ្យ រក្ខសោ
យញ្ច មេ អយ្យបុត្តស្ស មនោ ហេស្សតិ អញ្ញថា ។

ន សន្តិ ទេវា បវសន្តិ នូន
ន ហិ នូន សន្តិ ឥធ លោកបាលា
សហសា ករោន្តានមសញ្ញតានំ
ន ហិ នូន សន្តិ បដិសេធិតារោ ។

(៤៣៨) ឥត្ថីនមេសា បវរា យសស្សិនី
សន្តា សមា អគ្គិរិវុគ្គតេជា
តញ្ចេ តុវំ រក្ខសាទេសិ កញ្ញំ
មុទ្ធា ច ហិ សត្តធា តេ ផលេយ្យ
មា ត្វំ ទហិ មុញ្ច បតិព្វតាយ ។

(៤៣៩) សា ច អស្សមមាគច្ឆិ បមុត្តា បុរិសាទកា
និឌ្ឌំ បលីនសកុណីវ[១] គតសិង្គីវ អាលយំ ។
សា តត្ថ បរិទេវេសិ រាជបុត្តី យសស្សិនី
សម្ពុលា ឧតុមត្តក្ខា វនេ នាថំ អបស្សន្តី ។

១ ម. និឡ្លលីនសកុណី ។

យក្សស៊ីខ្ញុំដោយហេតុណា ហេតុនេះ មិនមែនជាទុក្ខនៃខ្ញុំទេ
តែព្រះហឫទ័យ នៃអយ្យបុត្ត របស់ខ្ញុំ នៅជាប្រការដទៃ
(ប្រែប្រួល) ដោយហេតុណា ហេតុនោះ (ទើបជាទុក្ខនៃខ្ញុំ) ។

មិនមានពួកទេវតា នៅប្រចាំប្រទេសដោយពិត ពពួកទេវតា
អ្នករក្សាលោក ក្នុងលោកនេះ ក៏មិនមានដោយពិត ទេវតា
ទាំងឡាយ អ្នកហាមឃាត់ ពួកជនជាអ្នកមិនសង្រួម ជាអ្នក
ធ្វើដោយការកំហែង ក៏មិនមានដោយពិត ។

(៤៣៨) (សក្កៈ...) ស្ត្រីនេះជាស្ត្រីមានយស ជាស្ត្រីប្រសើរជាងស្ត្រី
ទាំងឡាយ ជាស្ត្រីស្ងប់ស្ងៀម មានតេជៈហាក់ដូចភ្លើង មានរស្មី
ផ្សាយរុងរឿងដូចជាភ្លើង បើអ្នកឯងស៊ីនាងកញ្ញានោះ ក្បាលអ្នកឯង
នឹងបែកជា ៧ ភាគមិនខាន អ្នកឯងកុំដុត(នូវនាងសម្ពុលា)
អ្នកឯងចូរលែងនាងទៅ ព្រោះនាងជាស្ត្រីគោរពប្តី ។

(៤៣៩) (អភិសម្ពុទ្ធគាថា) នាងសម្ពុលារួចអំពីបុរិសាទ បានត្រឡប់
មកកាន់អាស្រមវិញ ដូចជាមេបក្សីនៃកន្ទ្រកកូន ហើយមកកាន់ទ្រនំ
ឬដូចជាមេគោ មកកាន់លំនៅ (ដែលមានកូនទៅបាត់ហើយ) ។
ព្រះរាជបុត្រីនោះ ជាស្ត្រីមានយស ព្រះនាមសម្ពុលា មានភ្នែក
ស្រទន់ ព្រោះរដូវ កាលមិនឃើញព្រះស្វាមី ជាទីពឹង ក្នុង
ព្រៃហើយ ក៏ទ្រង់ព្រះកន្សែង ក្បែរអាស្រមនោះជា

សមណព្រាហ្មណេ វន្ទេ សម្បន្នចរណេ ឥសេ

រាជបុត្តំ អបស្សន្តី ទុក្ខិតា សរណំ គតា ។

វន្ទេ សីហេ ច ព្យគ្ឃេ ច យេ ច អញ្ញេ វនេ មិគា

រាជបុត្តំ អបស្សន្តី ទុក្ខិតា សរណំ គតា ។

តិណលតានិ ឱសធ្យោ បព្វតានិ វនានិ ច

រាជបុត្តំ អបស្សន្តី ទុក្ខិតា សរណំ គតា ។

វន្ទេ ឥន្ទីវរីសាមំ រត្តិំ នក្ខត្តមាលិនិំ[១]

រាជបុត្តំ អបស្សន្តី ទុក្ខិតា សរណំ គតា ។

វន្ទេ ភាគីរសិំ គង្គំ សវន្តីនំ ឧទក្កហំ

រាជបុត្តំ អបស្សន្តី ទុក្ខិតា សរណំ គតា ។

វន្ទេ អហំ បព្វតរាជ- (សេដ្ឋំ) ហិមវន្តំ សិលុច្ចយំ

រាជបុត្តំ អបស្សន្តី ទុក្ខិតា សរណំ គតា ។

[៥៤០] អតិសាយំ វតាគច្ឆិ រាជបុត្តិ យសស្សិនិ

កេន អជ្ជ សមាគច្ឆិ កោ តេ បិយតរោ មយា ។

---

១ ម. រត្តិន្នក្ខត្តមាលិនី ។

ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំពួកសមណព្រាហ្មណ៍ដ៏មានសីលជាទីពឹង ដែលមានការប្រព្រឹត្តិបរិបូណ៌ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវពួកសីហៈ ខ្លាធំ និងពួកម្រឹគដទៃ ក្នុងព្រៃ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំ ស្មៅ វល្លិ ឈើជាឱសថ ភ្នំ និងព្រៃជាទីពឹង ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវរបៀបផ្កាយក្នុងរាត្រី ដែលមានពណ៌ដូចផ្កាឈូកខៀវ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវស្ទឹងឈ្មោះភាគីរសី ជាទីទទួលនូវស្ទឹងទាំងឡាយដែលហូរមក ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវភ្នំហិមពាន្ត ជាស្តេចភ្នំដ៏ប្រសើរ ខ្ញុំសូមដល់នូវលោកជាទីពឹង ។

[៥៤០] (វេស្សន្តរ...) រាជបុត្រី ជាស្ត្រីមានយស មកក្នុងវេលាល្ងាចពេក តើថ្ងៃនេះ នាងមកប្រទះនឹងអ្នកណាហ្ន៎ អ្នកណា ជាទីស្រឡាញ់ របស់នាង ជាងខ្ញុំ ។

(៤៦១) ឥទំ ខោ ហំ ឥធាកដំ គហិតា តេន សត្តុនា
ន មេ ឥទំ តថា ទុក្ខំ យំ មំ ខាទេយ្យ រក្ខសោ
យញ្ច មេ អយ្យបុត្តស្ស មនោ ហេស្សតិ អញ្ញថា ។
(៤៦២) ចោរីនំ ពហុពុទ្ធិនំ យាសុ សច្ចំ សុទុល្លភំ
ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ ។
(៤៦៣) តថា មំ សច្ចំ បាលេតុ បាលយិស្សតិ ចេ មមំ
យថាហំ នាភិជានាមិ អញ្ញំ បិយតរំ តយា
ឯតេន សច្ចវជ្ជេន ព្យាធិ តេ វូបសម្មតុ ។
(៤៦៤) យេ កុញ្ជរា សត្តសតា ឧឡារា
រក្ខន្តិ រត្តិន្ទិវមុយ្យតាវុធា
ធនុគ្គហានញ្ច សតានិ សោឡស
កថំ ដេ បស្សសិ ភទ្ទេ សត្តវេ ។
(៤៦៥) អលង្កតាយោ បទុមុត្តរត្តចា
វិរោចិតា បស្សតិ ហំសគគ្គរា

(៤៦១) (នាងសម្ពុលា...) ខ្ញុំម្ចាស់ដែលសត្រូវនោះចាប់បាន ក៏បានពោល
ពាក្យនេះថា យក្សទំពាស៊ីខ្ញុំម្ចាស់ដោយហេតុណា ហេតុនោះមិនមែន
ជាទុក្ខនៃខ្ញុំម្ចាស់ទេ ក្រែងតែព្រះហឫទ័យព្រះអយ្យបុត្ររបស់ខ្ញុំម្ចាស់ទៅ
ជាបការៈដទៃ ដោយហេតុណា ហេតុនោះ (ទើបជាទុក្ខនៃខ្ញុំម្ចាស់) ។
(៤៦២) (សោត្ថិសេន...) ពាក្យសច្ចៈ គឺពួកស្រីចោរ មានចោរយ៉ាងច្រើន
គេរកបានដោយក្រលំបាក ភាពដ៏ប្លុកនារយោចរបស់ស្ត្រីទាំងឡាយ
គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។
(៤៦៣) (នាងសម្ពុលា...) ខ្ញុំម្ចាស់ មិនធ្លាប់ស្គាល់ឡើយបុគ្គលដទៃជាទី
ស្រឡាញ់ជាងព្រះអង្គយ៉ាងណា តើ(ដំណើរ) របស់ខ្ញុំម្ចាស់(នោះ)
ជាសច្ចៈ យ៉ាងនោះ សូមសច្ចៈ រក្សាព្រះអង្គជាងរក្សាខ្ញុំម្ចាស់
ដោយពាក្យសច្ចៈនេះ សូមព្យាធិរបស់ព្រះអង្គស្ងប់រម្ងាប់ ។
(៤៦៤) (តាបស...) ដំរីទាំងឡាយច្រើនប្រមាណ៧០០ ពានសារ
ដែលរយោធាប្រុងប្រយ័ត្ន ទាំងពួកកាន់ធ្នូមួយពាន់ប្រាំមួយ
រយ ក៏នឹងរក្សាទាំងយប់ទាំងថ្ងៃ ម្នាលនាងដ៏ចំរើន តើ
នាងនៅឃើញពួកសត្រូវ ដូចម្តេច ។
(៤៦៥) (នាងសម្ពុលា...) ស្វាមី ឃើញពួកស្ត្រី ដែល
តាក់តែងកាយ មានសម្បុរល្អ ដូចស្រទាប់
ផ្កាឈូក មានចង្កេះរៀវ មានសំឡេងដូចហង្ស

តាសំ សុណិត្វា មំ គតំ គណិតំ
ឧណ្ណាមិ មេ តាត តថា យថា បុរេ ។
សុវណ្ណសង្កច្ចធរា សុវិគ្គហា
អលង្កតា មានុសិយច្ឆរូបមា
សេនោបិយា តាត អនិន្ទិតង្គិយោ
ខត្តិយកញ្ញា បដិលោភយន្តិ នំ ។
សចេ អហំ តាត តថា យថា បុរេ
បតី តមុញ្ញាយ បុនា វជេ គរេ
សម្មានយេ មំ ន ច មំ វិមានយេ
ឥតោបិ មេ តាត តតោ វរំ សិយា ។
យមន្នបានេ វិបុលស្មិំ ឱហិតេ
នារី វិមដ្ឋាភរណា អលង្កតា
សព្វង្គុបេតា[១] បតិនោ ច អប្បិយា
អវជ្ឈ គលស្មិ មរណំ តតោ វរំ ។

១ ឱ. បព្វុបេតា ។

ទ្រង់ព្រះសណ្ដាប់នូវសម្ដីនិន្ទានិងប្រមាថដែលពួកគេពោល របស់ពួកស្រីទាំងនោះ បពិត្រព្រះបិតា ដរាបនេះ ព្រះស្វាមីរបស់ខ្ញុំម្ចាស់ មិនប្រព្រឹត្តដូចកាលមុន យ៉ាងនោះទេ ។ បពិត្រព្រះបិតា ពួកស្រីមានរូបល្អ ទ្រទ្រង់នូវប្រដាប់សម្រាប់កដែលធ្វើអំពីមាស តាក់តែងខ្លួន ជាស្រីមនុស្ស ដូចស្រីទេពអប្សរ ជាទីស្រឡាញ់នៃព្រះរាជាព្រះនាម សេនៈ ជាស្រីមានអង្គកាយ គេរៀលមិនបាន ជាខត្តិយកញ្ញា តែងប្រលោមព្រះរាជានោះ ។ បពិត្រព្រះបិតា ប្រសិនបើខ្ញុំម្ចាស់បំពេញព្រះស្វាមីនោះ ដោយការស្វែងរកផ្លែផ្កាឈើក្នុងព្រៃ ដូចក្នុងកាលមុនយ៉ាងនោះទៀត ព្រះស្វាមីគប្បីរាប់អានខ្ញុំម្ចាស់ ទាំងមិនមើលងាយខ្ញុំម្ចាស់ទេ បពិត្រព្រះបិតា ព្រោះហេតុនោះ (ព្រៃ) របស់ខ្ញុំម្ចាស់ (នោះឯង) ប្រសើរជាងរាជសម្បត្តិ ក្នុងក្រុងពារាណសីនេះ ។ នារីណា (កើតក្នុងផ្ទះត្រកូល) មានបាយនឹងទឹកបរិបូណ៌ ដែលគេតាក់តែងហើយ ជាស្រីមានគ្រឿងប្រដាប់ដ៏ស្អាតវិសេស តាក់តែងខ្លួនប្រកបដោយអង្គគ្រប់យ៉ាង តែមិនជាទីស្រឡាញ់របស់ប្ដី ចងសំឡាប់ (ខ្លួន) ហើយ សេចក្ដីស្លាប់របស់នារីនោះប្រសើរជាងការរស់នៅ ដោយការសានោះ ទៅទៀត ។

អហំ ចេ ទលិទ្ទា កបណា អនាឡ្ហិយា
កដាចុតិយា បតិតោ ច សា បិយា
សព្វត្ថុបេតាយបិ អប្បិយាយ
អយមេវ សេយ្យោ កបណាបិ យា បិយា ។

(៤៦៦) សុទុល្លភិត្ថី បុរិសស្ស យា ហិតា
ភត្តិត្ថិយា ទុល្លភោ យោ ហិតោ ច
ហិតា ច តេ សីលវតី ច ភរិយា
ជនិន្ទ ធម្មំ ចរ សម្ពុលាយ ។

(៤៦៧) សចេ ត្វំ វិបុលេ លទ្ធភោគេ
ឥស្សាវតិណ្ណា មរណំ ឧបេសិ
អហញ្ច តេ ភទ្ទេ ឥមា ច កញ្ញា
សព្វេ តេ វចនករា ភវាម ។

សម្ពុលាជាតកំ នវមំ ។

គណ្ឌុតិណ្ឌុកជាតកំ

(៤៦៨) អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។

បើស្ត្រីណា ទាល់ក្រ កំព្រា មិនមានបុរសគាំទ្រ មានតែការខ្វល់ជាទីបំផុត តែស្ត្រីនោះជាទីស្រឡាញ់របស់ប្តី ស្ត្រីណានោះកំព្រា តែជាទីស្រឡាញ់(របស់ប្តី) ស្ត្រីនោះឯងប្រសើរ ជាងស្ត្រីដែលប្រកបដោយគ្រឿងគ្រប់យ៉ាង ដែលមិនជាទីស្រឡាញ់ (របស់ប្តី) ។

(៤៦៦) (គាថាស...) ស្ត្រីណាជាគុណរបស់បុរស ស្ត្រីនោះរកបានក្រក្រៃលែង ភស្តាណាជាគុណរបស់ស្ត្រី ភស្តានោះរកបានដោយក្រ ម្នាលព្រះអង្គជាធំផែនដី ភរិយារបស់អ្នក ជាគុណ (នៃអ្នក) ផង ជាស្ត្រីមានសីលផង អ្នកចូរប្រព្រឹត្តធម៌ចំពោះនាងសម្ពុលា ។

(៤៦៧) (ព្រះរាជាសោត្ថិសេន...) ម្នាលនាងសម្ពុលា នាងបានភោគៈបានហើយដ៏ច្រើន បើនាងទ្រាំមិនបាននូវសេចក្តីច្រណែន ដល់នូវមរណៈ អញនឹងពួកកញ្ញាទាំងអស់ របស់នាងនេះ នឹងធ្វើតាមពាក្យរបស់នាង ។

ចប់ សម្ពុលាជាតក ទី ៩ ។

គណ្ឌុតិណ្ឌុកជាតក

(៤៦៨) (គណ្ឌុតិណ្ឌុកទេវតាពោលសូត្រពោលថា) សេចក្តីមិនប្រមាទ ជាផ្លូវនាំឲ្យដល់នូវព្រះនិព្វានឈ្មោះអមតៈ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រមាទ ឈ្មោះថា មិនស្លាប់ ពួកជនណា ជាអ្នកប្រមាទ ពួកជននោះដូចជាស្លាប់ហើយ ។

មទា បមាទោ ជាយេថ បមាទា ជាយតេ ខយោ
ខយា បទោសា ជាយន្តិ មា មទោ ភរតូសភ ។
ពហូ ហិ ខត្តិយា ជិតា អត្ថំ រដ្ឋំ បមាទិនោ
អថោបិ គាមិនោ គាមា អនាគារា អគារិនោ ។
ខត្តិយស្ស បមត្តស្ស រដ្ឋស្មឹ រដ្ឋវឌ្ឍន
សព្វេ ភោគា វិនស្សន្តិ រញ្ញោ តំ វុច្ចតេ អឃំ ។
នេស ធម្មោ មហារាជ អតិវេលំ បមជ្ជសិ
ឥទ្ធំ ផីតំ ជនបទំ ចោរា វិទ្ធំសយន្តិ នំ ។
ន តេ បុត្តា ភវិស្សន្តិ ន ហិរញ្ញំ ន ធានិយំ
រដ្ឋេ វិលុម្បមានម្ហិ សព្វភោគេហិ ជិយ្យសិ ។
សព្វភោគបរិជិណ្ណំ រាជានំ វាបិ ខត្តិយំ
ញាតិមិត្តា សុហជ្ជា ច ន តំ មញ្ញន្តិ មន្តិយំ(១) ។

១ ម. ធានិយំ ។ ឱ. វត្តិយំ ។

សេចក្តីប្រមាទ រមែងកើតឡើង ព្រោះសេចក្តីស្រវឹង ការអស់ទៅ (នៃញាតិជាដើម) រមែងកើតឡើង ព្រោះសេចក្តីប្រមាទ សេចក្តីប្រទូស្តទាំងឡាយ រមែងកើតឡើង ព្រោះការអស់ទៅ (នៃញាតិជាដើម) បពិត្រព្រះអង្គដ៏ប្រសើរ ជាងភរតៈ (ក្នុងដែន) ព្រះអង្គកុំប្រមាទឡើយ ។ ពួកក្សត្រិយ៍ច្រើនអង្គ មានសេចក្តីប្រមាទ ញុំាងសេចក្តីចំរើនគឺញុំាងដែនឲ្យវិនាស ចំណែកពួកមេស្រុក អ្នកស្រុក អ្នកបួស ត្រូវហស្ត វិនាស ។ បពិត្រព្រះរាជា ព្រះអង្គញុំាងដែនឲ្យចំរើន ភោគៈទាំងអស់ក្នុងដែនរបស់ក្សត្រជាអ្នកប្រមាទ រមែងវិនាស សេចក្តីវិនាសនោះ ជាទុក្ខរបស់ព្រះរាជា ។ បពិត្រមហារាជ សេចក្តីប្រមាទនេះ មិនមែនជាធម៌ (របស់ពួកព្រះរាជាបុរាណទេ) ព្រះអង្គប្រមាទហួសប្រមាណ ពួកចោរកំចាត់នូវជនបទដែលសម្បូណ៌ថ្កុំថ្កើងនោះ ។ ពួកបុត្ររបស់ព្រះអង្គមិនមាន ទាំងប្រាក់ក៏មិនមាន ទាំងទ្រព្យក៏មិនមាន កាលបើចោរប្លន់ក្រុង (យ៉ាងនេះ) ព្រះអង្គនឹងសាបសូន្យចាកភោគៈគ្រប់យ៉ាង ។ ពួកញាតិមិត្រនឹងសំឡាញ់ រមែងមិនទទួលដឹង នូវក្សត្រនោះ ដែលជាព្រះរាជាសាបសូន្យចាកភោគៈទាំងពួង ជាបុគ្គលដែលគួរទទួលដឹងទេ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
តមេវត្ថុបជីវន្តា ន តំ មញ្ញន្តិ មន្តិយំ ។
អសំវិហិតកម្មន្តំ ពាលំ ទុម្មន្តិមន្តិនំ
សិរី ជហតិ ទុម្មេធំ ជិណ្ណំវ ឧរគោ តចំ ។
សុសំវិហិតកម្មន្តំ កាលុដ្ឋាយឹ អតន្ទិតំ
សព្វេ ភោគាភិវឌ្ឍន្តិ គាវោ សឧសភាមិវ ។
ឧបស្សុតិំ មហារាជ រដ្ឋេ ជនបទេ ចរ
តត្ថ ទិស្វា ច សុត្វា ច តតោ តំ បដិបជ្ជសិ ។

(៨៤៩) ឯវំ វេទេតុ បញ្ចាលោ សង្គាមេ សរមប្បិតោ
យថាហមជ្ជ វេទេមិ កណ្ដកេន សមប្បិតោ ។

(៨៥០) ជិណ្ណោ ទុព្ពលចក្ខុសិ ន រូបំ សាធុ បស្សសិ
កឹ តត្ថ ព្រហ្មទត្តស្ស យំ មំ មគ្គេយ្យ កណ្ដកោ ។

ពួកពលដំរី ពួកសេនា ពលរថ ពលថ្មើរជើងនឹងពួកកម្មករ ដែលអាស្រ័យចិញ្ចឹមជីវិតនឹងព្រះរាជានោះឯង ក៏មិនទទួលដឹងនូវព្រះរាជាដែលគួរទទួលដឹងនោះ ។ សិរីនិយសសម្បត្តិ រមែងលះបង់នូវបុគ្គលពាល អ្នកមិនចាត់ចែងនូវការងារ មានគំនិតអាក្រក់ គាប់ឥតប្រាជ្ញ ដូចជាពស់លះបង់នូវសំណកចាស់ ។ ភោគៈទាំងអស់ រមែងចំរើនដល់បុគ្គលអ្នកចាត់ចែងការងារដោយល្អ ក្រោកឡើងតាមកាល ជាអ្នកមិនខ្ជិលច្រអូស ដូចជាគោប្រព្រឹត្តទៅមួយអន្លើដោយគោឧសភ ។ បពិត្រមហារាជ សូមព្រះអង្គយាងទៅកាន់ទីជាទីចាំស្ដាប់ ក្នុងជនបទ ក្នុងដែន លុះទតឃើញនិងទ្រង់ព្រះសណ្ដាប់ ក្នុងដែននោះហើយ ក៏យកការណ៍ តាមរាជកិច្ចនោះ តាមដំណើរនោះ ។

(៨៤៩) (បុរសចាស់ពោលថា) ខ្ញុំអញត្រូវបន្លាមុតហើយ រងវេទនា ក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យព្រះបាទបញ្ចាល ត្រូវសរក្នុងសង្គ្រាម ហើយរងវេទនាយ៉ាងនេះដែរ ។

(៨៥០) (បុរោហិតពោលថា) អ្នកជាមនុស្សចាស់ មានភ្នែកទុព្វល មើលរូបមិនឃើញដោយស្រួលទេ បន្លាមុតអ្នកឯង ដោយហេតុណា (ទោស) របស់ព្រះបាទព្រហ្មទត្តចំពោះហេតុនោះ តើដូចម្ដេច ។

(៨៨១) តហេតុ ព្រហ្មទត្តស្ស យោហំ(១) មគ្គស្មិ ព្រាហ្មណោ

អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា

រដ្ឋស្មិំ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។

ឯតាទិសេ ភយេ ជាតេ ភយដ្ដា តាត មាណវា

និល្លេនកានិ កុព្ពន្តិ វនេ អាហត្វ(២) កណ្ដកំ ។

(៨៨២) កទាស្សុ នាមយំ ភត្តា ព្រហ្មទត្តោ មរិស្សតិ

យស្ស រដ្ឋស្មិំ ជិយ្យន្តិ អប្បតិកា កុមារិកា ។

(៨៨៣) ទុព្ភាសិតញ្ហិ តេ ជម្មិ អនត្ថបទកោវិទេ

កុហឹ ភត្តា កុមារីនំ កត្តារំ បរិយេសសិ ។

(៨៨៤) ន មេ ទុព្ភាសិតំ ព្រហ្មេ កោវិទត្ថបទា អហំ

អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

---

១ អដ្ឋកថាយំ បន សោហំ បាឋោ ទិស្សតិ ។ ២ ម. អាហត្វា ។

(៨៨១) (បុរសចាស់...) ម្នាលព្រាហ្មណ៍ គឺដោយទោសរបស់ព្រះរាជាព្រហ្មទត្ត ជនច្រើន(បានជា)ខ្ញុំនោះ (ឮក) ក៏ផ្សាំ(មានបន្លា) ព្រោះពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយពលិកម្ម (សួយសារអាករ) មិនប្រកបដោយធម៌ ។ ក៏វេលាយប់ ពួកចោរស៊ី(ប្លន់) ក៏វេលាថ្ងៃ ពួកអ្នកគរជនការ បៀតបៀនស៊ី ក៏ដែនរបស់ព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌ មានច្រើន ។ ម្នាលអ្នក កាលបើភ័យបែបនេះ កើតឡើង មនុស្សទាំងឡាយ ដែលត្រូវភ័យគ្របសង្កត់ ក៏នាំយកបន្លាក្នុងព្រៃ មកធ្វើជាទីសម្រាប់ពឹងពួន ។

(៨៨២) (ស្រីទុគ៌តម្នាក់ ថាថា) ពួកកុមារី ជាស្រីគ្មានប្ដី ហួសចាស់ ក៏ដែននៃព្រះរាជាព្រហ្មទត្តណា កាលណាហ្ន៎ ព្រះរាជាព្រហ្មទត្តនេះ នឹងស្លាប់ទៅ ។

(៨៨៣) (បុរសពិតយាត់ថា) នែនាងលាមក ជាស្រីមិនឈ្លាស ក៏ឆ្ងាយនៃសេចក្ដីចំរើន ពាក្យនាង ជាពាក្យអាក្រក់ ព្រះរាជានឹងស្វែងរកប្ដីឲ្យពួកនាងកុមារី ក៏ពីណា ។

(៨៨៤) (ស្រីចាស់...) នែព្រាហ្មណ៍ ពាក្យរបស់ខ្ញុំមិនអាក្រក់ទេ ខ្ញុំជាស្រីឈ្លាសវៃ ក៏នាំចំរើន ព្រោះពួកអ្នកជនបទ ស្ដេចមិនរក្សា ទ្រង់បៀតបៀន ដោយសារសួយអាករ មិនប្រកបដោយធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ   ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មិំ កូដរាជស្ស   ពហុ អធម្មិកោ ជនោ
តាទិសេ វត្តមានេ   កុតោ កត្វា កុមារិយា ។

(៤៨៥) ឥមំ សយន្តុ បញ្ចាលោ សត្តិមេ សត្តិយា ហតោ
យថាយំ កបណោ សេតិ ហតោ ជាលេន សាលិយោ ។

(៤៨៦) អនានុមេន តុវំ ជម្ម ព្រហ្មទត្តស្ស កុជ្ឈសិ
យោ តំ សបសិ ភជាតិ អបាបវិត្វាន អត្តនោ ។

(៤៨៧) ធម្មេន ព្រហ្មទត្តស្ស អហំ កុជ្ឈាមិ ព្រាហ្មណ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិញ្ហិ ចោរា ខាទន្តិ   ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មិំ កូដរាជស្ស   ពហុ អធម្មិកោ ជនោ ។
សា នូន បុន រេ បក្កា វិកាលេ ភត្តមាហរិ
ភត្តហារី អបេក្ខន្តី ហតោ ជាលេន សាលិយោ ។

គ្រប់វេលាយប់ ពួកចោរស៊ី (ប្លន់) គ្រប់វេលាថ្ងៃ ពួកអ្នកយកពន្ធដាររៀករៀនស៊ី គ្រប់ដែនព្រះរាជាខ្លួនកាច ជនមិនប្រកបដោយធម៌មានច្រើន កាលបើក្រុងរស់នៅដោយលំបាក ចិញ្ចឹមប្រពន្ធកូនដោយលំបាក តើពួកនាងកុមារីបានខ្ចីអំពីណា ។

(៤៨៥) (អ្នកក្រមេរ៉ង់) ចោរឈ្មោះសាលិយៈនេះ ត្រូវគេសម្លាប់ហើយ ដេកស្រេកយ៉ាងណា សូមឲ្យព្រះរាជា ក្រុងបញ្ចាល ត្រូវសម្លាប់ដោយលំពែងក្នុងសង្គ្រាម ដេកយ៉ាងនោះចុះ ។

(៤៨៦) (ព្រាហ្មណ៍...) នែបុរសលាមក អ្នកណាខុសខ្លួនឯង ហើយផ្តាសាព្រះរាជា អ្នក(នោះ) ឈ្មោះថាខឹងចំពោះព្រះរាជាព្រហ្មទត្តដោយហេតុមិនត្រូវតាមធម៌ទេ ។

(៤៨៧) (អ្នកក្រ...) ម្នាលព្រាហ្មណ៍ ខ្ញុំខឹងចំពោះព្រះរាជាព្រហ្មទត្តដោយហេតុត្រឹមត្រូវតាមធម៌ (ព្រោះថា) ពួកអ្នកជនបទ ស្តេចមិនរក្សា ត្រូវគេបៀតបៀនដោយស្អុយសារពើពន្ធ មិនប្រកបដោយធម៌ ។ គ្រប់វេលាយប់ ពួកចោរស៊ី គ្រប់វេលាថ្ងៃ ពួកអ្នកយកពន្ធដាររៀករៀនស៊ី គ្រប់ដែនព្រះរាជាខ្លួនកាច ជនមិនប្រកបដោយធម៌មានច្រើន ។ ស្រីជាអ្នកនាំបាយមកនោះ ប្រាកដជាដាំម្តងទៀត បានជានាំបាយមកក្នុងវេលាល្ងាចរសៀល ខ្ញុំក៏កុងរកមើលនូវស្រីអ្នកនាំបាយមក ចោរឈ្មោះសាលិយៈ ក៏ត្រូវគេសម្លាប់ ។

(៨៥៨) យំ វិហារញ្ញាតុ បញ្ចាលោ សត្តាហ អសិតា ហតោ
យថាហាបដ្ឋ ឋបាហតោ ទីរញ្ញ មេ បវត្តិតំ ។

(៨៥៩) យំ ឧសុ ទិរិ ឧទ្ទេតិ ឧសុ ជាលំ វិហីសតិ
កិំ គន្ធ ព្រហ្មទត្តស្ស យំ នោ ករហាមេ កវិ ។

(៨៦០) តារយ្យោ ព្រហ្មេ បញ្ចាលោ ព្រហ្មទត្តស្ស កងិនោ
អរក្ខិតា ជានបទា អជ្ឈគលិតា ហតា ។
វត្តិញ្ចិ ហោក មានន្តិ ធិត មានន្តិ ឝុណ្ណិយា
វេដ្ឋស្មិ ក្ជេកជស្ស ពហុ អជម្មិតោ ជនោ ។
ចណ្ឌា អកាឡនា តាវី យំ ពុរេ ន ឧបាមរេស
តំពាធិ អជ្ជ នោហាម ទីរតាមេហុបឆុតា ។

(៨៦១) យំ កន្ទតុ បញ្ចាលោ វិមុត្តោ វិប្បវុត្តតុ
យថាយំ កបណា តាវី វិមុត្តោ បរិតាវតិ ។

(៨៥៨) (អ្នកត្រូវទឹកដោះជាហេតុ) ក្នុងថ្ងៃនេះ ខ្ញុំអញ្ចេញ (ត្រូវបោះតា) បាក់ចាំងទឹកដោះរបស់គញ្ញាំគប់ទៅយ៉ាងណា សូមឲ្យព្រះរាជាបញ្ចាល-ឥសរ ត្រូវគេសំឡាប់ដោយដាវក្នុងសង្គ្រាម វិនាសយ៉ាងនោះចុះ ។

(៨៥៩) (បុរោហិត...) សត្វចិញ្ចឹមនេះ ចាក់ចោលនូវទឹកដោះ សត្វចិញ្ចឹមបៀតបៀនគូរ៉ាល អ្នកជិះរថីធំបៀតបៀនយើង ដោយហេតុណា កំហុសដូចម្តេច របស់ព្រះរាជាព្រហ្មទត្តក្នុងហេតុនោះ ។

(៨៦០) (អ្នកត្រូវទឹកដោះ...) ម្នាលព្រាហ្មណ៍ ព្រះរាជាបញ្ចាលឥសរបស់ពជព្រពួលព្រហ្មទត្ត ទុកអ្នកស្រុកបៀតបៀនហើយ ព្រោះថា ពួកអ្នកជន-បទ ព្រះរាជាមិនរក្សា ត្រូវគេបៀតបៀនដោយស្អុយតាក់ មិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នកកាំ-ការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខ្ទួចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ ហេតុ ភ័យ ធំ យើងមិនបានក្រុងនូវទឹកដោះណាក្នុងកាលមុន ក្នុងថ្ងៃនេះ ដល់ថ្ងៃនេះ ពួកយើងក៏ត្រូវពួកកាជបុរសអ្នកប្រាជ្ញនូវទឹកដោះមកប្រមាំ ហើយត្រូវនូវទឹកដោះនោះ ។

(៨៦១) (ពួកក្មេងអ្នកស្រុកជាហេតុ) មេគោកំព្រា ដាសក្បាលក្បាលនេះ ស្រែកទ្រហ៊ោ យ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលឥសរ ព្រាត់ប្រាសចាកស ចិត្តវិតក្នុង កន្ទក់កន្ទេញ យ៉ាងនោះចុះ ។

(៨៦២) យំ បសុ បសុតាលស្ស សម្ពេយ្យ រេយ្យ ក

គោចិន អបកច្ចិ ព្រហ្មទត្តស្ស កដិតោ ។

(៨៦៣) អបភាតោ មហាព្រហ្មា ព្រហ្មទត្តស្ស កដិតោ

អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា

រដ្ឋស្មិំ កូដរាជស្ស ពហុ អធម្មិកោ ជនោ

តាទិសេ អសេ កោសក្ខា ទីវតា តាញ្ញាកេ ខជា ។

(៨៦៤) បរិ ទដ្ឋកុ បញ្ចាលោ ហតោ យុទ្ធេ សត្តុកោ

យថាហមជ្ជ ទជ្ជាមិ តាមិកោហិ អញ្ញជោ ។

(៨៦៥) ន សព្វភូតេសុ វិធន្តិ រក្ខំ

រាជានោ មណ្ឌូក មនុស្សលោកេ

នេត្តាវតា រាជា អធម្មចារី

យំ តាទិសំ ជីវមេយ្យ ធង្ក្ខា ។

(៨៦២) (បុរោហិត ..) សត្វចិញ្ចឹម របស់អ្នកស្រុកនូវសត្វចិញ្ចឹម ស្ទះ ធ្វេតុក្តី ស្រែកក្តី ដោយហេតុណា កំហុសដូចម្តេច របស់ព្រះរាជា ព្រហ្មទត្ត ក្នុងហេតុនេះ ។

(៨៦៣) (ក្អែកនឹងអ្នកស្រុក...) មហាព្រហ្មតាព្រាហ្មណ៍ កំហុសរបស់ ព្រះរាជាព្រហ្មទត្ត (មានតិច) ព្រោះថា ពួកអ្នកជនបទ ព្រះរាជា មិនរក្សា ទុកឲ្យគេបៀតបៀនដោយសួយសារអាករ មិនប្រកបដោយ ធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នកជនការ បៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌ មានច្រើន រាំកុដូចម្តេចហ្នឹង ពួកយោយរបស់យើងក៏ក្នុងព្រៃដេរ ខាន ប្រយោជន៍ដល់គ្រោមនាំ ត្រូវកត់ទុកសំឡាប់ ។

(៨៦៤) (ក្អែកបាដេរ) អញជាសត្វកើតក្នុងព្រៃ ត្រូវពួកឈ្លើកក្នុងស្រុក ចិកស៊ីក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យស្តេចបញ្ចាលនោះ ព្រមទាំង បុត្រត្រូវគេកាប់ក្នុងចម្បាំងដាច់ខ្ទេចខ្ទី យ៉ាងនោះចុះ ។

(៨៦៥) (បុរោហិត...) នែកន្ថែប ព្រះរាជាទាំងឡាយ ក្នុងមនុស្ស- លោក មិនបានកែចែងនូវការរក្សាក្នុងពួកសត្វទាំងពួងទេ ក្អែកក្អែក ស៊ីនូវសត្វទាំងរស់ដូចជាឯង ដោយហេតុណា ព្រះរាជាមិន ឈ្មោះថាមិនប្រព្រឹត្តធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

(៤៦៦) អជេយ្យោ ឯស ព្រហ្មចារី

អនុប្បិយំ ភាសតិ ទក្ខិណេយ្យោ

វិលុម្បមានាយ បុថុប្បជាយ

ថូដេសិ ភត្តំ បរមប្បកម្បិ ។

សាធុ ឥទំ ព្រហ្ម សុភាសិតំ សិយា

ឧទិតំ រដ្ឋំ ឧមិតំ វិប្បសន្នំ

កុត្វា ពលី អត្តបិណ្ឌញ្ច ភាកា

ន មានិសំ ជីវិតហេយ្យ ធត្តាតិ ។

គណ្ឌតិណ្ឌុកជាតកំ ទសមំ ។

តស្សុទ្ទានំ

កិំឆន្ទ កុម្ភ ជយទ្ទិស ឆទ្ទន្ត

អថ បណ្ឌិតសម្ភវ សេរកបិ

ទករក្ខស បណ្ឌរនាគវរោ

អថ សម្ពុល តិណ្ឌុកទេវសុតោ ។

តិំសនិបាតំ និដ្ឋិតំ ។

(៤៦៦) (តន្ទីប...) អ្នកជាព្រហ្មចារី នៃមានសេចក្តីមិនប្រែប្រួល គឺមិនសាវ ពោលនូវពាក្យសារសើរ ចំពោះពួកប្រជា កាល ហើយប្រជាជនជាច្រើន ដែលព្រះរាជាបៀតបៀន អ្នកនៅតែចូល ចំពោះព្រះរាជា ជាអ្នកមានកិច្ចៈដ៏ក្រៃលែង ។ នៃព្រាហ្មណ៍ ប្រសិនបើ ដែនរដ្ឋមានអ្នកដឹកនាំល្អ ទើបដីជាដែនសុខក្សេម មានស្រីកាយជ្រះថ្លា ពាំងពួកក្អែកស៊ីនូវដុំបាយដ៏ប្រសើរ ជាគ្រឿងបួងសួង (របស់មនុស្ស) ពួកក្អែកមិនគប្បីស៊ីសត្វពាហនៈ ដោយគ្រោះថ្នាក់ជាប្រាំ ។

ចប់ គណ្ឌតិណ្ឌុកជាតក ទី ១០ ។

ឧទ្ទាននៃតិំសនិបាតនោះគឺ

និយាយអំពីកិំឆន្ទជាតក ១ កុម្ភជាតក ១ ជយទ្ទិសជាតក ១

ឆទ្ទន្តជាតក ១ សម្ភវជាតក ១ មហាកបិជាតក ១

ទករក្ខសជាតក ១ នាគដ៏ប្រសើរឈ្មោះ បណ្ឌរកៈ ១

សម្ពុលាជាតក ១ តិណ្ឌុកជាតក ១ ។

ចប់ តិំសនិបាត ។

ចត្តាលីសនិបាតជាតកំ

តេសកុណជាតកំ

(៨៦៧) វេស្សន្តរំ តំ បុច្ឆាមិ សកុណ ភទ្ទមត្ថុ តេ

រជ្ជំ ការេតុកាមេន កឹសុ កិច្ចំ កតំ វរំ ។

(៨៦៨) ចិរស្សំ វត មំ តាតោ កំសោ ពារាណសិគ្គហោ

បមត្តោ អប្បមត្តំ មំ បិតា បុត្តំ អចោទយិ ។

(៨៦៩) បឋមេនេវ វិតថំ កោធំ ហាសំ និវារយេ

តតោ កិច្ចានិ ការេយ្យ តំ វតំ អាហុ ខត្តិយ ។

យំ ត្វំ តាត តបោកម្មំ បុព្វេ កតមសំសយំ

រត្តោ ទុដ្ឋោ ច យំ កយិរា ន តំ កយិរា តតោ បុន ។

ចត្តាលីសនិបាតជាតក

តេសកុណជាតក

(៨៦៧) (ព្រះបាទព្រហ្មទត្តត្រាស់ថា) ម្នាលសត្វស្លាប អញសូមសួរអ្នក ឈ្មោះវេស្សន្តរៈ សេចក្តីចម្រើន ចូរមានដល់អ្នក កិច្ចដូចម្តេចដែល អញជាអ្នកប្រាថ្នា ដើម្បីសោយរាជ្យ ធ្វើហើយប្រសើរ ។

(៨៦៨) (វេស្សន្តរៈទូលថា) យូរណាស់ហើយ បិតារបស់ខ្ញុំព្រះអង្គ ព្រះនាម កំសៈ ជាអ្នកសោយរាជ្យក្នុងក្រុងពារាណសី ប្រមាទប្រហែស ជាបិតាពិតស្តីម បានដាស់ស្មារតីខ្ញុំព្រះអង្គ ជាកូនមិនប្រហែស ។

(៨៦៩) (ខ្ញុំទូលថា) មុនដំបូង ព្រះរាជាត្រូវហាមឃាត់នូវពាក្យវៀចវេរ សេចក្តីក្រោធនឹងការសើច រួចស្រេចហើយ ទើបគប្បីធ្វើនូវកិច្ច ទាំងឡាយ បពិត្រក្សត្រ បុគ្គលគប្បីធ្វើកិច្ចទាំងឡាយ ពួកបណ្ឌិតពោល នូវពាក្យដែលខ្ញុំព្រះអង្គក្រាបទូលនោះ ថាជាវត្ត ។ បពិត្រព្រះបិតា កម្មចំពោះហេតុដ៏ក្តៅក្រហាយណា ដែលព្រះអង្គធ្វើហើយ ក្នុង កាលមុន ជាសំស័យ ព្រះអង្គត្រេកត្រអាលក្តី ប្រទូស្តក្តី ធ្វើនូវកម្មណា ព្រះអង្គមិនគប្បីធ្វើ នូវកម្មនោះ តទៅទៀតទេ ។

ទត្តិយស្ស ឥមន្តស្ស   វេទស្សី វេទវិទ្ធុស

សាទ្ធិកោតា វិចស្សន្តិ   វញ្ញា តំវុច្ចតេ អយំ ។

សំវិច តាត សត្តិ ច   ធុម្ពិកា បិតាព្រហ្ម

ឧត្តរេ ភិយ្យោ ហោសេ   មោមហំ អនុសុយ្យកោ ។

ឧស្សុយ្យកោ ទុហទយោ   បុរិសោ កម្មទុស្សកោ

កាឡកណ្ណី មហារាជ   មេតំ កណ្ហកញ្ញតិ ។

សោ ត្វំ សព្វេសំ សុហទយោ សព្វេសំ រក្ខិតោ ភវ

អលក្ខី នុទ មហារាជ   លក្ខ្យា ភវ និវេសនំ ។

សលក្ខី ធីតិសម្បន្នោ   បុរិសោ ហិ មហគ្គតោ

អមិត្តានំ កាសិបតិ   មូលំ អគ្គញ្ច ឆិន្ទតិ ។

សក្កោបិ ហិ ភូតបតិ   ឧដ្ឋានេ នប្បមជ្ជតិ

សកល្យាណេ ធិតិ កត្វា   ឧដ្ឋានេ កុរុតេ មនោ ។

បពិត្រព្រះឥន្ទ្រអ្នកញុំាងក្រុងឲ្យចំរើន កាលបើក្សត្រិយ៍ ប្រហែស ហើយ គោរសម្បត្តិទាំងអស់ក្នុងផែនដី ទឹកនិងមាសទៅ សេចក្តីវិនាស នោះ លោកពោលថាជាទុក្ខ របស់ព្រះរាជា ។ បពិត្រព្រះវិធា បុគ្គលមានសិរី គឺបុគ្គលមានបុណ្យ ដែលសុចរិតមិនសន្សំសូរហើយ បានពោលពាក្យនេះថា ខ្ញុំប្រគល់ ចំពោះបុរសមានសេចក្តីខ្លាច មានសេចក្តីប្រាថ្នាថ្លៃ ជាអ្នកមិនប្រាថ្នា ។ បពិត្រមហារាជ បុគ្គលកាឡកណ្ណី ជាអ្នកចាប់ចិត្តក្នុងបំព្រើកុសល នឹងក្រោកឡើង ក្នុងបុរសជាអ្នកប្រាថ្នា មានចិត្តក្រោធ ជាអ្នកប្រទូស្តចំពោះ កល្យាណកម្ម ។ សូមព្រះអង្គ មានព្រះទ័យល្អចំពោះពួកជនទាំង ពីរ សូមព្រះអង្គ រក្សានូវពួកជនទាំងពីរ បពិត្រមហារាជ សូម ព្រះអង្គបណ្ដេញនូវបុគ្គលអតបុណ្យចេញ សូមព្រះអង្គយកបុគ្គល មានបុណ្យ មកជាទីពឹងវិញ ។ បពិត្រព្រះអង្គជាម្ចាស់ផែន ដី ព្រោះថា បុរសមានបុណ្យ ប្រកបដោយបញ្ញា តាំងនៅ ក្នុងសម្បត្តិប្រសើរ រមែងកាត់បង់នូវគល់និងចុង នៃសត្រូវទាំង ឡាយបាន ។ បពិត្រព្រះអង្គ ជាម្ចាស់នៃមនុស្ស ដូចជាព្រះ ឥន្ទ្រមិនប្រហែស ក្នុងការព្យាយាមដែរ លោកធ្វើនូវការព្យាយាម ចំពោះកម្មដ៏ល្អ តាំងចិត្តព្រះហឫទ័យ ក្នុងការព្យាយាម (ចប់ភាគ) ។

កិច្ចា ចិតកោ តេស សាធិកេ យោត្តិ តាតិយោ

ទុដ្ឋហោតោ អព្យមដ្ឋោ អនុតិដ្ឋន្តិ ទេវតា ។

សោ អប្បមត្តោ អកុទ្ធោ តាត កិច្ចានិ ការយ

ភយមស្ស សកិច្ចេសុ ឆាលសោ រិន្ទេ សុចិ ។

គតេ្តា តេ វត្ថុជា ឯសាវ អនុសាសនី

អលំ មិត្តេ សុខាបេតុំ អមិត្តានំ ទុខាយ ច ។

(៤៧០) សក្កំ នុ កុណ្ឌលិនិ មញ្ញសិ ខត្តពន្ធុនិ

រជ្ជំ ការេតុកាមេន ពិសុ ពិទ្ធុំ តាតំ ភំ ។

(៤៧១) ទ្វេវ តាត បទកានិ យត្ថ សព្វំ បតិដ្ឋិតំ

អលទ្ធស្ស ច យោ លាភោ លទ្ធស្ស ចានុរក្ខណា ។

អមច្ចេ តាត ជានាហិ ធីរេ អត្ថស្ស កោវិទេ

កូនឯង្គ កូនចិត្ត (គួរ) កូនទៅ មានសេចក្ដីព្យាយាមដ៏ក្រៃ លែង ដែលមានកំណើតក្នុងត្រកូលយ៉ាងនេះ កូនចៅតែងតាមថែ (រក្សា) នូវព្រះរាជ ជាអ្នកមិនប្រមាទ ។ បពិត្រព្រះបិតា ព្រះអង្គជាអ្នកមិនប្រមាទ មិនក្រោធ សូមធ្វើនូវកិច្ចទាំងឡាយចុះ សូមព្រះអង្គប្រើប្រែកូនកិច្ចទាំងឡាយរបស់ព្រះអង្គ បុគ្គលខ្ជិល ច្រអូស រមែងមិនបាននូវសេចក្ដីសុខទេ ។ នេះជាវត្តបទ ក្នុងបញ្ហា នោះឯង នុ៎ះឯងជាអនុសាសនី (របស់ខ្ញុំព្រះអង្គ) ព្រះរាជា គាប់ ប្រព្រឹត្តយ៉ាងនេះ ទើបអាចញុំាងពួកមិត្តឲ្យបានសុខផង អាចញុំាង ពួកសត្រូវឲ្យបានទុក្ខផង ។

(៤៧០) (ព្រះរាជា...) ត្រាស់នាងកុណ្ឌលិនី នាងអាច (ឆ្លើយប្រស្នាបាន) នាងជាកញ្ញាវែកមហាសេនាក្សត្រ* ឈ្មោះខត្តៈ ដឹង (នូវការឆ្លើយប្រស្នា) កិច្ចដូចម្ដេចដែលរាជាគួរធ្វើឲ្យប្រពៃ ក្នុងកាលដែលមកគ្រប់គ្រងរាជសម្បត្តិ ។

(៤៧១) (សារិកាឈ្មោះកុណ្ឌលិនី) បពិត្រព្រះបិតា ប្រយោជន៍នឹង សេចក្ដីសុខទាំងអស់ តាំងនៅក្នុងបទណា បទនោះមានតែពីរយ៉ាង គឺការបាននូវរបស់ ដែលមិនធ្លាប់បាន ១ ការរក្សានូវរបស់ដែលបាន មកហើយ ១ ។ បពិត្រព្រះបិតា សូមព្រះអង្គជ្រាប នូវ អាមាត្យទាំងឡាយ ដែលមានប្រាជ្ញា ឈ្លាសវៃ ក្នុងការប្រយោជន៍

---

* ក្សត្រីឈ្មោះ ម្ដាយរបស់ស្ដេច មហាសេនា ។

អនក្ខា កិតវា តាត អសោណ្ឌេ អវិនាសកេ ។

យោ ច តំ តាត រក្ខេយ្យ ធនំ យញ្ចេវ តេ សិយា

សូតោវ រថំ សង្គណ្ហេ សោ តេ កិច្ចានិ ការយេ ។

សុសង្គហិតន្តជនោ សយំ វិត្តំ អវេក្ខិយ

និធិញ្ច ឥណទានញ្ច ន ករេ បរបត្តិយា ។

សយំ អាយំ វយំ ជញ្ញា សយំ ជញ្ញា កតាកតំ

និគ្គណ្ហេ និគ្គហារហំ បគ្គណ្ហេ បគ្គហារហំ ។

សយំ ជានបទំ អត្ថំ អនុសាស រថេសភ

មា តេ អធម្មិកា យុត្តា ធនំ រដ្ឋញ្ច នាសយុំ ។

មា ច វេគេន កិច្ចានិ ការេសិ[១] ការយេសិ វា

វេគសា ហិ កតំ កម្មំ មន្ទោ បច្ឆានុតប្បតិ ។

១ ម. ករោសិ ។

បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមិនលេងល្បែងភ្នាល់ មិនបោកប្រាស់ មិនជាអ្នកលេងស៊ីផឹក មិនជាអ្នកបំផ្លាញទ្រព្យ ។ បពិត្រព្រះបិតា អាមាត្យណាគួរតែរក្សានូវទ្រព្យរបស់ព្រះអង្គ ដែលមាន ដូចនាយសារថីប្រុងប្រយ័ត្ននូវរថ អាមាត្យនោះ ព្រះអង្គគប្បីឲ្យធ្វើនូវកិច្ចការទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គ ដែលមានជនខាងក្នុងសង្គ្រោះល្អ ត្រួតត្រាមើល នូវព្រះរាជទ្រព្យដោយព្រះអង្គឯង មិនគួរធ្វើនូវកំណប់ទ្រព្យនឹងការឲ្យជាបំណុល ដោយការជឿអ្នកដទៃ ។ ព្រះអង្គគប្បីជ្រាបនូវសេចក្តីចំរើននឹងសេចក្តីវិនាស ដោយព្រះអង្គឯង គប្បីជ្រាបនូវកិច្ចការដែលបានធ្វើ នឹងមិនបានធ្វើ ដោយព្រះអង្គឯង គប្បីសង្កត់សង្កិននូវបុគ្គលដែលគួរសង្កត់សង្កិន គប្បីលើកតំកើង នូវបុគ្គលដែលគួរលើកតំកើង ។ បពិត្រព្រះអង្គ ជាធំលើរថ សូមព្រះអង្គប្រៀនប្រដៅនូវប្រយោជន៍ដល់អ្នកជនបទ ដោយព្រះអង្គឯង ពួករាជបុរសអ្នកប្រកបការមិនប្រកបដោយធម៌ សូមកុំឲ្យញ៉ាំងទ្រព្យនឹងដែន របស់ព្រះអង្គឲ្យវិនាស ។ មួយទៀត សូមព្រះអង្គកុំធ្វើ ឬប្រើគេឲ្យធ្វើនូវកិច្ចទាំងឡាយដោយរួសរាន់ ព្រោះមនុស្សល្ងង់រមែងក្តៅក្រហាយរឿយៗ ក្នុងកាលខាងក្រោយ ចំពោះការងារ ដែលខ្លួនធ្វើដោយរួសរាន់ ។

មា តេ អតិសរេ ទុក្ខ   សុខាឡ្ហមង់ គោចិតំ

គោធសា ហិ ពហូ ជីតា   កុលា អកុលតំ គតា ។

មា តាត បិស្សកេត្វាតិ   អត្តាយ បតាយិ

នត្ថិ ធុរិសាធញ្ញ   មា តេ អសិ ទុក្ខុប្រយោ ។

អបេតលោមហំសស្ស   វញ្ញា តានាធុសាគរោ

សព្វេ គោត វិនស្សន្តិ   វញ្ញា តំ វុត្តេ អយំ ។

តាតូ តេ វត្តបតា   បិសា ធុសាសធី

ឧត្តុស្សុតានិ បុញ្ញកោ   អសោណ្ណា អរិចា សរោគា

សីលវស្ស ឧយាកន   ធុស្សវ៉េលោ វិប៉ចាតិគោ ។

(៨៧៦)អធុដ្ឋិហ្វា គោសិយគោត្តិ   កុណ្ឌលធិ តាចេ ៤

ជម្មុតា ត្វំ តាធិ វិធហិ   តលាធំ តលមុត្តំ ។

សូមព្រះអង្គកុំបណ្ដោយ នូវព្រះហឫទ័យក្រោធក៏តែ ចំពោះ អកុសល (របស់អ្នកដទៃ) ដែលប្រព្រឹត្តកន្លង (នូវកុសល) ព្រោះ ថា ត្រកូលជាច្រើនឡាយដែលធ្លាប់ធ្វើកហើយ ច្រើនដល់នូវភាពមិន មែនជាត្រកូលទៅវិញ ព្រោះសេចក្ដីក្រោធ ។ បពិត្រព្រះបិតា សូមព្រះអង្គកុំបណ្ដោយ (មហាជន) ឲ្យធ្លាក់ទៅក្នុងសេចក្ដីវិនាស ដោយគិតថា ខ្ញុំនេះជាធំស្រុក ការកើតឡើងនៃទុក្ខលំបាក កុំ ឲ្យមានដល់ស្រ្ដីបុរសទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ។ គោ- សម្បត្តិទាំងអស់របស់ព្រះបិតា ជាអ្នកប្រាសចាកការព្រឺរោម (ជន ទោនគ្រាគ្រើម) តាមចំណង់ នឹងវិនាសទៅ (ដោយគិត) ថា វិនាសនោះ លោកពោលថាជាទុក្ខរបស់ព្រះបិតា ។ នោះជា ផ្លូវបរកចំណែកនេះឯង នុ៎ះឯងជាអនុសាសនី ដទៃទៀត សូម ព្រះអង្គសង្រ្គោះធ្វើបុណ្យ កុំជាអ្នកពាល កុំញ៉ាំងប្រយោជន៍ឲ្យ វិនាស បពិត្រមហាជន សូមព្រះអង្គមានសីល (ព្រោះថា) បុគ្គលអ្នកទ្រុស្តសីល ឈ្មោះថាជាអ្នកញ៉ាំងខ្លួនឲ្យធ្លាក់ចុះ ។

(៨៧៦) (ព្រះរាជា...) អញបានស្ដាប់សន្ធិៈ ជាកោសិយគោត្រ នឹង តាធិកុណ្ឌលិនី ដោយប្រការដូច្នោះហើយ ក្នុងពេលខាងមុខ ដទៃទៀត អ្នកឲ្យពោល នូវកំឡាំងនិងខ្លួន ជាងកំឡាំងទាំងឡាយ ។

(៨៧៣) ពលំ បញ្ចវិធំ លោកេ បុរិសស្មឹ មហគ្គតេ

តត្ថ ពាហុពលំ នាម ចរិមំ វុច្ចតេ ពលំ

ភោគពលញ្ច ទីឃាវុ ទុតិយំ វុច្ចតេ ពលំ ។

អមច្ចពលញ្ច ទីឃាវុ តតិយំ វុច្ចតេ ពលំ

អភិជច្ចពលញ្ចេវ តំ ចតុត្ថំ អសំសយំ

យានិ ចេតានិ សព្វានិ អធិគណ្ហាតិ បណ្ឌិតោ ។

តំ ពលានំ ពលំ សេដ្ឋំ អគ្គំ បញ្ញាពលំ ពលំ

បញ្ញាពលេនុបត្ថទ្ធោ អត្ថំ វិន្ទតិ បណ្ឌិតោ ។

អបិ ចេ លភតិ មន្ទោ ផីតំ ធរណិមុត្តមំ

អកាមស្ស បសយ្ហំ វា អញ្ញោ តំ បដិបជ្ជតិ ។

អភិជាតោបិ ចេ ហោតិ រជ្ជំ លទ្ធាន ខត្តិយោ

ទុប្បញ្ញោ ហិ កាសិបតិ សព្វេនបិ ន ជីវតិ ។

បញ្ញា សុតវិនិច្ឆិនី បញ្ញា (កិត្តិ) សិលោកវឌ្ឍនី

បញ្ញាសហិតោ នរោ ឥធ (អបិ) ទុក្ខេ សុខានិ វិន្ទតិ ។

(៨៧៣) (សេនកជម្ពូកោធិសត្វ...) កំឡាំងក្នុងលោក មាន ៥ យ៉ាង រមែងមានក្នុងបុរសដែលមានអធ្យាស្រ័យធំ បណ្តាកំឡាំងទាំងនោះ កំឡាំងដៃ (កាយ) បណ្ឌិតពោលថាជាកំឡាំងថោកទាប បពិត្រព្រះអង្គមានព្រះជន្មវែង កំឡាំងភោគៈ បណ្ឌិតពោលថាជាកំឡាំងទី ២ ។ បពិត្រព្រះអង្គមានព្រះជន្មវែង កំឡាំងអាមាត្យ បណ្ឌិតពោលថាជាកំឡាំងទី ៣ កំឡាំងជាតិខ្ពស់ ជាកំឡាំងទី ៤ ឥតសង្ស័យ បុគ្គលជាបណ្ឌិត រមែងគ្របសង្កត់នូវកំឡាំងទាំងអស់នេះ ។ កំឡាំងបញ្ញា នោះជាកំឡាំងប្រសើរ ជាកំឡាំងដ៏ខ្ពស់ជាងកំឡាំងទាំងឡាយ បណ្ឌិតដែលមានកំឡាំងបញ្ញាគ្រាំទ្រហើយ រមែងបាននូវសេចក្តីចំរើន ។ បុគ្គលមានបញ្ញាទន់ ទោះបីបាននូវផែនដីស្តុកស្តម្ភប្រសើរ កាលបើបុគ្គលមានបញ្ញាទន់នោះ មិនមានប្រាថ្នា បុគ្គលដែលមានបញ្ញាដទៃ ធ្វើនូវការកំហែង ហើយគ្រប់គ្រងនូវផែនដីនោះ ។ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី បើទុកជាបុគ្គលមានជាតិខ្ពស់ ជាក្សត្របាននូវរាជ្យ តែឥតប្រាជ្ញា ក៏រមែងមិនរស់នៅ ដោយរាជ្យទាំងពួងបាន ។ បញ្ញាជាគ្រឿងវិនិច្ឆ័យនូវសេចក្តីដែលបានស្តាប់ បញ្ញាជាគ្រឿងញុំាងកេរ្តិ៍ឈ្មោះ និងលាភសក្ការៈឲ្យចំរើន នរជនប្រកបដោយបញ្ញា ក្នុងលោកនេះ សូម្បីទុក្ខ (កើតឡើង) ក៏រមែងបាននូវសុខទាំងឡាយវិញ ។

បញ្ញាញ្ចេ អស្សុតស្ស ច ហោតិ អតិកច្ចតិ

ពហុស្សុតំ អនាគន្តំ ធម្មំ អវិទិត្វាន ។

យោ ច ធម្មវិភង្គញ្ញូ កាលុដ្ឋាយី អតន្ទិតោ

អនុដ្ឋាតា កាលេន កម្មផលំ តស្ស ឥជ្ឈតិ ។

អនាយតនសីលស្ស អនាយតនសេវិនោ

ន និព្វិន្ទិយការីស្ស សម្មទត្ថោ វិបច្ចតិ ។

អជ្ឈត្តញ្ច បយុត្តស្ស តថាយតនសេវិនោ

អនិព្វិន្ទិយការីស្ស សម្មទត្ថោ វិបច្ចតិ ។

យោគប្បយោគសង្ខាតំ សម្ភតស្សានុរក្ខណំ

តានិ ត្វំ តាត សេវស្សុ មា អកម្មាយ រន្ធយិ

អកម្មុនា ហិ ទុម្មេធោ នឡាគារំវ សីទតិ ។

មួយទៀត បុគ្គលណាមួយ មិនស្ដាប់ដោយគោរព មិនជឿនូវបុគ្គលជាពហុស្សុត មិនពេញចិត្តនូវកិច្ចការ ដែលបំពេញនូវប្រយោជន៍ ហើយមិនចុះចូលទៅកាន់ ។ លុះតែបុគ្គលណា ជាអ្នកដឹងនូវចំណែកនៃធម៌ ច្រើនប្រកបកិច្ចការតាមកាល មិនខ្ជិលច្រអូស ច្រើនប្រកបព្យាយាម ។ តាមកាលគួរ ផលកើតអំពីការងារ រមែងសម្រេចដល់បុគ្គលនោះ ។ កាលបុគ្គលមិនមានសីលជាទីកើត (នៃលាភ យស សុខ) សេពគប់នូវបុគ្គលទ្រុស្តសីល មិនជាទីកើត(នៃលាភ យស សុខ) ធ្វើការខ្ជិលច្រអូស រមែងមិនឲ្យផលដោយប្រពៃទេ ។ លុះតែបុគ្គល ប្រកបព្យាយាមក្នុងសន្ដាន សេពគប់នូវបុគ្គលមានសីលជាទីកើត (នៃលាភ យស សុខ) ដូច្នោះ ធ្វើការមិនខ្ជិលច្រអូស ប្រយោជន៍ រមែងឲ្យផលដោយប្រពៃ ។ បពិត្រពាណិជ សូមព្រះអង្គសេពនូវហេតុទាំងឡាយនោះ គឺបញ្ញាជាចំណែកនៃព្យាយាម គឺហេតុដែលរក្សាទ្រព្យ និងការថែទាំនូវទ្រព្យដែលព្រះអង្គបាន ព្រះអង្គកុំ (ញ៉ាំងទ្រព្យ) ឲ្យវិនាស ដោយការងារមិនគួរ ព្រោះថា បុគ្គលឥតបញ្ញា រមែងលិចចុះ (គឺសេចក្ដីវិនាស) ដោយអំពើមិនមែនជាការងារ ដូចផ្ទះដែលគេធ្វើដោយដើមបបុស ។

[៥៧៦] ធម្មំ ចរ មហារាជ មាតាបិតូសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មំ ចរ មហារាជ បុត្តទារេសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មំ ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មំ ចរ មហារាជ វាហនេសុ ពលេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មំ ចរ មហារាជ គាមេសុ និគមេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មំ ចរ មហារាជ រដ្ឋេសុ ជនបទេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

ធម្មំ ចរ មហារាជ សមណេ ព្រាហ្មណេសុ ច

ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។

(៥៧៦) បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបំរើមាតា បិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោក នេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះចំពោះបុត្តភរិយាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមិត្រនឹងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពាហនៈ នឹងពលទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះអ្នកស្រុក នឹងអ្នកនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែននឹងអ្នកជនបទ ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះ ហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្ត ធម៌ ចំពោះអ្នកសមណៈនឹងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ ធម្មោ ចិណ្ណោ សុខាវហោ
ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ ឥន្ទា ទេវា សព្រហ្មកា
សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បាមទោ[១]
តត្រេវ តេ វត្តបទា ឯសា អនុសាសនី
សប្បញ្ញសេវី កល្យាណំ សមត្តំ សាម តំ វិទូតិ ។

តេសកុណជាតកំ បឋមំ ។

សរភង្គជាតកំ

(៥៨៥) អលង្កតា កុណ្ឌលិនោ សុវត្ថា
វេឡុរិយមុត្តាថរុខគ្គពន្ធា
រថេសភា តិដ្ឋថ កេ នុ តុម្ហេ

១ ឱ. បមាទោ ។

បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ក្នុងមិត្រអាមាត្យ ចំពោះពួកមិត្រ និងសេវកបរិវារទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ (ព្រោះថា) ធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំមកនូវសេចក្ដីសុខ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកទេវតាព្រមទាំងព្រះឥន្ទ្រ ទេវតាព្រមទាំងព្រហ្ម បានដល់នូវទិព្វសម្បត្តិ ដោយធម៌ដែលខ្លួនប្រព្រឹត្តល្អ បពិត្រព្រះរាជា សូមព្រះអង្គកុំប្រមាទធម៌ឡើយ ។ នេះជាវត្តបទក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញា សូមមានគុណធម៌ល្អ ព្រះបាទសាមអើយ នូវធម៌នោះ ដឹងច្បាស់ដោយព្រះអង្គឯង (ប្រកបក្នុងធម៌តាមពាក្យទូន្មានប្រាប់នុះ) ។

ចប់ តេសកុណជាតក ទី ១ ។

សរភង្គជាតក

(៥៨៥) (អនុសិស្សតាបសសួរថា) បពិត្រលោក ទាំងឡាយដ៏ប្រសើរ លោកទាំងឡាយ មានខ្លួនប្រដាប់ហើយ មានកុណ្ឌល មានសំពត់ស្លៀកល្អ ស្ពាយព្រះខ័នមានដងប្រដាប់ដោយកែវពិទូរ្យនិងកែវមុក្តា ឈរនៅ (លើរថតែមួយ) លោកទាំងឡាយ ឈ្មោះអ្វី

កាមំ ភេ ជាតមុត្តំ មនុស្សលោកេ ។

(៥៧៦) អហាមន្តុំ ភោ កឹមរេជា ចជោយំ
កាលិន្ទ្រិកជា ឋម ទក្ខោណំ
សុសញ្ញាតនំ វសីនំ ឧស្សូចាយ
វណាកតា ចុម្ពុំតយេត្ត ចណ្ឌោ ។

(៥៧៧) វេហាសយំ តិដ្ឋសិ អន្តលិក្ខេ
បថទ្ធុនោ បណ្ណរសេវ ចន្ទោ
បុច្ឆាមិ តំ យក្ខ មហានុភាវ
កាមម្ពិ ជាតម្ពិ មនុស្សលោកេ ។

(៥៧៨) យមាហុ ទេវេសុ សុជម្បតីតិ
មឃវាតិ តំ អាហុ មនុស្សលោកេ
ស ទេវរាជា ឥធមជ្ជ បត្តោ
សុសញ្ញតានំ វសីនំ ឧស្សូចាយ ។

(៥៧៩) ទូរេ សុតា នោ វសយោ សមាគតា
មហិទ្ធិកា ឥទ្ធិគុណូបបន្នា
វន្ទាមិ តេ អយិរេ បសន្នចិត្តោ
យេ ជីវលោកេត្ថ មនុស្សសេដ្ឋា ។

ពួកជនក្នុងមនុស្សលោក ស្លាប់ទៅកាន់ទីឡាយផ្ទុះឆ្អែត ។

(៥៧៦) (ព្រះភាគ្យព្រះគោមមដ្ឋកៈត្រាស់ថា) ខ្ញុំជាព្រះកាថា ឈ្មោះ អដ្ឋកៈ នេះជាព្រះភាគ្យព្រះគោមតីមានថា នេះជាព្រះភាគ្យព្រះគោមកាលិន្ទ្រ ដែលមានទេវជាធុភាព មានក្តីស៍ព្ទល្បីល្បាញ យើងទាំងឡាយមកក្នុងទីនេះ ដើម្បីឃើញនូវឥសីទាំងឡាយ ដែលសង្រួមល្អហើយ ដើម្បីសួរនូវប្រស្នាទាំងឡាយ ។

(៥៧៧) (អន្តលិក្ខេ...) លោកឋិតនៅក្នុងអាកាស ជាទីកកាយ នៃសត្វស្លាប ដូចព្រះចន្ទក្នុងថ្ងៃ១៥កើត ដែលបិតនៅ អន្តលិក្ខ (អាកាស) ចាំព្រោយក្ស សូមសួរសួរលោក ដែលមានអានុភាពធំ ពួកជនក្នុងមនុស្សលោក ចិត្តស្គាល់ លោកដូចម្តេច ។

(៥៧៨) (សុក្កទេវេន...) ទេវតាទាំងឡាយ ក៏ពួកទេវតា បានហៅ ខ្ញុំណា ថា មឃវ ខ្ញុំនោះ ជាទេវតាមកកាន់ទីនេះ ក្នុង ថ្ងៃនេះ ដើម្បីឃើញឥសីទាំងឡាយ អ្នកសង្រួមល្អហើយ ។

(៥៧៩) ឥសីទាំងឡាយ របស់យើងខ្ញុំ ដែលមកជុំគ្នា មានឫទ្ធិ ប្រកបដោយគុណនៃឫទ្ធិ ល្បីទៅក្នុងទីឆ្ងាយ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលប្រសើរក្នុងពួកមនុស្ស ក្នុងជីវលោកនេះ ។

(៤៨០) គន្ធោ ឥសីនំ ចិរទិក្ខិតានំ
កាយា ចុតោ គច្ឆតិ មាលុតេន
ឥតោ បដិក្កម្ម សហស្សនេត្ត
គន្ធោ ឥសីនំ អសុចិ ទេវរាជ ។

(៤៨១) គន្ធោ ឥសីនំ ចិរទិក្ខិតានំ
កាយា ចុតោ គច្ឆតុ មាលុតេន
វិចិត្របុប្ផំ សុរភឹវ មាលំ
គន្ធញ្ច ឯតំ បដិកង្ខាម ភន្តេ
ន ហេត្ថ ទេវា បដិកូលសញ្ញិនោ ។

(៤៨២) បុរិន្ទទោ ភូតបតី យសស្សី
ទេវានមិន្ទោ មឃវា សុជម្បតិ
ស ទេវរាជា អសុរ (គណ) ប្បមទ្ទនោ
ឱកាសមាកង្ខតិ បញ្ហ បុច្ឆិតុំ ។
កោ នេវិមេសំ ឥធ បណ្ឌិតានំ
បញ្ហេ បុដ្ឋោ និបុណេ ព្យាករិស្សតិ
តិណ្ណញ្ច រញ្ញំ មនុជាធិបានំ
ទេវានមិន្ទស្ស ច វាសវស្ស ។

(៤៨០) (អនុសិស្សតាបស...) ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ រមែងផ្សាយចេញពីកាយទៅតាមខ្យល់ បពិត្រសហស្សនេត្ត សូមព្រះអង្គថយចេញពីទីនេះ បពិត្រទេវរាជ ក្លិនរបស់ឥសីទាំងឡាយមិនស្អាតទេ ។

(៤៨១) (សក្កទេវរាជ...) ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ ចូរផ្សាយចេញពីកាយទៅតាមខ្យល់ចុះ បពិត្រលោកដ៏ចំរើន យើងខ្ញុំតែងប្រាថ្នានូវក្លិននុ៎ះ ដូចបុគ្គលប្រាថ្នានូវកម្រងផ្កាមានផ្កាវិចិត្រ មានក្លិនក្រអូប ព្រោះទេវតាទាំងឡាយ ជាអ្នកមិនមានសេចក្តីសំគាល់ក្នុងក្លិននុ៎ះ ថាជាបដិកូលទេ ។

(៤៨២) (អនុសិស្សតាបស...) ទេវរាជនោះ ឈ្មោះបុរិន្ទទៈ ឈ្មោះភូតបតី ជាអ្នកមានយស ឈ្មោះទេវានមិន្ទៈ ឈ្មោះមឃវា ឈ្មោះសុជម្បតិ ជាអ្នកញាំញី(នូវពួក)អសុរ ទ្រង់ប្រាថ្នានូវឱកាសដើម្បីសួរប្រស្នា ក្នុងទីនេះ បណ្តាឥសីជាបណ្ឌិតទាំងឡាយនេះ បណ្ឌិតណាមួយ ដែលព្រះរាជាទាំង ៣ ព្រះអង្គ ជាធំជាងមនុស្ស និងព្រះវាសវៈជាធំជាងទេវតា ត្រាស់សួរប្រស្នាដ៏ល្អិតហើយ នឹងដោះស្រាយបាន ។

(៤៨៣) អយំ ឥសិ សរភង្គោ តបស្សី

យតោ ជាតោ វិរតោ មេថុនស្មា

អាចេរបុត្តោ សុវិនីតរូបោ

សោ នេសំ បញ្ហានិ វិយាករិស្សតិ ។

(៤៨៤) កោណ្ឌញ្ញ បញ្ហានិ វិយាករោហិ

យាចន្តិ តំ ឥសយោ សាធុរូបា

កោណ្ឌញ្ញ ឯសោ មនុជេសុ ធម្មោ

យំ វុឌ្ឍមាគច្ឆតិ ឯស ភារោ ។

(៤៨៥) កតាវកាសា បុច្ឆន្តុ ភោន្តោ

យំ កិញ្ចិ បញ្ហំ មនសាភិបត្ថិតំ

អហញ្ហិ តំ តំ វោ វិយាករិស្សំ

ញត្វា សយំ លោកមិមំ បរញ្ច ។

(៤៨៦) តតោ ច មឃវា សក្កោ អត្ថទស្សី បុរិន្ទទោ

អបុច្ឆិ បឋមំ បញ្ហំ យញ្ចាសិ អភិបត្ថិតំ ។

(៤៨៣) (ក្រុមឥសី...) ឥសីឈ្មោះសារភង្គៈនេះ មានតបៈ ជាអ្នកវៀរចាកមេថុនធម្ម តាំងអំពីកើតមក ជាបុត្រនៃបុរោហិតដែលជាអាចារ្យ (របស់ព្រះរាជាពារាណសី) មានសភាពរៀបរយល្អហើយ ឥសីឈ្មោះសារភង្គៈនោះ នឹងឆ្លើយនូវប្រស្នាទាំងឡាយ របស់ព្រះរាជាទាំងនោះបាន ។

(៤៨៤) (អនុសិស្សតាបស...) បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសីទាំងឡាយមានសភាពល្អ អារាធនាលោក បពិត្រកោណ្ឌញ្ញៈ ការដោះប្រស្នានុ៎ះ ជាទំនៀមនៃជន ក្នុងពួកមនុស្ស ប្រស្នាណា មកកាន់សេចក្ដីចំរើន ប្រស្នានុ៎ះ ជាភារៈរបស់លោក ។

(៤៨៥) (សារភង្គតាបស...) លោកដ៏ចំរើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវប្រស្នាណាមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខ ដោយខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន ។

(៤៨៦) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ទេវិន្ទ បុរិន្ទទៈ មឃវា សក្កៈ អ្នកឃើញនូវប្រយោជន៍ បានសួរប្រស្នាជាដំបូងដែលខ្លួនបានប៉ងទុកហើយថា

បាលីសង្ខេប ត្រៃ សង្គ្រាមភាគ

កិំសុ ឆេត្វា ន ការាធិ សោចតិ

កិស្សប្បហានំ សំយោ វណ្ណយន្តិ

កាស្សីធ ត្វំ ជហាសិ ទទេថ

អក្ខាហិ មេ គោណ្ឌញ្ញ ឋិតមត្តំ ។

(៨៨៧) កោធំ ឆេត្វា ន ការាធិ សោចតិ

មក្ខប្បហានំ សំយោ វណ្ណយន្តិ

សារម្ភំ ត្វំ ជហាសិ ទទេថ

ឯតំ ខន្តី ទុក្ខមហាហុ សន្តោ ។

(៨៨៨) សព្វា ទុក្ខំ វចនំ តិតិក្ខេ

សមិសស្ស ច សេដ្ឋស្ស ភេទ

កាមំ ន ហីនស្ស វទោ ខមេថ

អក្ខាហិ មេ គោណ្ឌញ្ញ ឋិតមត្តំ ។

(៨៨៩) ភយា ហិ សេដ្ឋស្ស វចោ ខមេថ

សារម្ភហេតុ ចប សាទិសស្ស

យោ ចីធ ហីនស្ស វចោ ខមេថ

បាលីសង្ខេប សង្គ្រាមភាគ ទី ២

បុគ្គលសម្លាប់អ្វី ទើបដេកលក់ គឺមិនមានសេចក្តីសោយ សរសើរនូវការលះបង់អ្វី បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលណាពោលហើយគឺលោក នេះ បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្តីនុះដល់ខ្ញុំ ។

(៨៨៧) (សោកគ្គិតចស...) បុគ្គលសម្លាប់សេចក្តីក្រោធ ទើបមិនក្តៀមក្រំគឺមានសេចក្តីសោយ សរសើរទាំងឡាយ ទើបរិះរសើរនូវការលះបង់នូវសេចក្តីលុបគុណនេះ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្តីអត់ធន់នុ៎ះ ថាជាគុណជាតិដ៏ខ្ពង់ខ្ពស់ ។

(៨៨៨) (សក្កោទោក...) បុគ្គលគាប់អត់ធន់នូវពាក្យរបស់ជនទាំងពួងបាន និងបុគ្គលស្មើគ្នានឹងបុគ្គលប្រសើរជាង ចុះបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលថោកទាប តើដូចម្តេច បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្តីនុះដល់ខ្ញុំ ។

(៨៨៩) (សោកគ្គិតចស...) បុគ្គលអត់ធន់នូវពាក្យ របស់បុគ្គលដ៏ប្រសើរ ព្រោះសេចក្តីខ្លាច ឯបុគ្គលអត់ធន់នូវពាក្យ របស់បុគ្គលស្មើគ្នា ព្រោះហេតុនៃការប្រណាំងប្រជែង ចំណែកបុគ្គលណា គឺលោកនេះ អត់ធន់នូវពាក្យ របស់បុគ្គលថោកទាបបាន

ឯតំ ខន្តិំ ឧត្តមមាហុ សន្តោ ។

(៨៤០) កថំ វិជញ្ញា ចតុមដ្ឋរូបំ

សេដ្ឋំ សរិក្ខំ អថវាបិ ហីនំ

វិរូបរូបេន ចរន្តិ សន្តោ

តស្មា ហិ សព្វេសំ វចោ ខមេថ ។

(៨៤១) ន ហេតមត្ថំ មហតីបិ សេនា

សរាជិកា យុជ្ឈមានា លភេថ

យំ ខន្តិមា សប្បុរិសោ លភេថ

ខន្តិ ពលស្សូបសមន្តិ វេរា ។

(៨៤២) សុភាសិតន្តេ អនុមោទិយាន

អញ្ញំ តំ បុច្ឆាមិ តទិង្ឃ ព្រូហិ

យថា អហុ ទណ្ឌកី នាលិកីរោ

អថជ្ជុនោ កលាពុ ចាបិ រាជា

តេសំ គតិំ ព្រូហិ សុបាបកម្មិនំ

កត្ថូបបន្នា ឥសីនំ វិហេឋកា ។

សប្បុរសទាំងឡាយ ពោលនូវសេចក្ដីអត់ធន់នុ៎ះ (របស់បុគ្គលនោះ) ថាជាគុណជាតិដ៏ខ្ពង់ខ្ពស់ ។

(៨៤០) ម្នាលព្រាហ្មណ៍ បុគ្គលគប្បីដឹងច្បាស់នូវបុគ្គលប្រសើរជាង ឬបុគ្គលស្មើៗគ្នា ឬពួកបុគ្គលថោកទាប ដែលមានសេចក្ដីបរិសុទ្ធ ដោយឥរិយាបថ ៤ បាន សប្បុរសទាំងឡាយ តែងប្រព្រឹត្តតាមរូបនៃបុគ្គលផ្សេងៗគ្នា ព្រោះហេតុនោះ បុគ្គលគួរអត់ធន់នូវពាក្យរបស់បុគ្គលទាំងពួង ។

(៨៤១) សប្បុរស អ្នកមានខន្តិ គប្បីបាននូវសេចក្ដីចំរើនណា សេនាធំប្រកបដោយព្រះរាជា កាលច្បាំងគ្នា មិនគប្បីបាននូវសេចក្ដីចំរើននុ៎ះទេ ពៀរទាំងឡាយរបស់បុគ្គលអ្នកមានខន្តិជាកំឡាំង រមែងស្ងប់រម្ងាប់បាន ។

(៨៤២) (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកពោលប្រស្នានោះ ដូចជាព្រះបាទទណ្ឌកី ព្រះបាទនាលិកីរៈ ព្រះបាទអជ្ជុនៈ នឹងព្រះបាទកលាពុ សូមលោកប្រាប់នូវគតិរបស់ស្ដេចទាំងនោះ ដែលមានបាបកម្មដ៏ក្លៀវក្លា តើព្រះរាជាទាំងនោះ ជាអ្នកបៀតបៀននូវឥសីទាំងឡាយ ទៅកើតក្នុងទីណា ។

(៨៤៣) កឹសុ ហិ វត្វា អបរាធំ ទណ្ឌកី

ទុច្ចិន្តិតោ សមណោ សង្កិច្ចោ

កុក្កុឡនាមេ ចិរយន្តិ បច្ចតិ

តស្ស ផុលិង្គានិ បតន្តិ កាយេ ។

យោ សញ្ញតេ បព្វជិតេ អវញ្ចយិ

ធម្មំ ភណន្តេ សមណេ អទូសកេ

តំ នាឡិកេរំ សុនខា បរត្ថ

សង្គម្ម ខាទន្តិ វិផន្ទមានំ ។

អជ្ជុនោ ចិរាយ សត្តិសូលេ

អវំសិរោ បតិតោ ឧទ្ធំបាទោ

អង្គីរសំ គោតមំ ហេឋយិត្វា ។

ខន្តិំ តបស្សិំ ចិរព្រហ្មចារិំ ។

យោ ចណ្ឌសោ បព្វជិតំ អទេធយិ

ខន្តិំ វទន្តំ សមណំ អទូសកំ

កាលាគុរិជំ ឧបបជ្ជ ខន្តិ

មហាបតាបំ កដុកំ ភយានកំ ។

បិតាច សុត្វា ចិរយាចិ បណ្ឌិតោ

អញ្ញានិ បាបិដ្ឋតរានិ ចេត្ថ

(៨៤៣) (សង្កិច្ចតាបស.) ព្រះរាជាទណ្ឌកី ក្រោធខឹងនឹងតាបសអ្នកដែល

បួសស្អាតហើយ ក៏រាជសាលាឈ្មោះកិសវច្ឆៈ ព្រះអង្គមានមូលរាជធំ

ហើយនាំនរកឈ្មោះកុក្កុឡៈ រងើកភ្លើងតាំងឡើយធ្លាក់ចុះ

តាំងលើកាយនៃព្រះអង្គ ។ ព្រះរាជាកាលិង្គៈណា បៀតបៀន-

បៀតបៀនបព្វជិតតាំងឡើយ ជាអ្នកសង្រួម ជាអ្នកសម្ដែងធម៌ មិន

ប្រទូស្តកុំសំដែងធម៌ ឆ្កែទាំងឡាយតែងនាំស៊ីនូវព្រះរាជា

កាលិង្គៈនោះ ឲ្យរន្ធត់ក្នុងលោកខាងមុខ ។ ឯព្រះរាជាអជ្ជុនៈ

មានព្រះសិរស្សៈក្រោម មានព្រះបាទឡើងលើ ធ្លាក់ក្នុងនរក

ឈ្មោះសត្តិសូលៈ ព្រោះតែបៀតបៀនលោកឈ្មោះអង្គីរសៈ

ជាគោតមគោត្រ ជាអ្នកអត់ធន់ មានតបៈ ប្រព្រឹត្តព្រហ្មចរិយៈ

អស់កាលយូរ ។ ព្រះរាជាកលាពុណា ចុះកាត់ឲ្យជាកំណាត់

នូវនឹងកំណាត់ នូវបព្វជិតដែលពោលនូវខន្តិ ជាអ្នកសម្ងំ

ស្ងប់ ជាអ្នកមិនប្រទូស្ត ព្រះរាជាកលាពុ (នោះ) ក៏កើតនោះ

នៅក្នុងនរកឈ្មោះកាឡិរ មានកំដៅដ៏ខ្លាំង ជាទីគួរខ្លាច

ក្ដៅ ជាទីគួរខ្លាច ។ បណ្ឌិតបានឮនូវនរកទាំងឡាយនេះផង

នូវនរកទាំងឡាយដទៃ ដ៏លាមក លើសជាងនរកនេះផង

ធម្មដ្ឋោ សមណព្រាហ្មណេសុ
សំវិភាគី សក្កច្ច ទេតិ ទានំ ។

(៨៩៤) សុភាសិតន្តំ អនុមោទិយាន
អញ្ញំ តុវំ បុច្ឆាមិ តទិង្ឃ ព្រូហិ
កថំវិធំ សីលវន្តំ វទន្តិ
កថំវិធំ បញ្ញវន្តំ វទន្តិ
កថំវិធំ សប្បុរិសំ វទន្តិ
កថំវិធំ នោ សិរី នោ ជហាតិ ។

(៨៩៥) កាយេន វាចាយ ច យោធ សញ្ញតោ
មនសា ច កិញ្ចិ ន ករោតិ បាបំ
ន អត្តហេតុ អលិកំ ភណាតិ
តថាវិធំ សីលវន្តំ វទន្តិ ។
គម្ភីរបញ្ហំ មនសាភិចិន្តយំ
នច្ចាហិតំ កម្ម ករោតិ លុទ្ទំ
កាលាគតំ អត្ថបទំ ន រិញ្ចតិ
តថាវិធំ បញ្ញវន្តំ វទន្តិ ។

គួរប្រព្រឹត្តគោរពក្នុងសមណព្រាហ្មណ៍ទាំងឡាយ ឲ្យទានដោយគោរពហើយ រមែងកើតក្នុងឋានសួគ៌ ។

(៨៩៤) (សុភាសិតន្ត...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកម្ចាស់ ហើយ សូមសួរនូវប្រស្នាដទៃ ចំពោះលោកម្ចាស់ទៀត សូមលោកម្ចាស់ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយពោលនូវបុគ្គលដែលដូចម្តេច ថាជាអ្នកមានសីល ពោលនូវបុគ្គលដែលដូចម្តេច ថាជាអ្នកមានប្រាជ្ញា ពោលនូវបុគ្គលដែលដូចម្តេច ថាជាសប្បុរស សិរីមិនលះបង់នូវបុគ្គលដែលដូចម្តេច ។

(៨៩៥) (កាយេន វាចាយ...) បុគ្គលណាក្នុងលោកនេះ ជាអ្នកសង្រួមដោយកាយ ដោយវាចា ទាំងមិនធ្វើនូវបាបតិចតួចដោយចិត្ត មិនពោលពាក្យកុហក ព្រោះហេតុនៃខ្លួន បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានសីល ។ បុគ្គលណា កាលគិតនូវប្រស្នាដ៏ជ្រាលជ្រៅដោយចិត្ត ហើយមិនធ្វើនូវអំពើអាក្រក់ ដែលឥតមានប្រយោជន៍ មិនលះបង់នូវចំណែកនៃប្រយោជន៍ ដែលមកដល់ក្នុងកាលគួរ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានបញ្ញា ។

យោ ច កាមញ្ញូ កាមយេតិ ឥធ
កល្យាណមិត្តោ ឧឡារភត្តិ ច ហោតិ
ឧត្តមស្ស សក្កច្ច ករោតិ កិច្ចំ
តថាវិធំ សប្បុរិសំ វទន្តិ ។
ឯតេហិ សព្វេហិ គុណេហុបេតោ
សទ្ធោ មុទុ សំវិភាគី វទញ្ញូ
សង្គាហកំ សខិលំ សណ្ហវាចំ
តថាវិធំ នោ សិរី នោ ជហាតិ ។

(៨៨៦) សុភាសិតន្តេ អនុមោទិយាន
អញ្ញំ តុ បុច្ឆាមិ តទិង្ឃ ព្រូហិ
សីលំ សិរិញ្ចាបិ សតញ្ច ធម្មំ
បញ្ញញ្ច កំ សេដ្ឋតរំ វទន្តិ ។

(៨៨៧) បញ្ញា ហិ សេដ្ឋា កុសលា វទន្តិ
នក្ខត្តរាជារិវ តារកានំ
សីលំ សិរី ចាបិ សតញ្ច ធម្មោ
អន្វាយិកា បញ្ញវតោ ភវន្តិ ។

(៨៨៨) សុភាសិតន្តេ អនុមោទិយាន
អញ្ញំ តុ បុច្ឆាមិ តទិង្ឃ ព្រូហិ

បុគ្គលណា ជាអ្នកដឹងនូវគុណ មានប្រាជ្ញា មានចិត្តស្លូត មានការសេពគប់ល្អ ធ្វើនូវកិច្ចដោយគោរព ចំពោះបុគ្គលអ្នកដល់នូវសេចក្តីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលនោះថាជាអ្នកសប្បុរស ។ បុគ្គលណា ជាអ្នកប្រកបដោយគុណទាំងអស់នេះ ជាអ្នកមានសទ្ធា មានចិត្តទន់ ជាអ្នកចែករំលែក ជាអ្នកដឹងនូវពាក្យ (របស់ស្មូម) សិរីមិនលះបង់នូវបុគ្គលជាអ្នកសង្គ្រោះ មានវាចាពីរោះ មានវាចាផ្អែមល្ហែមនោះទេ ។

(៨៨៦) (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកហើយ សូមសួរនូវប្រស្នាដទៃនឹងលោកទៀត សូមលោកឆ្លើយប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយ ពោលនូវសីលផង សិរីផង ធម៌របស់សប្បុរសផង ប្រាជ្ញាផង តើគុណជាតិណាប្រសើរបំផុត ។

(៨៨៧) (សេនកតាបស...) អ្នកឈ្លាសវៃទាំងឡាយ ពោលថាប្រាជ្ញាជាគុណជាតិប្រសើរបំផុត ដូចស្តេចនៃផ្កាយ (ព្រះចន្ទ្រ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ ចំណែកសីលក្តី សិរីក្តី ធម៌របស់សប្បុរសក្តី ក៏ប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា ។

(៨៨៨) (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកប្រាប់ប្រស្នានោះ

កថង្ករោ កិន្តិករោ កិមាចរំ
កឹ សេវមានោ លភតីធ បញ្ញំ
បញ្ញាយ ទានិប្បដិបទំ វទេហិ
កថង្ករោ បញ្ញវា ហោតិ មច្ចោ ។

(៨៩៩) សេវេថ វុទ្ធេ និបុណេ ពហុស្សុតេ
ឧគ្គាហកោ ច បរិបុច្ឆកោ សិយា
សុណេយ្យ សក្កច្ច សុភាសិតានិ
ឯវង្ករោ បញ្ញវា ហោតិ មច្ចោ ។
ស បញ្ញវា កាមគុណេ អវេក្ខតិ
អនិច្ចតោ ទុក្ខតោ រោគតោ ច
ឯវំវិបស្សី បជហាតិ ឆន្ទំ
ទុក្ខេសុ កាមេសុ មហព្ភយេសុ ។
ស វីតរាគោ ស វិនេយ្យ ទោសំ
មេត្តំ ចិត្តំ ភាវយេ អប្បមាណំ
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អនិន្ទិតោ ព្រហ្មមុបេតិ ឋានំ ។

បុគ្គលក្នុងលោកនេះ ធ្វើដូចម្តេច ធ្វើការដូចម្តេច ប្រព្រឹត្តដូចម្តេច សេពគប់អ្វី ទើបបាននូវប្រាជ្ញា សូមលោកត្រាស់ប្រាប់ នូវបដិបទា នៃប្រាជ្ញាក្នុងកាលឥឡូវនេះ បុគ្គលធ្វើដូចម្តេច ទើបជាអ្នកមានប្រាជ្ញា ។

(៨៩៩) (សរភង្គតាបស...)បុគ្គលគប្បីសេពគប់នូវពួកអ្នកចំរើន(ដោយប្រាជ្ញា) ពួកចេះដឹងនូវធាតុដ៏ល្អិត ជាពហុស្សូត គប្បីជាអ្នករៀនផង ជាអ្នកសាកសួរផង គប្បីស្តាប់នូវសុភាសិតទាំងឡាយ ដោយគោរពផង បុគ្គលធ្វើយ៉ាងនេះ ទើបជាអ្នកមានប្រាជ្ញា ។ បុគ្គលជាអ្នកប្រាជ្ញនោះ ឃើញច្បាស់នូវកាមគុណទាំងឡាយ ជាមិនទៀង ជាទុក្ខ ជារោគ បុគ្គលឃើញច្បាស់ យ៉ាងនេះ ទើបលះបង់នូវឆន្ទៈ ក្នុងកាមទាំងឡាយ ដែលជាទុក្ខ ជាភ័យធំបាន ។ បុគ្គលនោះ ប្រាសចាករាគៈ កំចាត់បង់នូវទោសៈហើយ គប្បីចំរើននូវមេត្តាចិត្ត រកប្រមាណមិនបាន ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងពួង ជាអ្នកដែលបុគ្គលណាមួយ តិះដៀលមិនបាន រមែងទៅកើតក្នុងឋានព្រហ្ម ។

(៦០០) ឧហន្ទិ យំ[១] អាកាសំ អវហាសិ
ករមន្តា កីឡជស្ស ចាចិ
កាលិង្គរាជស្ស ច ឧក្កតស្ស
សព្វេស តេ កាមករោ បហីនោ ។

(៦០១) ឋិតមតិ បរចិត្តវេទិ
សព្វេស តេ កាមករោ បហីនោ
ការេហិ ឱកាសមនុគ្គហាយ
យថា គតិន្តេ អភិសម្ភវេម ។

(៦០២) ការេមិ ឱកាសមនុគ្គហាយ
តថាហិ តេ កាមករោ បហីនោ
ជានំ កាយំ វិញ្ញុណាយ ចិត្តិយា
យថា គតឹ មេ អភិសម្ភវេថ ។

(៦០៣) សព្វំ ករីសង្ឃម គតិនុស្សាសនី
យំ យំ តុវំ វក្ខសិ ភូមិបាល
ជានំ កាយំ វិញ្ញុណាយ ចិត្តិយា
យថា គតិន្តេ អភិសម្ភវេម ។

---

១ ឱ. ឧហន្ទិយំ ។

(៦០០) ដំរីព្រះបាទអង្គដ្ឋក: កាលយានមក នៃព្រះអង្គឯង នៃព្រះបាទ
កិលោធៈឯង នៃព្រះបាទកាលិង្គៈ ដែលមានពេជ្ជានុភាពជាវរ
ហើរឯង ជាព្រះគជដំណើរមានឫទ្ធិដ៏ច្រើន (ព្រោះ) កាមករ
នៃព្រះអង្គទាំងអស់ បាត់លះបង់ហើយ ។

(៦០១) (ព្រះរាជាត់តាំងព្រះអង្គព្រះឥសីសាស្ត្រាថា) លោកម្ចាស់បានដឹង
ច្បាស់នូវចិត្តរបស់បុគ្គលដទៃ ទុំហើរនេះឯង ឯកាមករ យើង
ខ្ញុំទាំងអស់គ្នាបានលះហើយ សូមលោកម្ចាស់ធ្វើឱកាស ដើម្បី
អនុគ្រោះ (យើងខ្ញុំ) ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ។

(៦០២) (ឥសីពោល...) អាត្មាធ្វើឱកាសដើម្បីអនុគ្រោះ ព្រោះ
ថា មហាពលទាំងឡាយបានលះបង់នូវកាមករ ដោយប្រការ
ដូច្នោះមែន មហាពលទាំងឡាយ ចូរញ៉ាំងកាយឲ្យជ្រួតជ្រាប
ដោយបីតិ ដ៏ធំ(ធំពិលាន) ដ៏ឧត្តម ឲ្យមហាពលទាំង
ឡាយបានដល់ នូវគតិរបស់អាត្មាភាព ។

(៦០៣) (ព្រះរាជាទាំងព្រះអង្គ...) បពិត្រលោកអ្នកមានប្រាជ្ញា ដូច
ផែនដី លោកម្ចាស់ពោលពាក្យណាៗ យើងខ្ញុំនឹងធ្វើតាមពាក្យ
របស់លោកទាំងអស់នោះ យើងខ្ញុំនឹងញ៉ាំងកាយឲ្យជ្រួតជ្រាប
ដោយបីតិដ៏ឧត្តម ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ។

(២០៦) អាតាប ខន្តិស្ស ឥសិស្ស បុត្តា

អច្ឆិត្ត កោណ្ឌ ឥសយោ សាធុរូបា

ឈានេ រតា ហោន្ត សទា សមាហិតា

ឯសា រតី បព្វជិតស្ស សេដ្ឋា ។

(២០៧) សុត្វាន គាថា បរមត្ថសញ្ហិតា

សុភាសិតា ឥសិនា បណ្ឌិតេន

តេ វេទជាតា អនុមោទមានា

បក្កាមុ ទេវា ទេវបុរំ យសស្សិនោ ។

គាថា ឥមា អត្ថវតី សុព្យញ្ជនា

សុភាសិតា ឥសិនា បណ្ឌិតេន

យោ កោចិមា អដ្ឋិកត្វា សុណេយ្យ

លភេថ បុព្វាបរិយំ វិសេសំ

លទ្ធាន បុព្វាបរិយំ វិសេសំ

អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

(២០៨) សាលិស្សរោ សារីបុត្តោ មេណ្ឌិស្សរោ ច កស្សបោ

បព្វតោ អនុរុទ្ធោ ច កច្ចាយនោ ច ទេវលោ

អនុសិស្សោ ច អានន្ទោ កិសវច្ឆោ ច កោលិតោ

(២០៦) (សរភង្គតាបស...) ការបួសនេះ ពួកឥសីបានត្រូវហើយ ដល់ឥសីឈ្មោះកិសវច្ឆៈ ឥសីទាំងឡាយដ៏ចំរើន មានសភាពល្អ ចូរទៅចុះ អ្នកទាំងឡាយ ចូរត្រេកអរក្នុងឈាន មានចិត្តតំកល់ស្ងប់ ជានិច្ច នេះជាសេចក្តីត្រេកអរដ៏ប្រសើររបស់បព្វជិត ។

(២០៧) (អភិសម្ពុទ្ធគាថា) ទេវតាទាំងឡាយនោះ មានយស បានស្តាប់នូវគាថាទាំងឡាយ ដ៏ប្រកបដោយប្រយោជន៍ដ៏ក្រៃលែង ដែលឥសីជាបណ្ឌិតពោលល្អហើយ ជាអ្នកមានចិត្តរីករាយហើយ អនុមោទនា ទៀងចេញទៅកាន់ទេវបុរី ។ គាថាទាំងឡាយនេះ មានអត្ថ មានព្យញ្ជនៈដ៏ពីរោះ ដែលឥសីជាបណ្ឌិតពោលល្អហើយ បុគ្គលឯណានីមួយ ស្តាប់គាថាទាំងឡាយនេះ ធ្វើឲ្យមានប្រយោជន៍ រមែងបាននូវគុណវិសេសខាងដើមនិងខាងចុង លុះបាននូវគុណវិសេស ខាងដើមនិងខាងចុងហើយ គប្បីដល់នូវព្រះនិព្វាន ជាគុណមិនឃើញនូវមច្ចុរាជ ។

(២០៨) (ប្រជុំជាតក) សាលិស្សរតាបស គឺសារីបុត្រ មេណ្ឌិស្សរតាបស គឺកស្សបៈ បព្វតតាបស គឺអនុរុទ្ធ ទេវលតាបស គឺកច្ចាយនៈ អនុសិស្សតាបស គឺអានន្ទ កិសវច្ឆតាបស គឺកោលិតៈ

(នារទោ ឧទាយី ថេរោ បរិសា ពុទ្ធបរិសា)

សរភង្គោ ពោធិសត្តោ[1] ឯវំ ធារេថ ជាតកន្តិ ។

សរភង្គជាតកំ ទុតិយំ ។

អលម្ពុសាជាតកំ

(២០៣) អថព្រវិ ព្រហា ឥន្ទោ វត្រភូ ជយតំ បិតា

ទេវកញ្ញំ បរាភេត្វា សុធម្មាយំ អលម្ពុសំ ។

(២០៤) មិស្សេ តំ យាចន្តិ តាវតឹសា សឥន្ទកា

